**មាត្រា ១** : តែងតាំងជាសមាជិកបន្ថែមនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ៖

១-ឯកឧត្តមបណ្ឌិតសភាចារ្យ **ខៀវ ថវិកា** ទីប្រឹក្សារាជរដ្ឋាភិបាល
២-ឯកឧត្តមបណ្ឌិត **សុខ ទូច** ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី និងជាអនុប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា
៣-ឯកឧត្តមបណ្ឌិត **នូ ចាន់សុភី** ប្រធានវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា
៤-ឯកឧត្តមបណ្ឌិត **អ៊ាប បុណ្ណា** ប្រធានវិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃរាជបណ្ឌិត្យសភាកម្ពុជា
៥-ឯកឧត្តម **ផៃ សុខខេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់
៦-លោកបណ្ឌិត **លី ស្មើ** មន្ត្រីខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
៧-លោកបណ្ឌិត **ឆោ ឈុនណារិទ្ធ** មន្ត្រីខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
៨-លោកបណ្ឌិត **សួន ឱសថ** ជំនាញភាសាខ្មែរ បាឡី និងសំស្រ្កឹត

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ២ :** អនុញ្ញាតឲ្យឯកឧត្តម **ឡាយ សុខា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ លាឈប់ពីសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ និង តែងតាំងលោក **ឡាយ ម៉ុនថន** តំណាងក្រសួងមហាផ្ទៃ ជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរជំនួស។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត/០១១៣/០៤៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១៣*

លេខៈ ៧៨ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៣

**អគ្គលេខាធិការរងទីស្ដីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**គណៈកម្មាធិការជាតិភាសាខ្មែរ**
លេខ: ០៣៤/១១ គជភខ

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការអាដហុក ដើម្បីពិនិត្យនិងកែសម្រួលជាបឋមលើវចនាធិប្បាយ ព្រះពុទ្ធសាសនា រៀបរៀងដោយលោក លី រស្មី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង ជាប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា ១២ មាត្រា១៤ មាត្រា១៧ និង មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ ៧៩២ អនក្រ.តត ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលសមាសភាពនៃគណៈកម្មាធិការជាតិភាសាខ្មែរ
- បានឃើញសេចក្ដីសម្រេចលេខ ១២៣ សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្ដីពីការបង្កើតគណៈកម្មការបច្ចេកទេសនៃគណៈកម្មាធិការជាតិភាសាខ្មែរ
- យោងតាមការចាំបាច់

# សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មការអាដហុក ដើម្បីពិនិត្យនិងកែសម្រួលជាបឋមលើវចនាធិប្បាយព្រះពុទ្ធសាសនារៀបរៀង ដោយលោក លី រស្មី ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-លោកជំទាវបណ្ឌិតសភាចារ្យ **ខ្លួត ធីតា** | ប្រធានរាជបណ្ឌិត្យសភាកម្ពុជា | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ **តិច សំណាង** | អគ្គលេខាធិការនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត **ម៉ៅ សុភ្ណន** | ទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤-ឯកឧត្តម **ឈន អៀម** | រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | ទីប្រឹក្សា |
| ៥-ឯកឧត្តម **សូ មុយឃៀង** | សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ | សមាជិក |
| ៦-ឯកឧត្តម **ឃួន វិចិត្រ** | ទីប្រឹក្សាក្រសួងព័ត៌មាន និងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ព័ត៌មាននិងសោតទស្សន៍ នៃក្រសួងព័ត៌មាន | សមាជិក |
| ៧-ឯកឧត្តម **ស៊ឹម សារ៉ាក់** | អតីតអគ្គនាយករដ្ឋបាលនៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | សមាជិក |
| ៨-ឯកឧត្តម **ម៉ន់ សម្បត្តិ** | ទីប្រឹក្សាអមរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ៩-លោកបណ្ឌិត **សន ពៅ** | លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានភាសាជាតិ | សមាជិក |
| ១០-លោក **ជួរ គារី** | ប្រធានផ្នែកខេមរនីយកម្ម វចនានុក្រម និងបកប្រែ នៃវិទ្យាស្ថានភាសាជាតិ | សមាជិក |
| ១១-លោកស្រី **កែវ សុជាតិ** | ប្រធានផ្នែកធម្មសាស្ត្រនិងចរិយាសាស្ត្រ នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម | សមាជិក |
| ១២-លោក **សួន ឱសថ** | មន្ត្រីនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ | សមាជិក |
| ១៣-លោក **មាឃ បូរ៉ា** | មន្ត្រីនៃវិទ្យាស្ថានភាសាជាតិ | សមាជិក |
| ១៤-លោក **ទូច គីមស្រ៊ាង** | សមាជិកក្រុមជំនុំព្រះត្រៃបិដកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ | សមាជិក |
| ១៥-លោកបណ្ឌិត **លី រស្មី** | មន្ត្រីខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន | សមាជិករបាយការណ៍ |

**ប្រការ ២.-**

គណៈកម្មការអាដហុកនេះ មានភារកិច្ចពិនិត្យនិងកែសម្រួលជាបឋមលើវចនាធិប្បាយព្រះពុទ្ធសាសនារៀបរៀងដោយលោក លី រស្មី ដើម្បីឲ្យវចនាធិប្បាយនេះទទួលបាននូវសុក្រឹត្យភាព។

**ប្រការ ៣.-**

ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ និង សមាសភាពដូចមានចែងក្នុងប្រការមួយត្រូវអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិនា ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ **សុខ អាន**

**កន្លែងទទួល៖**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ:** ០៥ សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតគណៈកម្មការអាដហុក**
**ដើម្បីរកគោលការណ៍អានពាក្យកម្ចីពីភាសាបាឡី និង សំស្ក្រឹត**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៧៦ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ១៣៨អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញសេចក្តីសម្រេចលេខ ៦៥សសរ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

# សម្រេច

**ប្រការ១**: បង្កើតគណៈកម្មការអាដហុក ដើម្បីរកគោលការណ៍នៃការអានពាក្យកម្ចីពីភាសាបាឡី-សំស្ក្រឹត ដែលមានសមាសភាពជាសមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ ដូចខាងក្រោម៖

| | |
|---|---|
| ១- លោកបណ្ឌិត **នៅ ស៊ីន** | ប្រធាន |
| ២- លោកបណ្ឌិត **សួន ឱសថ** | អនុប្រធាន |
| ៣- លោក **សឹង ផុស** | សមាជិក |
| ៤- លោក **ឆន់ ហ៊ិន** | សមាជិក |
| ៥- លោក **ទូច គីមស្រ៊ាង** | សមាជិក |

**ប្រការ២**: គណៈកម្មការអាដហុក មានភារកិច្ចរកគោលការណ៍នៃអំណានពាក្យកម្ចីពីភាសាបាឡី-សំស្ក្រឹតដែលមានបញ្ហាក្នុងការអាន ដើម្បីដាក់ជូនក្រុមប្រឹក្សាជាតិភាសាខ្មែរ ពិនិត្យ និង អនុម័ត។

**ប្រការ៣**: គណៈកម្មការអាដហុក មានរយៈពេល២ខែក្នុងការបំពេញកិច្ចការនេះ។

**ប្រការ៤**: ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ និង សមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

ស៊ុខ.អាន

**កន្លែងទទួល៖**

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


**ក្រុមប្រឹក្សាជាតិភាសាខ្មែរ**
អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
គេហទំព័រ : www.nckl.gov.kh, ទូរសព្ទ :០១២ ៤៧៣ ៧០១,០១២ ៩០៦ ៥៨៥,០៩២ ៨៩២ ៣៨៣

National Council of Khmer Language
Conseil National de la Langue Khmère
ទូរសារ : ០២៣ ៨៦៦ ២០៧, អ៊ីមែល : info@nckl.gov.kh


លេខៈ ១៤៦/១៣.ន.ក.ជ.ក/ខ៧

រាជធានីភ្នំពេញ, ថ្ងៃអង្គារ ទី០៤ ខែមិថុនា ឆ្នាំ២០១៣

**<u>សូមគោរពជូន</u>**

**ឯកឧត្តម បណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និង ជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)**

**កម្មវត្ថុ** : សំណើសុំគោលការណ៍បើកថ្នាក់បង្រៀនភាសាខ្មែរ ដល់គ្រូបង្រៀនជនជាតិចិននៅវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា។

**យោង** :
- លិខិតចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១២ របស់វិទ្យាស្ថានខុងជឺ(Confucius Institute Headquarters)
- ចំណារឯកភាពរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១២

ដូចសេចក្តីដែលមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូនឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា កាលពីថ្ងៃទី២២-៣០ ខែវិច្ឆិកា ឆ្នាំ២០១២ វិទ្យាស្ថានខុងជឺប្រទេសចិន បានអញ្ជើញថ្នាក់ដឹកនាំនិងមន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃក.ជ.ភ.ខ.ទៅចូលរួមសិក្ខាសាលាស្តីពី **«វប្បធម៌និងភាសាចិន»**នៅសាកលវិទ្យាល័យ Jiujiang ខេត្ត Jianxi ប្រទេសចិន។ ក្រៅពីកម្មវិធីសិក្ខាសាលា ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានក.ជ.ភ.ខ. និង ថ្នាក់ដឹកនាំសាកលវិទ្យាល័យ Jiujiang មានជំនួបជាមួយគ្នាមួយដែលនៅក្នុងជំនួបនោះ ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យ Jiujiang បានស្នើសុំក.ជ.ភ.ខ.ឱ្យជួយបើកថ្នាក់បង្រៀនភាសាខ្មែរដល់គ្រូបង្រៀនភាសាចិននៃសាកលវិទ្យាល័យJiujiang ដែលមកបង្រៀនភាសាចិននៅវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា ដើម្បីទទួលចំណេះដឹងខាងភាសានិងវប្បធម៌ខ្មែរ និង ជាការប្តូរបទពិសោធន៍គ្នាទៅវិញទៅមក។ ក្រោយមកនៅថ្ងៃពុធ ទី៩ ខែមករា ឆ្នាំ២០១៣ សហប្រធាននៃវិទ្យាស្ថានខុងជឺប្រចាំនៅព្រះរាជាណាចក្រកម្ពុជាបានជួបពិភាក្សាជាមួយខ្ញុំបាទដើម្បីបញ្ជាក់បន្ថែមនូវសំណើខាងលើ ហើយ ខ្ញុំបាទជម្រាបគូភាគីថានឹងយកសំណើនេះសុំឆ្លងយោបល់ឯកភាពពីឯកឧត្តមបណ្ឌិត្យសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

ចំពោះសំណើនេះ ក្រុមប្រឹក្សាជាតិភាសាខ្មែរ យល់ថាជាឱកាសមួយដ៏ល្អសម្រាប់ភាគីកម្ពុជាយើងក្នុងការផ្សព្វផ្សាយភាសានិងវប្បធម៌ខ្មែរទៅក្រៅប្រទេស ក៏ដូចជាការលើកតម្កើងតម្លៃភាសានិងវប្បធម៌ខ្មែរ ជាពិសេសបញ្ជាក់នូវចំណងសាមគ្គីភាពដ៏រឹងមាំជាមួយប្រទេសចិន។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំបាទសូមឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី មេត្តាពិនិត្យ និង សម្រេចដោយក្តីអនុគ្រោះ។

សូមឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី មេត្តាទទួលការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

ក.ជ.ភ.ខ. បណ្ឌិតសភាចារ្យ ព្រុំ ម៉ល់

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
ចូល
មកដល់ថ្ងៃទី 20/6/2013
ម៉ោង ៩.២០
លេខ ០៩៥/៣/១៣ កជភខ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខៈ** ១៧៩៦ ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**គោរពជូន**
**ឯកឧត្តម បណ្ឌិតសភាចារ្យ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

**កម្មវត្ថុ**: ករណីសុំគោលការណ៍បើកថ្នាក់បង្រៀនភាសាខ្មែរដល់គ្រូបង្រៀនជនជាតិចិននៅវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា។

**យោង** : លិខិតលេខ១៤៦/១៣ កជភខ/របហ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ។

ដូចសេចក្តីដែលមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមជ្រាបថា ទីស្តីការគណៈរដ្ឋមន្ត្រីបានឯកភាពជាគោលការណ៍អនុញ្ញាតឱ្យក្រុមប្រឹក្សាជាតិភាសាខ្មែរ បើកថ្នាក់បង្រៀនភាសាខ្មែរ ដល់គ្រូបង្រៀនភាសាចិននៃសាកលវិទ្យាល័យជីវជាំង (Jiujiang) ដែលមកបង្រៀនភាសាចិននៅវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមជ្រាប និង ចាត់ចែងអនុវត្តតាមការគួរ។

**ជ. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**អគ្គលេខាធិការ**

**អ៊ិន-វីរៈជាតិ**

ចម្លងជូន ៖
- វិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី សុខ អាន
- ឯកសារ-កាលប្បវត្តិ

# កិច្ចព្រមព្រៀងស្ដីពី

## «ការបង្កើតថ្នាក់បង្រៀនភាសាខ្មែរសម្រាប់គ្រូបង្រៀនជនជាតិចិន នៃវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា»

## រវាង

## ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)

## និង

## វិទ្យាស្ថានខុងជឺ (វ.ខ.) នៃរាជបណ្ឌិត្យសភាកម្ពុជា

តាមសំណើរបស់សាកលវិទ្យាល័យជីវជាំងJiujiang សុំឱ្យក្រុមប្រឹក្សាជាតិភាសាខ្មែរជួយបង្រៀនភាសាខ្មែរដល់គ្រូបង្រៀននៃវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា និង មានការឯកភាពពីឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទើបក្រុមប្រឹក្សាជាតិភាសាខ្មែរនិងវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា បង្កើតថ្នាក់បង្រៀនភាសាខ្មែរដល់គ្រូបង្រៀនជនជាតិចិនដែលមកបម្រើការងារជូនវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា (ហៅថា ថ្នាក់បង្រៀនភាសាខ្មែរ) តាមលក្ខខណ្ឌដូចខាងក្រោម៖

### ប្រការ១

### លក្ខណៈ

ការបង្កើតថ្នាក់បង្រៀនភាសាខ្មែរនេះគឺដើម្បីផ្តល់ចំណេះដឹងខាងភាសានិងវប្បធម៌ខ្មែរ ការប្តូរបទពិសោធន៍គ្នាទៅវិញទៅមក និង ការពង្រឹងចំណងមិត្តភាព សាមគ្គីភាព រវាងប្រជាជាតិយើងទាំងពីរ(កម្ពុជា-ចិន)ឱ្យកាន់តែស៊ីជម្រៅឡើងថែមទៀត។

### ប្រការ២

### វិសាលភាពនៃសកម្មភាព

អនុលោមតាមតថភាពនៃតំបន់ ថ្នាក់បង្រៀនភាសាខ្មែរត្រូវអនុវត្តតាមកម្មវិធីនិងសកម្មភាពនានាដែលទាក់ទងនឹងភាសានិងវប្បធម៌ខ្មែរ៖

១- រៀបចំកម្មវិធីបង្រៀនភាសាខ្មែរសម្រាប់ជនជាតិចិនដែលបម្រើការនៅវ.ខ.នៃរាជបណ្ឌិត្យសភាកម្ពុជាតាមរយៈពេលជាក់ស្តែង។

២- រៀបចំសកម្មភាពដែលទាក់ទងនឹងការផ្សព្វផ្សាយភាសានិងវប្បធម៌ខ្មែរនៅប្រទេសចិន។

## ប្រការ៣
## ការគ្រប់គ្រងនិងកិច្ចប្រតិបត្តិការ

នៅពេលដែលថ្នាក់បង្រៀនភាសាខ្មែរនេះបានបង្កើត គណៈគ្រប់គ្រងមួយដែលមានសមាសភាពមកពី ក.ជ.ភ.ខ. និង វ.ខ. មានភារកិច្ចរៀបចំផែនការបង្រៀននិងផែនការអភិវឌ្ឍប្រចាំឆ្នាំ និង រាយការណ៍ប្រចាំត្រីមាស អំពីដំណើរការបណ្តុះបណ្តាលជូនប្រធានក.ជ.ភ.ខ. និង ប្រធានរាជបណ្ឌិត្យសភាកម្ពុជា។ ប្រធាន ក.ជ.ភ.ខ.ត្រូវរាយការណ៍អំពីការបើកវគ្គបណ្តុះបណ្តាល និង ការបញ្ចប់វគ្គបណ្តុះបណ្តាលនីមួយៗ ជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ។

ថ្នាក់បង្រៀនភាសាខ្មែរ នឹងចាប់ដំណើរការនៅក្រោយពេលការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

## ប្រការ៤
## ភារកិច្ច

ភារកិច្ចរបស់ ក.ជ.ភ.ខ.ចំពោះថ្នាក់បង្រៀនភាសាខ្មែរ ៖

១- ផ្តល់គ្រូបង្រៀន និង ប្រាក់ម៉ោងបង្រៀន។

២- ផ្តល់សម្ភារៈដែលទាក់ទងនឹងការបង្រៀន។

៣- សម្របសម្រួលការងាររដ្ឋបាលក្នុងកិច្ចដំណើរការងារផ្សេងៗ។

ភារកិច្ចរបស់ វ.ខ.នៃរាជបណ្ឌិត្យសភាកម្ពុជា ៖

១- ចាត់តាំងអ្នកតំណាងតាមការចាំបាច់ដើម្បីសហការជាមួយ ក.ជ.ភ.ខ.

២- ផ្តល់ថ្នាក់រៀននៅក្នុងវ.ខ.និងមានបំពាក់សម្ភារៈឧបទ្ទេសសមស្របតាមនិយាមគរុកោសល្យដើម្បីសម្រួលដល់ការបង្រៀននិងការរៀន។

៣- ផ្តល់ឱកាសដែលអាចធ្វើទៅបានជូនថ្នាក់ដឹកនាំនិងមន្ត្រីរបស់ក.ជ.ភ.ខ.ទៅបំពេញទស្សនកិច្ចសិក្សា នៅប្រទេសចិនក្នុងគោលបំណងផ្សព្វផ្សាយភាសានិងវប្បធម៌ខ្មែរ។

## ប្រការ៥
## អវសានប្បញ្ញត្តិ

ភាគីទាំងពីរនៃកិច្ចព្រមព្រៀង ត្រូវអនុវត្តតាមខ្លឹមសារដែលមានចែងខាងលើដោយការទទួលខុសត្រូវ និង មិនមានការបំពេញបន្ថែម ឬ លុបដោយគ្មានការយល់ព្រមពីភាគីហត្ថលេខីឡើយ។ កិច្ចព្រមព្រៀងនេះមានសុពលភាពរយៈពេល៥ឆ្នាំ។ បើគ្មានការកែប្រែពីភាគីណាមួយទេ កិច្ចព្រមព្រៀងនេះនឹងបន្ត៥ឆ្នាំទៀតដោយស្វ័យប្រវត្តិ។ ភាគីណាដែលមានបំណងចង់បញ្ចប់កិច្ចព្រមព្រៀងនេះ ត្រូវជូនដំណឹងទៅភាគីមួយទៀតឱ្យបាន

មុនរយៈពេល៣ខែ។ កិច្ចព្រមព្រៀងនេះនឹងបញ្ចប់ដោយស្វ័យប្រវត្តិក្នុងករណីដែលមានបញ្ហាពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ កិច្ចព្រមព្រៀងធ្វើឡើងចំនួន០២ច្បាប់ជាភាសាខ្មែរដែលមានតម្លៃស្មើគ្នា។

កិច្ចព្រមព្រៀងនេះមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣

**តំណាងក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិត **សន ពៅ**

**អគ្គលេខាធិការ ក.ជ.ភ.ខ.**

**តំណាងវិទ្យាស្ថានខុងជឺ**

បណ្ឌិត **ជា មុន្នីឫទ្ធិ** **វ៉ង ស៊ាវមាវ**

**សហនាយក វ.ខ.**

# II- សមិទ្ធផល
# នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

## II.1- **សិក្ខាសាលា ស្តីពី «ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ»**

### II.1.1- **របាយការណ៍នៃសិក្ខាសាលា ស្តីពី «ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ»**







កាលពីថ្ងៃព្រហស្បតិ៍ ទី២៥ ខែតុលា ឆ្នាំ២០១២ នៅសាលប្រជុំរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) បានសហការជាមួយក្រសួងព័ត៌មានធ្វើសិក្ខាសាលាមួយ ស្តីអំពី «**ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ**»។

សិក្ខាសាលានេះមានវាគ្មិនចំនួន០៥នាក់ អ្នកសម្របសម្រួលចំនួន០២នាក់ និង ភ្ញៀវចូលរួមចំនួន ៥៥៥នាក់(មកពីក្រសួងព័ត៌មាន ចំនួន៣២៥នាក់, ព្រឹទ្ធសភា, រដ្ឋសភា, ក្រុមប្រឹក្សាធម្មនុញ្ញ, ក្រសួងនិងស្ថាប័ន នានាចំនួន៤៨ នាក់ និង ក.ជ.ភ.ខ.ចំនួន១៨២នាក់)។

បន្ទាប់ពីការអានរបាយការណ៍របស់ឯកឧត្តមបណ្ឌិត **សន ពៅ** អគ្គលេខាធិការនៃក.ជ.ភ.ខ. និង សុន្ទរ-កថាស្វាគមន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ឡាំ ម៉ល់** ប្រធានក.ជ.ភ.ខ. រួចមក ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មានបានថ្លែងសុន្ទរកថាបើកសិក្ខាសាលាស្តីពី«**ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ**» ជូនអង្គពិធី។ ថ្លែងនៅក្នុងឱកាសនោះ ឯកឧត្តមមានប្រសាសន៍ថា បណ្តាអ្នកផ្តល់ព័ត៌មានទាំងឡាយត្រូវតែសរសេរ និយាយ និង ផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវ ដើម្បីឱ្យអ្នកអាន អ្នកស្តាប់ អ្នកទស្សនាអាចទទួលព័ត៌មានបានត្រឹមត្រូវ។ គោលបំណងរបស់រាជរដ្ឋាភិបាលចង់ឱ្យការប្រើប្រាស់ភាសាខ្មែរមានឯកភាពគ្នា ជាពិសេស ប្រព័ន្ធផ្សព្វផ្សាយតែម្តង។ សព្វថ្ងៃនេះ ប្រទេសកម្ពុជាមានស្ថានីយទូរទស្សន៍ចំនួន១៣, ស្ថានីយវិទ្យុចំនួន១០១ និង អង្គភាពសារព័ត៌មានជាច្រើនទៀត។ ឯកឧត្តមបានដាស់តឿនដល់អ្នកមានតួនាទីផ្សព្វផ្សាយព័ត៌មានទាំងឡាយត្រូវតែទាក់ទងមកក្រុមប្រឹក្សាជាតិភាសាខ្មែរ នៅពេលដែលខ្លួនមិនច្បាស់លាស់ក្នុងការប្រើពាក្យណាមួយ។ ឯកឧត្តមបានសំណូមពរដល់ក្រុមប្រឹក្សាជាតិភាសាខ្មែរឱ្យចងក្រងនិងបោះពុម្ពនូវឯកសារដែលខ្លួនបានអនុម័តរួចជាព្រឹត្តិបត្រឬសៀវភៅ ដើម្បីឱ្យអ្នកផ្សព្វផ្សាយព័ត៌មានទាំងអស់ងាយស្រួលសិក្សាស្រាវជ្រាវ។ ជាមួយគ្នានោះដែរ ឯកឧត្តមរដ្ឋមន្ត្រីបានផ្តល់អនុសាសន៍មួយចំនួនដល់ពិធីករ ពិធីការិនី គ្រប់ស្ថានីយទូរទស្សន៍និងវិទ្យុទាំងអស់ប្រមូលផ្តុំគ្នាបង្កើតជាសមាគមពិធីករ ពិធីការិនីមួយឡើង ដើម្បីងាយស្រួលក្នុងការទាក់ទងគ្នានិងចែករំលែកបទ-

ពិសោធន៍ឱ្យគ្នាទៅវិញទៅមក។ ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ថា អ្នកកាសែតនិងទស្សនាវដ្ដី គេមានសមាគម របស់គេរួចហើយ។

នៅក្នុងដំណើរការនៃអង្គសិក្ខាសាលា បទបង្ហាញទីមួយ ស្ដីអំពី ‹ការប្រព្រឹត្តទៅរបស់ ក.ជ.ភ.ខ.› វាគ្មិន ឯកឧត្តមបណ្ឌិត **សន ពៅ** បង្ហាញថា៖

មុននឹងមានក្រុមប្រឹក្សាជាតិភាសាខ្មែរ យើងមានគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ.) ដែលបាន បង្កើតឡើងតាមរយៈអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧។ គណៈកម្មការនេះបាន បំពេញភារកិច្ចរបស់ខ្លួនរហូតមកដល់ឆ្នាំ២០១១ដោយអនុម័តបានលទ្ធផលធំៗជាច្រើន។ ឯកឧត្តមបណ្ឌិតបាន បញ្ជាក់ពីទិសដៅថ្ងៃមុខរបស់ក.ជ.ភ.ខ.ថា នឹងរៀបចំពាក្យដែលបានអនុម័តរួចបោះពុម្ពជាសទ្ទានុក្រមទៅតាម មុខជំនាញនីមួយៗ ដើម្បីបម្រើដល់ការប្រើប្រាស់ឱ្យមានឯកភាព ទាំងអក្ខរាវិរុទ្ធនិងអំណាន និង ការបង្កើតពាក្យ ជាដើម។

វាគ្មិនទីពីរ ឯកឧត្តមបណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់** ធ្វើបទបង្ហាញស្ដីអំពី ‹សារបាននិងសមិទ្ធផលនៃក.ជ.ភ.ខ.›។ ឯកឧត្តមបណ្ឌិតសភាចារ្យបានរំឭកពីសាវតារនៃការអភិវឌ្ឍអក្សរសាស្ត្រខ្មែរ ដែលបានឆ្លងកាត់ដំណាក់កាលសំខាន់ៗជា ប្រវត្តិសាស្ត្រ។ ដំណាក់កាលទីមួយ គឺការកើតឡើងនៃក្រុមជំនុំរៀបចំវចនានុក្រមខ្មែរ នៅឆ្នាំ១៩១៥, បន្ទាប់មក នៅឆ្នាំ១៩៣៤ គឺការកើតឡើងនៃគណៈកម្មការវប្បធម៌ និង នៅឆ្នាំ១៩៦៧ គណៈកម្មាធិការជាតិអចិន្ត្រៃយ៍ នៃខេមរយានកម្ម (ដំណាក់កាលទីមួយ)បានកើតឡើង។ គណៈកម្មាធិការជាតិនេះបានបន្តរហូតមកដល់របប សាធារណរដ្ឋខ្មែរដែលជាដំណាក់កាលទីពីរ។ រីឯ គ.ជ.ភ.ខ.ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៧ តាមរយៈ ការរៀបចំសន្និសីទជាតិចំនួនបីលើករបស់វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា។ គណៈកម្មាធិការ ជាតិនេះបានដំណើរការរហូតមកដល់ឆ្នាំ២០១១ ទើបរាជរដ្ឋាភិបាលកម្ពុជាបង្កើតឱ្យមានក.ជ.ភ.ខ.នេះឡើង ជំនួសគ.ជ.ភ.ខ.ដើម្បីពង្រីកនិងពង្រឹងការស្វែងរកការឯកភាពក្នុងភាសាខ្មែរឱ្យកាន់តែមានប្រសិទ្ធភាព។ ចំពោះ ភារកិច្ចរបស់គ.ជ.ភ.ខ.ដំណាក់កាលទីមួយបានអនុម័ត៖ -យកវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ធ្វើជាមូលដ្ឋាន ក្នុងការសរសេរអក្ខរាវិរុទ្ធ, -គោលការណ៍បង្កើតពាក្យ/កម្ចីពាក្យ, -ការសរសេរអក្សរខ្មែរក្នុងការកត់ត្រាសូរបរទេស, -ពាក្យសម្គាល់ឈ្មោះប្រទេស រាជ/រដ្ឋធានី, -ពាក្យដែលគណៈកម្មការបច្ចេកសព្ទទាំង៨បានស្នើ, -បទបញ្ជាផ្ទៃ ក្នុងនៃគ.ជ.ភ.ខ., -ដោះស្រាយបញ្ហាផ្សេងៗដែលក្រសួង ស្ថាប័ន អង្គភាពមួយចំនួនបានស្នើមក ដូចជា ការ ពន្យល់ពាក្យ ការប្រែពាក្យ ការបង្កើតពាក្យ គោរមងារ។ល។ និង ដោះស្រាយសំណួររបស់មហាជនដែលមាន ចម្ងល់ពីបញ្ហាអក្សរសាស្ត្របានភ្លាមៗ តាមរយៈអង់តែនដែលគ.ជ.ភ.ខ.បានបង្កើត។

ឯកឧត្តមបានបញ្ជាក់ថា សិក្ខាសាលានាថ្ងៃនេះមានគោលបំណងផ្សព្វផ្សាយអ្វីដែលក.ជ.ភ.ខ.សម្រេច បានជូនដល់បងប្អូនទាំងអស់ដែលមានតួនាទីផ្សព្វផ្សាយព័ត៌មានបានយល់ដឹងពីការប្រើប្រាស់ភាសាខ្មែរ ពីព្រោះ ពួកគេមានឥទ្ធិពលធំធេងខ្លាំងណាស់ទៅលើសាធារណជនក្នុងការប្រើប្រាស់ភាសាខ្មែរ តាមរយៈពាក្យសម្ដីនិង ការសរសេរ(អក្ខរាវិរុទ្ធ)។ ទន្ទឹមនឹងនោះ ឯកឧត្តមបណ្ឌិត្យសភាចារ្យបានបង្ហាញពីទិសដៅរបស់ក.ជ.ភ.ខ.ថា ទៅថ្ងៃ មុខ ក.ជ.ភ.ខ. នឹងបោះពុម្ពសទ្ទានុក្រមនូវពាក្យតាមជំនាញនីមួយៗ ដែលខ្លួនបានអនុម័តរួច។

វាគ្មិនទីបី ឯកឧត្តម **ម៉ៅ អាយុទ្ធ** បទបង្ហាញស្ដីអំពី ‹សិល្បៈនៃការនិយាយរបស់ពិធីករ និង ពិធីការិនី› ជាដំបូង ឯកឧត្តមបានកោតសរសើរអំពីកិច្ចសហប្រតិបត្តិការរវាង ក.ជ.ភ.ខ.និងក្រសួង ព័ត៌មានដែលបានផ្ដួចផ្ដើម

ឱ្យមានសិក្ខាសាលានេះឡើង ដើម្បីជាទុនមួយក្នុងការរួមចំណែកលុបបំបាត់មតិរិះគន់ថា ‹ខ្លួនជាខ្មែរ សរសេរនិងនិយាយខ្មែរមិនត្រឹមត្រូវ›។ ឯកឧត្តមមានប្រសាសន៍ថា ពិធីករ ពិធីការិនី មិនមែនជាសាស្ត្រាចារ្យទេ ប៉ុន្តែពិធីករ ពិធីការិនីបានបំពេញតួនាទីជាអ្នកនិយាយរាល់ថ្ងៃទៅកាន់អ្នកស្តាប់ អ្នកទស្សនាគ្រប់ស្រទាប់វណ្ណៈចំនួន១៤លាននាក់ នៅទូទាំងប្រទេស។ ឯកឧត្តមបានបង្ហាញពីចំណុចវិជ្ជមាននិងអវិជ្ជមានរបស់ពិធីករ ពិធីការិនី ដូច្នេះថា៖

- ចំណុចអវិជ្ជមាន ពិធីករ ពិធីការិនីខ្លះនិយាយមិនទាន់ត្រឹមត្រូវ និយាយខុសរបៀប បានត្រឹមតែបង្ហាញសម្រស់ប៉ុណ្ណោះ។

- ចំណុចវិជ្ជមាន ពិធីករ ពិធីការិនី ត្រូវចេះរៀបចំខ្លួនឱ្យបានល្អ ស្លៀកពាក់សមស្របទៅតាមកម្មវិធី, ត្រូវចេះរៀបចំឫកពារឱ្យបានសមរម្យមិនឆ្គាំឆ្គង, និយាយស្តីត្រូវសមរម្យទៅតាមកម្មវិធី ត្រូវចេះប្រមូលផ្តុំអារម្មណ៍ឱ្យបានច្បាស់លាស់និងមានការជឿជាក់លើខ្លួនឯង។

ឯកឧត្តមបានផ្តល់អនុសាសន៍ដូច្នេះថា៖ ពិធីករ ពិធីការិនីទាំងអស់ត្រូវហ្វឹកហាត់និយាយនៅក្រៅឆាកជាមុនឱ្យបានច្រើនដង, ចំនួនលេខឬតួលេខត្រូវសរសេរជាអក្សរ ដើម្បីងាយអាន, រាល់ការនិយាយនិងការធ្វើកាយវិការផ្សេងៗត្រូវប្រុងប្រយ័ត្នគ្រប់ពេល, មិនត្រូវយកឱកាសសម្រាកពីរឬបីនាទីក្នុងកម្មវិធីរបស់ខ្លួនទៅនិយាយលេងសើចនោះទេ។ ចំពោះពាក្យណាមិនយល់ត្រូវបើកវចនានុក្រមខ្មែរមើល ឬ សួរមកក្រុមប្រឹក្សាជាតិភាសាខ្មែរ។

បទអន្តរាគមន៍ទីបួន ស្តីអំពី‹ ឈ្មោះប្រទេស រាជ/រដ្ឋធានី› ឯកឧត្តមបណ្ឌិត **ច័ន្ទ សំណព្វ** អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរបានលើកឡើងថា ៖ ទិដ្ឋភាពទូទៅ បុព្វបុរសខ្មែរបានយល់ដឹងពីបាតុភូតធម្មជាតិ របកគំហើញវិទ្យាសាស្ត្រ ភាសាវិទ្យា ជាដើម ហើយបានបង្កើតពាក្យតាមវិធីកម្លាយឬវិធីផ្សេងទៀត។ ចំពោះការខ្ចីពាក្យពីបរទេសមកប្រើក្នុងភាសាខ្មែរ ស្ទើរតែក្លាយទៅជាយន្តការមួយដែលជំនួសឱ្យការបង្កើតពាក្យថ្មីដើម្បីស្តែងពីបញ្ញត្តិដែលកើតចេញពីរបកគំហើញថ្មីៗក្នុងវិស័យនានា ជាពិសេស ផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា មានពាក្យ កុំព្យូទ័រ ព្រីនធ័រ អ៊ីនធឺណិត អ៊ីមែល ។ល។ ចំពោះការសរសេរនិងហៅឈ្មោះប្រទេសមួយចំនួនបានបង្កើតបញ្ហាចម្រូងចម្រាសនិងខ្វះឯកភាពនៅក្នុងការប្រើប្រាស់ ដូចជា ប្រទេសស្វ៊ីស គេបែរជាហៅ ស៊្វីសឡែន, ប្រទេសស៊ីប គេបែរជាហៅ សៃប្រឹស, ប្រទេសសិង្ហបុរី បែរជាហៅ សាំងកាពួ, ប្រទេសកូតឌីវ័រ បែរជាហៅ អាយវ៉ឺរីខូស ។ល។ ឯកឧត្តមបានបញ្ជាក់ថា បច្ចុប្បន្ន គ.ជ.ភ.ខ.បានអនុម័តឈ្មោះប្រទេស រាជ/រដ្ឋធានី និង ការកំណត់សញ្ញាព្យញ្ជនៈសម្រាប់កត់ត្រាសូរនៃពាក្យក្នុងភាសាបរទេសដោយឈរលើមូលភេទ អ/អ៊ ជាផ្លូវការហើយ។

បទអន្តរាគមន៍ទីប្រាំ ស្តីអំពី‹សីលធម៌របស់ពិធីករ ពិធីការិនីនៃវិទ្យុនិងទូរទស្សន៍› លោកជំទាវ **ចាន់ ធី** បានលើកពីទំនាក់ទំនងរវាងអ្នកនិយាយ និង អ្នកស្តាប់/អ្នកទស្សនាថា ប្រសិនបើអ្នកនិយាយមិនល្អដោយខ្វះសីលធម៌ធ្វើឱ្យអ្នកស្តាប់និងអ្នកទស្សនាទទួលយកមិនបាន ផ្ទុយទៅវិញ ប្រសិនបើអ្នកនិយាយប្រកបទៅដោយសីលធម៌ល្អ ប៉ុន្តែអ្នកទស្សនា អ្នកស្តាប់មិនយកចិត្តទុកដាក់ អាចធ្វើឱ្យអ្នកនិយាយបាក់កម្លាំងចិត្ត។ ពិធីករ ពិធី-ការិនីត្រូវយល់អំពីគោលបំណងមួយចំនួនរបស់អ្នកស្តាប់និងអ្នកទស្សនា។ ក្នុងកម្មវិធីកម្សាន្ត ពិធីករ ពិធីការិនីត្រូវចេះនិយាយដើម្បីបង្កើតបរិយាកាសរីករាយ ការនិយាយត្រូវស្របនឹងខ្លឹមសារកម្មវិធី មិនត្រូវនិយាយយូរពេក នាំឱ្យអ្នកស្តាប់ អ្នកទស្សនាធុញទ្រាន់នោះទេ។ ពិធីករ ពិធីការិនីមិនត្រូវយករឿងប្រឌិតឬពាក្យចចាមអារ៉ាមមកនិយាយដែលនាំឱ្យបង្កចលាចលដល់សង្គម។ ពិធីករ ពិធីការិនីត្រូវចេះនិយាយផ្តល់នូវចំណេះដឹង ទស្សនៈល្អៗដល់អ្នកស្តាប់និងអ្នកទស្សនា។ លោកជំទាវបានលើកពីចំណុចល្អនិងចំណុចមិនល្អក្នុងការអានឯកសារដូច្នេះថា៖ ចំណុច

ល្អ ពិធីករ ពិធីការិនីនិយាយចប់តាមពេលវេលាកំណត់ មានអត្ថន័យស្របតាមផែនការដែលបានត្រៀមទុក ប្រើភាសាបានសមរម្យ។ ចំណុចមិនល្អ ពិធីករ ពិធីការិនី និយាយឬអានសម្លឹងទៅរកអ្នកទស្សនា/អ្នកស្ដាប់តិចតួច មិនមានអារម្មណ៍ចូលជាមួយអ្នកស្ដាប់/អ្នកទស្សនា។ លោកជំទាវក៏បានផ្ដល់អនុសាសន៍ថា ពិធីករ ពិធីការិនីត្រូវអានឱ្យបានច្រើនចប់ជាមុនសិន មុននឹងឡើងអាន, អត្ថបទត្រូវកៀបនឹងក្រដាសរឹង ប្រសិនបើអត្ថបទសរសេរលើក្រដាសទន់ ត្រូវចេះប្រើសំឡេង កាយវិការ ស្លៀកពាក់ តុបតែងខ្លួនឱ្យបានសមរម្យ, ពាក្យពេចន៍ ដែលនិយាយចេញទៅ ត្រូវមានអត្ថន័យខ្លឹមសារល្អ អាចឱ្យអ្នកស្ដាប់/អ្នកទស្សនាយកជាគតិបាន។

បន្ទាប់ពីបទបង្ហាញរបស់របស់វាគ្មិន សមាជិក សមាជិកានៃអង្គសិក្ខាសាលាបានសួរនូវសំណួរជាច្រើនទៅកាន់វាគ្មិននិងអ្នកជំនាញខាងអក្សរសាស្ត្រ ដើម្បីធ្វើការបកស្រាយ និង ពន្យល់នូវពាក្យនិងការប្រើប្រាស់ពាក្យមួយចំនួន ដើម្បីឱ្យពួកគេប្រើប្រាស់ភាសាខ្មែរបានត្រឹមត្រូវនិងលែងមានការភាន់ច្រឡំ។

លោកជំទាវបណ្ឌិតសភាចារ្យ **ខ្លូត ធីតា** ទីប្រឹក្សាផ្ទាល់សម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និង ជាអនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ. ភ.ខ.) បានអានរបាយការណ៍បូកសរុបរបស់សិក្ខាសាលាដែលមានខ្លឹមសារដូចតទៅ៖

វាគ្មិនម្នាក់ៗបានបង្ហាញពីការប្រើប្រាស់ភាសាដែលត្រឹមត្រូវ មានទាំងរបៀបក្នុងការអាន ការនិយាយ ការសរសេរ ការហៅឈ្មោះប្រទេសត្រឹមត្រូវដល់អង្គសិក្ខាសាលាទាំងមូល។ ក្នុងរយៈពេលមួយថ្ងៃនេះ អង្គសិក្ខាសាលាទទួលបានអនុសាសន៍សំខាន់ៗមួយចំនួនពីសមាជិក សមាជិកា ដែលមានសេចក្ដី ដូចខាងក្រោម៖

១- ក.ជ.ភ.ខ. គប្បីរៀបចំកម្មវិធីផ្សព្វផ្សាយពីការប្រើភាសាខ្មែរតាមវិទ្យុ ទូរទស្សន៍ និង ធ្វើសិក្ខាសាលាស្ដីពីភាសាខ្មែរឱ្យបានញឹកញាប់។

២- ក្នុងការនិយាយនិងការសរសេរ ពិធីករ ពិធីការិនី អ្នកសារព័ត៌មានត្រូវអនុវត្តតាមវចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត** បោះពុម្ព ឆ្នាំ១៩៦៧-១៩៦៨ ជាមូលដ្ឋាន, វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែររបស់វិទ្យាស្ថានភាសាជាតិនិងបច្ចេកសព្ទនានាដែលក.ជ.ភ.ខ.បានអនុម័ត។

៣- ពិធីករ ពិធីការិនី អ្នកសារព័ត៌មាន ត្រូវអាន និយាយ និង សរសេរឈ្មោះប្រទេស រាជ/រដ្ឋធានីនៅលើពិភពលោកតាមសេចក្ដីសម្រេចរបស់ក.ជ. ភ.ខ.។

៤- ស្នើក្រសួងព័ត៌មាន មេត្តាឧស្សាហ៍បណ្ដុះបណ្ដាលពិធីករ ពិធីការិនីឱ្យបានញឹកញាប់។

៥- ការបង្កើតពាក្យថ្មី (ពាក្យតែមួយម៉ាត់)គួរប្រើពាក្យខ្មែរ ប្រសើរជាងប្រើពាក្យបាលី។

៦- គួររកអ្នកជំនាញអក្សរសាស្ត្រជួយអ្នកសរសេរអក្សរខារ៉ាអូខេ។

៧- ក.ជ.ភ.ខ.និងក្រសួងព័ត៌មាន គួរបែងចែក ពាក្យ«ផ្លាក»និង«ស្លាក»ឱ្យបានដាច់ដោយឡែកពីគ្នា។

៨- ពិធីករ ពិធីការិនី ត្រូវចេះស្រាវជ្រាវនិងប្រើពាក្យក្នុងការនិយាយឱ្យបានត្រឹមត្រូវតាមឋានានុក្រមក្នុងសង្គមខ្មែរឱ្យបានត្រឹមត្រូវ។

អង្គសិក្ខាសាលាបានបិទនៅវេលាល្ងាចថ្ងៃដដែល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានកិត្តិយសក្រុមប្រឹក្សាជាតិភាសាខ្មែរ ព្រមទាំងមានចែកវិញ្ញាបនបត្រជូនសិក្ខាកាមទាំងអស់ដែលបានចូលរួមសិក្ខាសាលានេះផងដែរ។

ឯកឧត្តមបណ្ឌិត្យសភាចារ្យ ឧបនាយករដ្ឋមន្ត្រីបានថ្លែងនៅក្នុងឱកាសបិទអង្គសិក្ខាសាលានេះដូច្នេះថា ការប្រើប្រាស់ពាក្យពេចន៍និងអក្ខរាវិរុទ្ធបានត្រឹមត្រូវ ពិតជារួមចំណែកយ៉ាងសំខាន់ក្នុងការថែរក្សាវប្បធម៌និងអត្តសញ្ញាណជាតិ។ យ៉ាងណាមិញ ការប្រើប្រាស់ភាសា រួមមាន ការប្រើពាក្យពេចន៍និងអក្ខរាវិរុទ្ធនៅតាមប្រព័ន្ធផ្សព្វផ្សាយមិនបានសមស្របឬប្រាសចាកពីការពិត វានឹងអាចក្លាយជាអាវុធមុខពីរ។ ឯកឧត្តមបន្តទៀតថា ភាសាត្រូវបានគេយកទៅប្រើប្រាស់ទាក់ទងគ្នាក្នុងគ្រប់រូបភាព។ ចំណែកឯការប្រើប្រាស់ភាសាតាមប្រព័ន្ធផ្សព្វផ្សាយអាចជះឥទ្ធិពលមិនល្អដល់ផ្នត់គំនិត ចិត្តសាស្ត្រ ស្មារតីសង្គម និង តម្លៃវប្បធម៌ជាតិ ក៏ដូចជាអាចបណ្តាលឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បញ្ហាសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខនិងសុវត្ថិភាពសង្គម។ ផ្ទុយទៅវិញ ប្រសិនបើការប្រើប្រាស់ពាក្យសម្តីប្រកបដោយសច្ចភាពនិងវិជ្ជាជីវៈខ្ពស់ អាចរួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹងស្មារតីជំនឿទុកចិត្តនិងការលើកកម្ពស់មោទនភាពជាតិ។ ឯកឧត្តមមានប្រសាសន៍បន្តទៀតថា ការប្រើប្រាស់ភាសាតាមប្រព័ន្ធផ្សព្វផ្សាយមានតួនាទីយ៉ាងសំខាន់ក្នុងការអប់រំបណ្តុះបណ្តាលនិងបង្កើនសមត្ថភាពយល់ដឹងឱ្យកាន់តែទូលំទូលាយថែមទៀតដល់ប្រជាពលរដ្ឋ។ ឯកឧត្តមមានសំណូមពរនិងផ្តាំផ្ញើដល់ពិធីករ ពិធីការិនី អ្នកធ្វើអត្ថាធិប្បាយតាមប្រព័ន្ធផ្សព្វផ្សាយទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ខ្ពស់និងប្រុងប្រយ័ត្នជាប់ជានិច្ចចំពោះការប្រើប្រាស់ភាសាជាតិឱ្យបានត្រឹមត្រូវ។ ទាំងអស់គ្នាត្រូវខិតខំប្រឹងប្រែងរៀនសូត្រនិងហ្វឹកហាត់ក្នុងការប្រើប្រាស់ភាសាខ្មែរឱ្យកាន់តែប្រសើរឡើងថែមទៀត ជាពិសេសរាល់ការប្រើប្រាស់នូវសំនួនវោហារសព្ទ ត្រូវតែស៊ីសង្វាក់ទៅនឹងបរិបទនិងសាច់រឿងដែលខ្លួនកំពុងនិយាយ។ ទន្ទឹមនឹងនោះដែរ ឯកឧត្តមក៏បានអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័នរដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់និងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ សូមបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនឹងក្រុមប្រឹក្សាជាតិភាសាខ្មែរឱ្យកាន់តែទូលំទូលាយថែមទៀត ដើម្បីឱ្យការប្រើភាសានិងអក្សរខ្មែរកាន់តែរលូនទៅមុខ និងមានការឯកភាពគ្នាជាចរន្តតែមួយ។

## II.1.2- សុន្ទរកថាស្វាគមន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រាំ ម៉ល់ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.)

ក្នុងពិធីបើកសិក្ខាសាលា ស្តីពី «**ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ**»

ថ្ងៃព្រហស្បតិ៍ ទី២៨ ខែតុលា ឆ្នាំ២០១២ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២

**ខ្ញុំព្រះករុណា ខ្ញុំបាទ ខ្ញុំ**

- សូមក្រាបថ្វាយបង្គំ ៖
  - ព្រះមុនីកោសល **ហ៊ុល សុវណ្ណ** រាជាគណៈថ្នាក់ទោ អនុគណខណ្ឌឫស្សីកែវ សមាជិកថេរ-សភាសង្ឃ ព្រះចៅអធិការវត្តទួលសុវណ្ណារាម និង ជាឧត្តមទីប្រឹក្សានៃក.ជ.ភ.ខ. ជាទីសក្ការៈ,
  - ព្រះតេជព្រះគុណ **យស ហ៊ុត** ខេមចារោ ប្រធានស្តីទីសមាគមធម្មទូត និង ជាប្រធានមូលនិធិពុទ្ធសាសនាខ្មែរ-វត្តធម្មវង្សី ជាសមាជិក ក.ជ.ភ.ខ. ជាទីសក្ការៈ,
  - ព្រះតេជព្រះគុណគ្រប់ព្រះអង្គ ជាទីសក្ការៈ,
- សូមគោរព ៖
  - ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាឧត្តមទីប្រឹក្សា ក.ជ.ភ.ខ. ជាទីគោរព,
  - ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ជាទីគោរព,
  - ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយស ជាទីគោរព,
  - ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកសារព័ត៌មាន អ្នកសរសេរទស្សនាវដ្តី អ្នកជំឡើងអក្សរតាមកញ្ចក់ទូរទស្សន៍ តាមខារ៉ាអូខេ ពិធីករ ពិធីការិនី ជាទីគោរពរាប់អាន,
  - ឯកឧត្តម លោកជំទាវ លោក លោកស្រី អនុប្រធាន ទីប្រឹក្សា អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាន សមាជិក និង សមាជិកានៃគណៈកម្មការបច្ចេកសព្ទនានា មន្ត្រីអគ្គលេខាធិការដ្ឋាននៃ ក.ជ.ភ.ខ. ជាទីមេត្រី,

**អង្គពិធីទាំងមូល ជាទីគោរព**,

ថ្ងៃនេះ ជាថ្ងៃវិសេសវិសាលក្រៃលែង ដោយឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មានផ្តល់កិត្តិយសដល់ក.ជ.ភ.ខ. ព្រមអញ្ជើញជាអធិបតីក្នុងឱកាសបើកសិក្ខាសាលាស្តីពី *«ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ»* រៀបចំឡើងដោយមានកិច្ចសហការជាមួយ ក្រសួងព័ត៌មាន។

ក្នុងនាមក.ជ.ភ.ខ. ខ្ញុំព្រះករុណា ខ្ញុំបាទ ខ្ញុំ សូមសម្តែងគារវកិច្ចគោរពស្វាគមន៍ចំពោះអង្គសិក្ខាសាលាទាំងមូលដោយបីតិសោមនស្ស និង សូមជម្រាបអង្គសិក្ខាសាលា មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានបង្កើត ***ក្រុមប្រឹក្សាជាតិភាសាខ្មែរ*** ដើម្បីអភិរក្សនិងអភិវឌ្ឍភាសាខ្មែរយើង ជាពិសេស ឱ្យរកឯកភាពក្នុងការប្រើប្រាស់ពាក្យនិងអក្ខរាវិរុទ្ធ។

**អង្គសិក្សាសាលាទាំងមូលជាទីគោរព,**

សម្តេចអគ្គមហាសេនាបតីតេជោ បណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ជាគុរុគណនៃក.ជ.ភ.ខ. តែងតែមានចំណាប់អារម្មណ៍ខ្ពស់លើការឯកភាព ក្នុងភាសាខ្មែរ ដោយសម្តេចតែងតែជំរុញគ.ជ.ភ.ខ.(ដែលបានក្លាយទៅជា ក.ជ.ភ.ខ.) ឱ្យធ្វើកិច្ចការរកឯកភាពជូនភាសាយើងនិងខំផ្សព្វ-ផ្សាយលទ្ធផលរបស់ខ្លួនឱ្យបានទូលំទូលាយ។

យើងទាំងអស់គ្នាបានដឹងហើយថា ការខ្វះឯកភាពក្នុងការប្រើប្រាស់ភាសា កើតមានរាប់សិបឆ្នាំកន្លងមកហើយ ហើយការរកការឯកភាពមិនអាចសម្រេចបានភ្លាមៗនោះទេ ហេតុនេះ ហើយទើបក.ជ.ភ.ខ. ធ្វើការងារជាជំហានៗ ដោយយកចិត្តទុកដាក់ខ្ពស់និងប្រុងប្រយ័ត្នបំផុត។ ទាក់ទងនឹងការរកឯកភាពជូនភាសាខ្មែរ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានកិត្តិយសក.ជ.ភ.ខ. មានប្រសាសន៍ ក្នុងពិធីបើកសម័យប្រជុំលើកទី១នៃក.ជ.ភ.ខ. ដូចនេះ «*ក្នុងករណីដែលមានការយល់មិនស្រប គ្នាទាំង វេយ្យាករណ៍ សំណេរ អំណាន និង បញ្ហាពាក់ព័ន្ធផ្សេងៗទៀតក្នុងការប្រើប្រាស់ភាសានិងអក្សរខ្មែរ ខ្ញុំព្រះករុណា ខ្ញុំ សូមឱ្យមានការជជែកគ្នាឱ្យបានល្អិតល្អន់ក្នុងក្របខណ្ឌក.ជ.ភ.ខ. ជាជាងធ្វើការបកស្រាយជាសាធារណៈដោយអត្តវិស័យភាព*»។ ដើម្បីសុខដុមនីយកម្ម ក្នុងការប្រើប្រាស់ភាសា ក.ជ.ភ.ខ. បានផ្សព្វផ្សាយសមិទ្ធផលរបស់ខ្លួនតាមព្រឹត្តិបត្រ តាមសន្និសីទកាសែត តាមការចុះផ្សាយក្នុងសារព័ត៌មាន តាមរយៈកិច្ចសហប្រតិបត្តិការជាមួយក្រសួងអប់រំ តាមគេហទំព័រ ជាដើម។

ខ្ញុំព្រះករុណា ខ្ញុំបាទ ខ្ញុំ សូមជម្រាបជាថ្មីម្តងទៀត ចំពោះអង្គសិក្សាសាលាទាំងមូល មេត្តាជ្រាបថា សិក្ខាសាលានេះដែលមានកិច្ចសហការជាមួយក្រសួងព័ត៌មាននេះមានបំណងផ្សព្វផ្សាយ តួនាទី ភារកិច្ច និង លទ្ធផលរបស់ក.ជ.ភ.ខ. ជូនឥស្សរជនគ្រប់មជ្ឈដ្ឋាន ជាពិសេស អ្នកសារព័ត៌មាន អ្នកសរសេរទស្សនាវដ្តី អ្នកជំឡើងអក្សរតាមកញ្ចក់ទូរទស្សន៍ តាមខារ៉ាអូខេ ពិធីករ ពិធីការិនី នៃវិទ្យុនិងទូរទស្សន៍ទាំងប៉ុន្មាន ដែលមានឥទ្ធិពលយ៉ាងធំធេងលើសាធារណជន ក្នុងការប្រើប្រាស់ភាសាខ្មែរ ទាំងខាងអក្ខរាវិរុទ្ធ ទាំងខាងការប្រើប្រាស់ និងការអានពាក្យពេចន៍ ទោះជាពាក្យខ្មែរសុទ្ធសាធក្តី ឬ ពាក្យកម្ចីក្តី។

ក.ជ.ភ.ខ.នឹងបន្តសហការជាមួយក្រសួងព័ត៌មាន ក្រសួងអប់រំ និង ក្រសួងដទៃទៀត ដើម្បីផ្សព្វផ្សាយលទ្ធផលរបស់ខ្លួនឱ្យបានទូលំទូលាយ ដើម្បីឱ្យការប្រើប្រាស់ភាសាខ្មែរមានការឯកភាពដូចអរិយភាសាក្នុងលោកដែរ។

ខ្ញុំព្រះករុណា ខ្ញុំបាទ ខ្ញុំ មានសុទិដ្ឋិនិយមយ៉ាងមុតមាំថា ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ បណ្ឌិតសភាចារ្យ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាគុរុគណនៃក.ជ.ភ.ខ. ដោយមានឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានកិត្តិយស ក.ជ.ភ.ខ. ដែលជាអាណាព្យាបាលនៃអង្គភាពនេះ ហើយ ដែលតែងតែគាំទ្រនិងណែនាំយើងខ្ញុំជានិច្ចកាលនោះ ភាសាខ្មែរនឹងរីកចម្រើនរុងរឿង ក្នុងការឯកភាពតាមសេចក្តីប៉ងប្រាថ្នារបស់យើងទាំងអស់គ្នា។

នៅទីបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំបាទ ខ្ញុំ សូមប្រគេនពរនិងជូនពរ ចំពោះ ព្រះតេជព្រះគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា សូមប្រកបនឹងសេចក្តីសុខ សេចក្តីចម្រើន មានព្រះជន្មាយុយឺនយូរជរាបរៀងទៅ។

**សូមអរព្រះគុណ និង សូមអរគុណ!**

## II.1.3- សុន្ទរកថារបស់ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន

ក្នុងឱកាសបើកសិក្ខាសាលា ស្តីពី «**ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ**»

រៀបចំដោយក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.) សហការជាមួយក្រសួងព័ត៌មាន

ថ្ងៃព្រហស្បតិ៍ ទី២៥ ខែតុលា ឆ្នាំ២០១២ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២

**ខ្ញុំព្រះករុណា ខ្ញុំ**

- សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមគោរព ៖
  - ឯកឧត្តមបណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់** ទីប្រឹក្សារាជរដ្ឋាភិបាល និង ជាប្រធាននៃក.ជ.ភ.ខ.
  - ឯកឧត្តមបណ្ឌិតសភាចារ្យ លោកជំទាវបណ្ឌិតសភាចារ្យ ឯកឧត្តមបណ្ឌិត ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាអនុប្រធាន ទីប្រឹក្សា អគ្គលេខាធិការ អគ្គលេខាធិការរង សមាជិក សមាជិកានៃក.ជ.ភ.ខ. និងសមាជិក សមាជិកានៃគណៈកម្មការបច្ចេកសព្ទនិងផ្នែកផ្សេងៗនៃអគ្គលេខាធិការដ្ឋានក.ជ.ភ.ខ.
  - ឯកឧត្តម លោកជំទាវ លោក លោកស្រីភ្ញៀវកិត្តិយស សមាជិក សមាជិកានៃអង្គសិក្ខាសាលា ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំព្រះករុណា ខ្ញុំ មានកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតដោយបានមកចូលរួម ជាអធិបតី បើកសិក្ខាសាលា ស្តីពី «**ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ**» រៀបចំដោយ ក.ជ.ភ.ខ. និង ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងព័ត៌មាន នៅសាលប្រជុំសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២ នាពេលនេះ។

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ បណ្ឌិតសភាចារ្យ **ហ៊ុន សែន** ជាប្រមុខ និង ជាគុរុគណនៃ ក.ជ.ភ.ខ. និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំព្រះករុណា ខ្ញុំ សូមសម្តែងនូវសេចក្តីកោតសរសើរដ៏ស្មោះចំពោះក.ជ.ភ.ខ.និងក្រសួង ព័ត៌មានដែលបានរៀបចំសិក្ខាសាលានេះឡើង ហើយដែលមានវាគ្មិនជាអ្នកជំនាញសំខាន់ៗ មកធ្វើបទបង្ហាញពីសីលធម៌ សិល្បៈនៃការនិយាយ និង ការប្រើប្រាស់ភាសាខ្មែរ ទាំងខាងអក្ខរាវិរុទ្ធ ទាំងខាងការអានឈ្មោះប្រទេសនិងរាជ/រដ្ឋធានី ជាដើម ជូនដល់អ្នកចូលរួមទាំងអស់ ជាពិសេស អ្នកសារព័ត៌មាន អ្នកសរសេរទស្សនាវដ្តី អ្នកដំឡើងអក្សរតាមកញ្ចក់ទូរទស្សន៍ តាមខារ៉ាអូខេ ពិធីករ ពិធីការិនីទាំងអស់ដែលអញ្ជើញចូលរួមនៅទីនេះ។

ក្រោយពីបានស្តាប់របាយការណ៍សង្ខេបរបស់ក.ជ.ភ.ខ. ថ្លែងដោយឯកឧត្តមបណ្ឌិត **សន ពៅ** អគ្គលេខាធិការនៃក.ជ.ភ.ខ. និង សុន្ទរកថាស្វាគមន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់** ប្រធានក.ជ.ភ.ខ. រួចមក ខ្ញុំព្រះករុណា ខ្ញុំ យល់ឃើញថា ភាសាខ្មែរបានរីកចម្រើន ខ្លាំងតាមលំដាប់លំដោយ រហូតដល់សម័យសម្តេចព្រះសង្ឃរាជ **ជួន ណាត**។ ក្រោយឆ្នាំ១៩៧៩ ភាសាខ្មែរមានការរីកចម្រើនកាន់តែរហ័ស ប៉ុន្តែ ការរីកចម្រើននេះបាននាំមកជាមួយនូវភាពចម្រូងចម្រាសផងដែរ គឺកង្វះឯកភាពលើអក្ខរាវិរុទ្ធនៃពាក្យមួយចំនួននិងការប្រើប្រាស់ពាក្យជាច្រើនសម្រាប់បញ្ញត្តិតែមួយ ហើយ រាជរដ្ឋាភិបាលដែលមានសម្តេចអគ្គមហាសេនាបតីតេជោ

**ហ៊ុន សែន** ជាប្រមុខ និង ដែលតែងតែយកចិត្តទុកដាក់នឹងភាសាជាតិបានបង្កើតឱ្យមានគណៈកម្មាធិការជាតិភាសាខ្មែរ(គ.ជ.ភ.ខ.) នៅឆ្នាំ២០០៧ ដែលបានក្លាយទៅជាក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.) នៅឆ្នាំ២០១១។ ឥឡូវនេះ ក.ជ.ភ.ខ.បានបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសកម្មក្នុងការស្វែងរកឯកភាពជូនភាសាខ្មែរ ទាំងក្នុងការសរសេរ ការបង្កើតពាក្យ ការខ្ចីពាក្យ និង តាមរយៈការអនុម័តពាក្យបច្ចេកទេសនានាកន្លងមកនេះ ជាពិសេសនោះ គឺការសរសេរអក្ខរាវិរុទ្ធតាមវចនានុក្រមខ្មែរ។

ការរៀបចំសិក្ខាសាលាស្ដីពី «**ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ**» នាឱកាសនេះពិតជាមានសារប្រយោជន៍យ៉ាងធំធេងក្នុងការបញ្ជ្រាបការប្រើប្រាស់ភាសាខ្មែរ ដល់ពិធីករ ពិធីការិនី អ្នកសារ-ព័ត៌មាន អ្នកសរសេរទស្សនាវដ្ដី។ល។

ជាការពិតហើយ ក្នុងភាសាជាតិសាសន៍ណាក៏ដូចក្នុងភាសាជាតិសាសន៍ណាដែរ ពាក្យថ្មីៗតែងតែត្រូវបានបង្កើតឡើង នៅពេលសង្គមមានការអភិវឌ្ឍ ហើយ ពាក្យខ្លះក៏ត្រូវស្លាប់ទៅវិញ នៅពេលដែលសង្គមឈប់ត្រូវការ។ ចំពោះសង្គមខ្មែរក៏ដូច្នេះដែរ ក្នុងពេលបច្ចុប្បន្ន សង្គមយើងកំពុងតែមានការអភិវឌ្ឍជឿនលឿនទៅមុខឥតឈប់ឈរតាមរយៈបច្ចេកវិទ្យានានា។ ការបង្កើតពាក្យថ្មី ការខ្ចីពាក្យ។ល។ ទាមទារឱ្យមានគោលការណ៍ច្បាស់លាស់ មានក្បួនខ្នាតត្រឹមត្រូវ ដើម្បីឱ្យការប្រើប្រាស់ភាសាមានឯកភាព ហើយ កិច្ចការទាំងនេះគឺជាភារកិច្ចរបស់ ក.ជ.ភ.ខ. នេះឯង។

កន្លងមក ក.ជ.ភ.ខ.បានត្រួសត្រាយផ្លូវឱ្យមានឯកភាពខាងអក្ខរាវិរុទ្ធ អំណាន និង មានគោលការណ៍បង្កើតពាក្យ តែបុគ្គលនិងស្ថាប័នមួយចំនួន ជាពិសេស ស្ថាប័នផ្សព្វផ្សាយព័ត៌មាន ដូចជា ទូរទស្សន៍ កាសែត ជាដើម នៅពុំទាន់បានអនុវត្តឱ្យបានសមស្របតាមអ្វីៗ ដែល ក.ជ.ភ.ខ. បានផ្សព្វផ្សាយនៅឡើយ។

យើងដឹងហើយថា វិស័យព័ត៌មាននិងសោតទស្សន៍បានបំពេញតួនាទីរបស់ខ្លួនក្នុងការផ្ដល់ព័ត៌មាន ផ្ដល់ការអប់រំ បណ្ដុះស្មារតី ផ្ដល់ការកម្សាន្តសប្បាយ ជូនប្រជាជននៅគ្រប់តំបន់ ទូទាំងប្រទេស ក្រោមពាក្យស្លោក «**ល្អែក លឿន ទុកចិត្តបាន នៅទីណា ពេលណាក៏បាន**»។ ដូច្នេះ ស្ថាប័នផ្សព្វផ្សាយ ដូចជា កាសែត ទស្សនាវដ្ដី ការអានតាមវិទ្យុ ទូរទស្សន៍ត្រូវតែប្រុងប្រយ័ត្នខ្ពស់ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

តាមរយៈសិក្ខាសាលានៅថ្ងៃនេះ ខ្ញុំព្រះករុណា ខ្ញុំ សង្ឃឹមថា បងប្អូនអ្នកសារព័ត៌មាន ពិធីករ ពិធីការិនី អ្នកដំឡើងអក្សរតាមទូរទស្សន៍ តាមខាវ៉ាអូខេបានយល់កាន់តែច្បាស់អំពីបញ្ហាអក្សរសាស្ត្រខ្មែរ តាមរយៈបទ-បង្ហាញរបស់វាគ្មិនយើងទាំងប៉ុន្មានក្នុងរយៈពេលមួយថ្ងៃនេះ។

ខ្ញុំព្រះករុណា ខ្ញុំ សង្ឃឹមយ៉ាងមុតមាំថា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្ដេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** ក.ជ.ភ.ខ.ដែលសម្ដេចបានបង្កើតឡើងនឹងសម្រេចបាននូវការឯកភាពសម្រាប់ភាសាខ្មែរ។

នៅទីបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំ សូមប្រគេនពរ និង សូមប្រសិទ្ធពរជ័យ ចំពោះព្រះតេជព្រះគុណ ឯកឧត្ដម លោកជំទាវ លោក លោកស្រី នាងកញ្ញា សូមជួបប្រទះតែនឹងពុទ្ធពរ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបី ឃ្លៀងឃ្លាតឡើយ។

ខ្ញុំព្រះករុណា ខ្ញុំ សូមប្រកាសបើកសិក្ខាសាលា ស្ដីពី «**ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ**» ចាប់ពីពេលនេះតទៅ។

សូមអរព្រះគុណ និង សូមអរគុណ!

## II.1.4- សុន្ទរកថារបស់ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្នុងពិធីបិទសិក្ខាសាលា ស្តីពី "ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ"

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២

- *សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ*
- *ឯកឧត្តមបណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់** ទីប្រឹក្សារាជរដ្ឋាភិបាល និងជាប្រធានក្រុមប្រឹក្សា ជាតិភាសាខ្មែរ*
- *ឯកឧត្តម លោកជំទាវ បណ្ឌិតសភាចារ្យ សាស្ត្រាចារ្យ អស់លោក លោកស្រី មន្ត្រីរាជការ ពិធីករពិធីការនី អ្នកសារព័ត៌មាន និងក្មួយៗសិស្សនិស្សិតទាំងអស់ជាទីមេត្រី*

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំ មានសេចក្តីសោមនស្សរីករាយចូលរួមជាមួយ ឯកឧត្តម លោកជំទាវ បណ្ឌិតសភាចារ្យ សាស្ត្រាចារ្យ អស់លោក លោកស្រី មន្ត្រីរាជការ ពិធីករ ពិធីការនី អ្នកសារព័ត៌មាន និង ក្មួយៗសិស្សនិស្សិតទាំងអស់ ក្នុងពិធីបិទសិក្ខាសាលាស្តីពី "**ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ**" ដ៏មានសារៈសំខាន់នេះ។

ក្នុងនាមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាគរុគណនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ខ្ញុំព្រះករុណាខ្ញុំសូមយកឱកាសនេះ សម្តែងនូវការកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលបានសហការយ៉ាងជិតស្និទ្ធជាមួយថ្នាក់ដឹកនាំក្រសួងព័ត៌មានរៀបចំសិក្ខាសាលានេះប្រព្រឹត្តទៅដោយរលូននិងទទួលបានជោគជ័យ។

ជាមួយគ្នានេះដែរ ខ្ញុំព្រះករុណាខ្ញុំក៏សូមថ្លែងអំណរគុណចំពោះវាគ្មិនទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងសិក្ខាសាលានេះ ដើម្បីចែករំលែកចំណេះដឹងនិងបទពិសោធអំពីការប្រើប្រាស់ភាសានិងអក្សរខ្មែរ ទាំងអក្ខរាវិរុទ្ធ ការអានពាក្យនិងការបង្កើតពាក្យដល់សិក្ខាកាមទាំងអស់ សំដៅរួមចំណែកដល់ការអភិរក្ស និងការអភិវឌ្ឍភាសាជាតិប្រកបដោយចីរភាពស្របតាមទស្សនទាន "**អភិរក្សដើម្បីអភិវឌ្ឍ អភិវឌ្ឍដើម្បីអភិរក្ស**"។

ការជួបជុំគ្នានៅថ្ងៃនេះ ជាសក្ខីភាពបញ្ជាក់នូវការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការថែរក្សាការពារអត្តសញ្ញាណជាតិខ្មែរ តាមរយៈការលើកកម្ពស់ការប្រើប្រាស់ភាសានិងអក្សរខ្មែរឱ្យកាន់តែត្រឹមត្រូវ និង មានការឯកភាពគ្នាថែមទៀត។

ព្រឹត្តិការណ៍នេះ ក៏ឆ្លុះបញ្ចាំងឱ្យឃើញផងដែរអំពីការរីកចម្រើនមួយជំហានទៀតរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលមានភារកិច្ចដ៏សំខាន់ក្នុងការត្រួតពិនិត្យរាល់ការប្រើប្រាស់ ការចងក្រងនិងការផ្សព្វផ្សាយភាសានិងអក្សរខ្មែរក្នុងគ្រប់រូបភាព សំដៅជំរុញឱ្យមានការឯកភាពគ្នាលើអក្ខរាវិរុទ្ធការអានពាក្យ ការប្រើពាក្យកម្ចីនិងការបង្កើត

ពាក្យ ក៏ដូចជាការកំណត់និយមន័យនៃពាក្យឱ្យបានត្រឹមត្រូវ និង ដែលអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងសង្គមជាតិយើង។

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងអង្គសិក្ខាសាលាទាំងមូល!*

ដូចដែលយើងទាំងអស់គ្នាបានដឹងស្រាប់ហើយថា ភាសាខ្មែរក៏ដូចភាសាដទៃទៀតដែរ សុទ្ធតែមានប្រភព កំណាកំណើត ដំណើរវិវត្តន៍ និងការរីកចម្រើនរបស់ខ្លួន ដែលអាស្រ័យដោយផ្ទាល់ទៅនឹងរបត់ប្រវត្តិសាស្ត្រ ក៏ដូចជាបម្រែបម្រួលស្ថានភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ជាពិសេសឥទ្ធិពល នៃការរីកលូតលាស់ផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ ក្នុងយុគសម័យសកលភាវូបនីយកម្មនេះ។ ភាសាខ្មែរគឺជាភាសាដ៏ចំណាស់មួយ ហើយក៏ជាភាសាដែលមានលក្ខណៈពិសេសដាច់ដោយឡែកពីភាសាដទៃ នៅត្រង់ថា ភាសាខ្មែរមានចំនួនតួព្យញ្ជនៈ និងស្រៈច្រើនជាងគេបង្អស់នៅលើសកលលោក ហើយក៏មានទម្រង់តួអក្សរ ខុសប្លែកពីភាសាដទៃៗទៀត។ យើងទាំងអស់គ្នាពិតជាមានមោទនភាពណាស់ចំពោះភាសាខ្មែរ ហើយ យើងក៏ត្រូវរួបរួមនិងសហការគ្នា ដើម្បីថែរក្សាមរតកវប្បធម៌ និងលើកកម្ពស់តម្លៃភាសាជាតិយើង ឱ្យកាន់តែមានភាពប្រសើរឡើង។ ជាក់ស្តែងភាសាខ្មែរមានភាពសម្បូណ៌បែបនៃសំនួនវោហាស័ព្ទ និងពាក្យពេចន៍ដែលមានន័យដូចគ្នា ប៉ុន្តែទាមទារឱ្យយើងចេះប្រើចំគោលដៅ ទើបមានភាពត្រឹមត្រូវស្របតាម តម្លៃវប្បធម៌ខ្មែរ។ ឧទាហរណ៍ គ្រាន់តែពាក្យ "ហូប" មានពាក្យជាច្រើនដែលមានន័យដូច ដូច្នេះយើងត្រូវ ដឹងថាពាក្យណាគួរប្រើទៅកាន់ព្រះមហាក្សត្រ ព្រះសង្ឃ មនុស្សចាស់ អ្នកមានវ័យឬឋានៈស្មើគ្នា អ្នក មានវ័យក្មេងជាង និងពាក្យណាគួរប្រើជាមួយកុមារតូចៗ ហើយ ក៏មានពាក្យមួយចំនួនទៀតសម្រាប់ប្រើក្នុងន័យអសុរោះ ឬមាក់ងាយផងដែរ។

ភាសាអាចត្រូវបានគេយកទៅប្រើប្រាស់ជាមធ្យោបាយសម្រាប់ការប្រាស្រ័យទាក់ទងគ្នាក្នុងគ្រប់រូប-ភាព។ យ៉ាងណាមិញ ការប្រើប្រាស់ភាសាតាមប្រព័ន្ធផ្សព្វផ្សាយអាចក្លាយជាអាវុធមុខពីរ ប្រសិនបើការប្រើប្រាស់នោះពុំមានលក្ខណៈសមស្រប ឬប្រាសចាកពីការពិត។ ការប្រើប្រាស់ភាសាតាម ប្រព័ន្ធផ្សព្វផ្សាយអាចជះឥទ្ធិពលមិនល្អដល់ផ្នត់គំនិត ចិត្តសាស្ត្រ ស្មារតីសង្គម និងតម្លៃវប្បធម៌ជាតិ ក៏ដូចជាអាចបណ្តាលឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បញ្ហាសណ្តាប់ធ្នាប់សាធារណៈសន្តិសុខ និងសុវត្ថិភាពសង្គម។ ផ្ទុយទៅវិញ ប្រសិនបើការប្រើប្រាស់ពាក្យសម្តីប្រកបដោយសច្ចភាព និងវិជ្ជាជីវៈខ្ពស់ អាចរួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹងស្មារតីជំនឿទុកចិត្ត និងការលើកកម្ពស់មោទនភាពជាតិ។ ការប្រើប្រាស់ភាសាតាមប្រព័ន្ធផ្សព្វផ្សាយមានតួនាទីយ៉ាងសំខាន់ក្នុងការអប់រំបណ្តុះបណ្តាល និង បង្កើនសមត្ថភាពយល់ដឹងឱ្យកាន់តែទូលំទូលាយថែមទៀតដល់ប្រជាពលរដ្ឋ។ ក្នុងន័យនេះ យើងត្រូវបន្តយកចិត្តទុកដាក់ខ្ពស់ និង ប្រុងប្រយ័ត្នជាប់ជានិច្ចចំពោះការប្រើប្រាស់ភាសាឱ្យបានត្រឹមត្រូវ។ ដើម្បីទទួលបាននូវការកោតសរសើរ និង ការវាយតម្លៃខ្ពស់ពីសំណាក់មហាជន ចូរក្មួយៗពិធីករ ពិធីការនី និង អ្នកធ្វើបទអត្ថាធិប្បាយតាមប្រព័ន្ធផ្សព្វផ្សាយទាំងអស់បន្តខិតខំរៀនសូត្រនិងហ្វឹកហាត់ការប្រើប្រាស់ភាសាខ្មែរឱ្យកាន់តែប្រសើរឡើងថែមទៀត ជាពិសេស ព្យាយាមប្រើប្រាស់សំនួនវោហាស័ព្ទរបស់ខ្លួនឱ្យមានភាពស៊ីសង្វាក់គ្នាទៅនឹងបរិបទ និង សាច់រឿងដែលត្រូវបរិយាយ។

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងអង្គសិក្ខាសាលាទាំងមូល!*

របាយការណ៍របស់លោកជំទាវបណ្ឌិតសភាចារ្យ **ខូត ធីតា** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងជាអនុ-ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរបានឱ្យដឹងថាសិក្ខាសាលា ស្តីពី "**ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ**" ដែលបានប្រព្រឹត្តទៅពេញមួយថ្ងៃនេះ មានការចូលរួមពន្យល់បកស្រាយនិងពិភាក្សា ផ្លាស់ប្តូរយោបល់យ៉ាង

ផុលផុសពីសំណាក់វាគ្មិននិងសិក្ខាកាមទាំងអស់ សំដៅរួមចំណែកដល់ការពង្រឹង និងលើកកម្ពស់តម្លៃវប្បធម៌និងអត្តសញ្ញាណជាតិខ្មែរ។ សិក្ខាសាលាបានផ្តោតការយកចិត្តទុកដាក់ពន្យល់ ណែនាំដល់សិស្ស និស្សិត បញ្ញវន្ត អ្នកនិពន្ធ អ្នកសារព័ត៌មាន អ្នកអានព័ត៌មាន និងអ្នកជំទើងអក្សរតាមកញ្ចក់ទូរទស្សន៍និងប្រព័ន្ធផ្សព្វផ្សាយនានាឱ្យចេះប្រើភាសានិងអក្សរខ្មែរបានត្រឹមត្រូវ។ ជាងនេះទៅទៀត អង្គសិក្ខាសាលាក៏បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការពង្រឹង និងការលើកកម្ពស់តម្លៃសិល្បៈនិងសីលធម៌នៃការនិយាយរបស់ក្មួយៗពិធីករ ពិធី-ការនី ក៏ដូចជាអ្នកធ្វើបទអត្ថាធិប្បាយតាមវិទ្យុនិងទូរទស្សន៍នានាផងដែរ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំព្រះករុណាខ្ញុំ សូមយកឱកាសនេះ អំពាវនាវដល់ក្រសួង ស្ថាប័ន រដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ និងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ សូមបន្តពង្រឹងកិច្ចសហការជាមួយនឹងក្រុមប្រឹក្សាជាតិភាសាខ្មែរឱ្យកាន់តែទូលំទូលាយថែមទៀត ដើម្បីឱ្យការប្រើភាសានិងអក្សរខ្មែរ ប្រកបដោយភាពរលូន និងមានការឯកភាពគ្នាជាចរន្តតែមួយ។ ជាមួយគ្នានេះដែរ សូមបងប្អូនជនរួមជាតិទាំងអស់ដែលមានអាជីពជាគ្រូបង្រៀន អ្នកនិពន្ធ អ្នកសារព័ត៌មាន អ្នកជំទើងអក្សរតាមប្រព័ន្ធផ្សព្វផ្សាយ ពិធីករ ពិធីការនី និង អ្នកធ្វើបទអត្ថាធិប្បាយតាមវិទ្យុនិងទូរទស្សន៍បន្តយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នខ្ពស់ចំពោះការប្រើប្រាស់ភាសានិងអក្សរខ្មែរ នៅតាមប្រព័ន្ធផ្សព្វផ្សាយក្នុងគ្រប់រូបភាព សំដៅកាត់បន្ថយកំហុសដោយអចេតនាដើម្បីជំរុញឱ្យមានការឯកភាពគ្នាស្របតាមការណែនាំរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ ទាំងផ្នែកអក្ខរាវិរុទ្ធ ការអាននិងគោលការណ៍បង្កើតពាក្យក៏ដូចជាការប្រើពាក្យកម្ចីពីភាសាបរទេស តួយ៉ាងដូចជា ការហៅឈ្មោះប្រទេសនិងឈ្មោះទីក្រុងនានាលើពិភព-លោក ជាដើម។

ការប្រើប្រាស់ភាសា ពាក្យពេចន៍ និង អក្ខរាវិរុទ្ធបានត្រឹមត្រូវពិតជារួមចំណែកយ៉ាងសំខាន់ដល់ការថែរក្សាវប្បធម៌និងពង្រឹងអត្តសញ្ញាណជាតិយើង ពីព្រោះថា ការប្រើពាក្យពេចន៍ឬអក្ខរាវិរុទ្ធខុសនៅតាមប្រព័ន្ធផ្សព្វផ្សាយនឹងបណ្តាលឱ្យមហាជនមានភាពស្រពិចស្រពិល ភាន់ច្រឡំ រកការពិតនិងភាពត្រឹមត្រូវមិនឃើញ ជាពិសេស កំហុសដែលអាចជៀសបានទាំងនេះនឹងដក់ជាប់ក្នុងអារម្មណ៍និងស្មារតីរបស់កុមារតូចៗចាប់តាំងពីពេលដែលពួកគេចូលសិក្សាដំបូង ហើយ បទពិសោធនេះនឹងធ្វើឱ្យពួកគេនៅតែចងចាំជានិច្ច។ អាស្រ័យហេតុនេះ ចូរក្មួយៗសិស្ស និស្សិត បញ្ញវន្តខ្មែរគ្រប់រូបនិងធុរជនបន្តចូលរួមសហការឱ្យបានល្អជាមួយក្រុមប្រឹក្សាជាតិភាសាខ្មែរ ដោយតាមដានរាល់ការណែនាំនិងការផ្សព្វផ្សាយអំពីការប្រើប្រាស់ភាសានិងអក្សរខ្មែរឱ្យបានជាប់ជាប្រចាំ ហើយត្រូវជួយផ្តល់យោបល់កែលម្អនូវរាល់ចំណុចខ្វះខាតនានា ដើម្បីឱ្យមានការឯកភាពគ្នាលើការប្រើប្រាស់ភាសាជាតិយើង។

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងអង្គសិក្ខាសាលាទាំងមូល!*

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណា ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រុមប្រឹក្សាជាតិភាសាខ្មែរ រាជបណ្ឌិត្យសភាកម្ពុជា និងក្រសួងព័ត៌មាន ដែលបានផ្តួចផ្តើមគំនិតរៀបចំសិក្ខាសាលាដ៏មានសារៈសំខាន់នេះឡើង ហើយក៏សូមថ្លែងអំណរគុណចំពោះវាគ្មិននិងសិក្ខាកាមទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មជំរុញឱ្យសិក្ខាសាលានេះប្រព្រឹត្តិទៅដោយជោគជ័យ។

ខ្ញុំព្រះករុណា ខ្ញុំ មានជំនឿយ៉ាងមុតមាំថា ក្រសួងព័ត៌មាននឹងបន្តសហការជាមួយក្រុមប្រឹក្សាជាតិភាសាខ្មែរឱ្យកាន់តែទូលំទូលាយថែមទៀត ដើម្បីអប់រំនិងផ្សព្វផ្សាយនូវរបកគំហើញនិងគោលការណ៍ណែនាំឱ្យបាន

ជ្រាបដល់មហាជនគ្រប់ស្រទាប់។ ជាមួយគ្នានេះដែរ ខ្ញុំព្រះករុណា ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីនិងសិក្ខាកាមទាំងអស់នឹងបន្តចូលរួមយ៉ាងសស្រាក់សស្រាំ គាំទ្រដល់សកម្មភាពរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ តាមរយៈការពាំនាំយកចំណេះដឹងនិងបទពិសោធ ដែលទទួលបានពីសិក្ខាសាលានេះទៅផ្សព្វផ្សាយបន្ត នៅតាមអង្គភាពរៀងៗខ្លួន ដើម្បីឱ្យយល់កាន់តែច្បាស់អំពីតម្លៃភាសាជាតិយើង។

ជាទីបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំ សូមប្រគេនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គទទួលបានពុទ្ធពរទាំងបួនប្រការ អាយុ វណ្ណៈ សុខៈ ពលៈ និងសូមជូនពរឯកឧត្តម លោកជំទាវ បណ្ឌិតសភាចារ្យ សាស្ត្រាចារ្យ អស់លោក លោកស្រី មន្ត្រីរាជការ ពិធីករ ពិធីការនី អ្នកសារព័ត៌មាន និងក្មួយៗសិស្សនិស្សិតទាំងអស់ សូមមានសុខភាពល្អ ទទួលបានជោគជ័យគ្រប់ភារកិច្ច និងមានសុភមង្គលក្នុងក្រុមគ្រួសារ។

ខ្ញុំព្រះករុណា ខ្ញុំ សូមប្រកាសបិទសិក្ខាសាលាស្ដីពី **"ការប្រើប្រាស់ភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយ"** នាពេលនេះ។

**សូមអរព្រះគុណនិងសូមអរគុណ !**

## II.2- បច្ចេកសព្ទស្នើដោយគណៈកម្មការមួយចំនួន

### II.2.1- អក្ខរាវិរុទ្ធនិងនិយមន័យ

#### II.2.1.1- បច្ចេកសព្ទនៃគណៈកម្មការវិទ្យាសាស្ត្រនយោបាយនិងការទូត

| | |
|---|---|
| **១- នយោបាយការ៉ុតនិងដំបង**<br>អ. carrot and sstick policy<br>បារ. politique de la carotte et du baton | នយោបាយប្រើប្រាស់ការទូតផងនិងកម្លាំងផងក្នុងពេលតែមួយ តាមគ្រប់រូបភាពដែលអាចធ្វើទៅបាន រួមមាន ការចរចា ការផ្តល់ជំនួយ ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ការផ្តាច់ទំនាក់ទំនងការទូត និង ការប្រើកម្លាំងយោធា ជាដើម។<br>ឧ. នយោបាយការ៉ុតនិងដំបងរបស់អង្គការសហប្រជាជាតិចំពោះប្រទេសអ៊ីរ៉ង់អំពីបញ្ហាអាវុធនុយក្លេអ៊ែរ។ |
| **២- នយោបាយចម្រុះពណ៌**<br>អ. multi-colored politics<br>បារ. politique multicolore | នយោបាយដែលទទួលយកមនោគមវិជ្ជានយោបាយគ្រប់និន្នាការ ក្នុងទិសដៅបង្ហាញពិភពលោកថា ខ្លួនមិនរើសអើងនិន្នាការនយោបាយ។<br>ឧ. ក្រោយពីការបង្កើតបក្សសម្ព័ន្ធសេអាតូ នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៥៤ ប្រទេសកម្ពុជាបានប្រកាសជាប្រទេសអព្យាក្រឹត្យ មិនចូលបក្សសម្ព័ន្ធ ក្រោមនយោបាយនេះ ប្រទេសកម្ពុជាបានប្រើប្រាស់នយោបាយចម្រុះពណ៌ ដើម្បីអាចទទួលបានជំនួយពីចិន រុស្ស៊ី អាម៉េរិក ...។ |
| **៣- ជីកស្មៅជីកទាំងឫស**<br>អ. To get to the root of the problem<br>បារ. combattre le mal à la racine | ពាក្យប្រើប្រាស់ជាសាកលក្នុងរបបផ្តាច់ការ។ ដោយឡែកក្នុងសង្គមខ្មែរ ពាក្យនេះបានយកមកប្រើពេញនិយមនិងអនុវត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)។ តាមន័យត្រង់ ដើម្បីកុំឱ្យស្មៅដុះសាជាថ្មី គេត្រូវជីកយកទាំងឫស។ តាមន័យនយោ-បាយ បើគេយល់ថា ក្រុមណាឬបុគ្គលណាមួយដែលជាគូប្រជែងឬគូប្រឆាំងមិនពេញចិត្តទៅនឹងមនោគមវិជ្ជារបស់គេ ត្រូវគេកម្ទេចចោលទាំងអស់ ដើម្បីកុំឱ្យប្រឆាំងតបតមកវិញ។<br>ឧ. នៅឆ្នាំ១៩១៧ បដិវត្តន៍រុស្ស៊ីបានអនុវត្តនយោបាយជីកស្មៅជីកទាំងឫសដែលបានសម្លាប់រាជវង្សស្តេចត្សារទាំងពូជ។ |
| **៤- ស្វាស៊ីបាយលាបមាត់ពពែ** | ល្បិចកលរបស់អ្នកនយោបាយឬក្រុមណាមួយដែលបំភាន់ការពិត ដោយយកកំហុសរបស់ខ្លួនទៅទម្លាក់ដាក់ឱ្យអ្នកដទៃ ដែលមិនបានប្រព្រឹត្តកំហុសនោះ។ |
| **៥- នយោបាយច័ក្កច័ន** | ប្រភេទនយោបាយមួយដែលគេរៀបចំឡើងដោយមានពហុមនោគមវិជ្ជា ដើម្បីសម្រេចគោលដៅណាមួយរបស់អ្នកនយោបាយ ដូចជា ការបង្កើតរដ្ឋាភិបាលឬចលនានយោ-បាយចម្រុះពណ៌។<br>ឧ. ក្រោយពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៩ ក្រុមអ្នកតស៊ូត្រីភាគីដែលមាននិន្នាការនយោបាយច័ក្កច័នបានរួបរួមគ្នាប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ |
| **៦- អ្នកនយោបាយផ្កាយរីកគ្រប់រដូវ** | អ្នកនយោបាយណា ដែលយកទេពកោសល្យ សមត្ថភាព បច្ចេកទេស យុទ្ធវិធី យុទ្ធ-សាស្ត្រ និង ទស្សនវិស័យ ដើម្បីសម្រេចបានជ័យជម្នះគ្រប់សម័យកាល។ |

| | |
|---|---|
| **៧- អ្នកនយោបាយព្រះអាទិត្យ**<br>**អ.** sun politician | អ្នកនយោបាយទាំងឡាយណាដែលគ្រប់គ្រងអំណាច ហើយ នៅក្នុងកាលៈទេសៈណាមួយ ដែលបានបាត់បង់អំណាចនោះទៅ ក្នុងរយៈពេលក្រោយមកទៀត ក៏បានចាប់យកអំណាចមកវិញ។ អ្នកនយោបាយប្រភេទនេះ គេហៅថា អ្នកនយោបាយព្រះអាទិត្យ។ |
| **៨- អ្នកនយោបាយអស្តង្គត** | ឥស្សរជននយោបាយទាំងឡាយណាដែលទទួលជោគជ័យក្នុងនយោបាយ ហើយក៏បរាជ័យទៅវិញ។<br>ឧ. របបកម្ពុជាប្រជាធិបតេយ្យដឹកនាំដោយ ប៉ុល ពត បានដួលរលំ នៅថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ហើយ ប៉ុល ពត ក៏បញ្ចប់ជីវិតនយោបាយរបស់ខ្លួន។ |
| **៩- នយោបាយអត្តឃាត**<br>**អ.** suicidal politics<br>**បារ.** politique suicidaire | បុគ្គលឬក្រុមបក្សនយោបាយណាមួយដែលគេបង្កើតឡើងគ្មានមូលដ្ឋានរឹងមាំ ហើយត្រូវទទួលបរាជ័យនិងបាត់ឈ្មោះពីក្នុងបញ្ជីគណបក្សនយោបាយទៅវិញ ក្រោយពីមានការប្រកួតប្រជែង។ |
| **១០- ពិភពលោកមួយភូមិមួយ**<br>**អ.** one world one village<br>**បារ.** un monde, un village | ពាក្យពេញនិយម ដែលគេប្រើប្រាស់ក្នុងសម័យសាកលភាវូបនីយកម្ម សំដៅទៅលើទំនាក់ទំនងរបស់មនុស្សកាន់តែមានភាពងាយស្រួល និង ឆាប់រហ័ស ឯឥទ្ធិពលនិងផលប៉ះពាល់ ក៏មានភាពរាលដាលយ៉ាងឆាប់រហ័សពាសពេញពិភពលោកដែរ ក្នុងវិស័យទាំងឡាយ ដូចជា នយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន ព័ត៌មាន បច្ចេកវិទ្យា ការអប់រំ ជាដើម។<br>ឧ. វិបត្តិសេដ្ឋកិច្ចនៅចុងឆ្នាំ២០០៨ បានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចទូទាំងពិភពលោក។ |
| **១១- ជំងឺតួឯក**<br>**អ.** egotism<br>**បារ.** égotisme ( m. ) | ទស្សនៈអត្មានិយម បុគ្គលនិយម ដែលប្រកាន់ថា មានតែខ្លួនទេដែលល្អជាង់គេ លើសគេ ផុតគេ ជាអ្នកសំខាន់ឬអស្ចារ្យជាងគេ ប្រសិនបើពុំមានវត្តមានរបស់ខ្លួនទេ ពុំមាននរណាផ្សេងអាចជំនួសខ្លួនបានឡើយ។ |
| **១២- យុទ្ធសាស្ត្រដុតឱ្យខ្លោចរោចឱ្យឆៅ** | យុទ្ធសាស្ត្ររបស់អ្នកនយោបាយ ដែលរុញឬបង្អាក់បញ្ហាណាមួយឱ្យបរាជ័យ ហើយបង្ហាញបញ្ហានោះឱ្យសាធារណជនមើលឃើញ ដើម្បីឆក់យកអំណាចឬយកប្រៀបខាងនយោបាយ។ ម្យ៉ាងវិញទៀត ដើម្បីចាប់កំហុសឬទម្លាក់នរណាម្នាក់ចេញពីតំណែង គេក៏ប្រើវិធីនេះផងដែរ។ |
| **១៣- ចៅហ្វាយឡើងបុណ្យខុនឡើងសក្តិ** | ការឡើងបុណ្យឬឥទ្ធិពលតាមរយៈចៅហ្វាយនាយរបស់ខ្លួន។ ជាធម្មតា កាលណាចៅហ្វាយនាយឡើងបុណ្យ ខុនដែលជាមន្ត្រីធ្វើការក្រោមឱវាទតែងតែឡើងសក្តិតាមឋានៈខ្ពស់ៗឬយ៉ាងហោចណាស់ក៏បានទទួលឥទ្ធិពលពីមេខ្លះៗដែរ។ |
| **១៤- យុទ្ធសាស្ត្រព្រួញមួយបាញ់បានសត្វពីរ**<br>**អ.** kill two birds with one stone<br>**បារ.** faire d' une pierre deux coups | ភាពប៉ិនប្រសប់របស់អ្នកនយោបាយ ក្នុងការដោះស្រាយបញ្ហាអ្វីមួយ ដោយប្រើមធ្យោបាយតែមួយ ហើយ អាចដោះស្រាយបញ្ហាពីរឬច្រើន ឬ ផ្តល់គុប្រជែងពីរឬច្រើនបាន។ |

| | |
|---|---|
| **១៥- ការត្រួតពិនិត្យព័ត៌មាន**<br>**អ.** information control<br>**បារ.** contrôle des informations | ការអង្កេតនិងតាមដានខ្លឹមសារព័ត៌មានដែលប្រព័ន្ធផ្សព្វផ្សាយទាំងអស់របស់រដ្ឋនិងឯកជន ដោយផ្អែកច្បាប់និងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានរបស់ទេសនីមួយៗ។<br>ឱ. នាពេលបច្ចុប្បន្ននេះ ប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសមួយចំនួនត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យព័ត៌មានពីរដ្ឋយ៉ាងតឹងរ៉ឹង។ |
| **១៦- វិទ្យាសាស្ត្រនយោបាយ**<br>**អ.** political science<br>**បារ.** science politique | វិទ្យាសាស្ត្រសង្គមមួយបែបដែលសិក្សាជាប្រព័ន្ធអំពីជីវិតសង្គមនយោបាយនិងអំពីគ្រប់បាតុភូតនយោបាយទាំងអស់ដែលកើតមានឡើង ពោលគឺទំនាក់ទំនងរវាងស្ថាប័ននយោបាយនិងអង្គការនយោបាយ ដែលក្នុងនោះ មានរដ្ឋាភិបាល គណបក្សនយោ-បាយ អង្គការសង្គមនានា។<br>ឱ. នៅប្រទេសរុស្ស៊ីវិទ្យាសាស្ត្រនយោបាយបានក្លាយជាវិទ្យាសាស្ត្រឯករាជ្យមួយនៅចុងសតវត្សរ៍ទី២០។ |
| **១៧- អ្នកនយោបាយ**<br>**អ.** politician<br>**បារ.** politicien | អ្នកធ្វើការទាក់ទងនឹងការងារនយោបាយឬជាអ្នកដោះស្រាយបញ្ហានយោបាយគ្រប់ប្រភេទ ដើម្បីបម្រើផលប្រយោជន៍សង្គមជាតិ។<br>ឱ. សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករដ្ឋាភិបាលជាអ្នកនយោបាយ។ |
| **១៨- អ្នកធ្វើនយោបាយ**<br>**អ.** political player | ពលរដ្ឋទូទៅដែលមានគំនិត ទស្សនៈ ចក្ខុវិស័យ មនោគមវិជ្ជានយោបាយ ហើយ ធ្វើសកម្មភាពនយោបាយ យកនយោបាយជាអាជីព ក្នុងបំណងសម្រេចប្រយោជន៍អ្វីមួយរបស់ខ្លួន។<br>ឱ. សកម្មជនគណបក្សនយោបាយទាំងអស់ជាអ្នកធ្វើនយោបាយ។ |
| **១៩- អ្នកគាំទ្រនយោបាយ**<br>**អ.** political supporter<br>**បារ.** supporteur politique | ពលរដ្ឋទាំងឡាយណាដែលចូលរួមគាំទ្រ ដោយផ្ទាល់ក្ដី ដោយប្រយោលក្ដី ទាំងផ្នែកស្មារតីនិងសម្ភារៈ ចំពោះគណបក្សនយោបាយណាមួយដែល ខ្លួនពេញចិត្ត។<br>ឱ. លទ្ធផលនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ចំនួនអសនៈដែល ទទួលបានបញ្ជាក់ពីសំឡេងនៃអ្នកគាំទ្រនយោបាយ។ |
| **២០- រដ្ឋាភិបាល**<br>**អ.** government<br>**បារ.** gouvernement ( m. ) | អង្គការចាត់តាំងរបស់ប្រជាជននៅក្នុងរដ្ឋមួយ ដែលមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់និងគ្រប់គ្រងកិច្ចការនានារបស់រដ្ឋ។ រដ្ឋាភិបាល គឺជាផ្នែកមួយរបស់រដ្ឋ គ្មានលក្ខណៈអចិន្ត្រៃយ៍និងអាចមានការផ្លាស់ប្ដូរតាមរយៈបដិវត្តន៍ រដ្ឋប្រហារ ការបោះឆ្នោតនិង វិធីផ្សេងៗខាងផ្លូវច្បាប់។<br>ឱ. ចលនាតស៊ូរបស់ខ្មែរក្រហមផ្ដួលរំលំរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ប្រកបដោយជោគជ័យនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ |
| **២១- អធិបតេយ្យភាព**<br>**អ.** sovereignty<br>**បារ.** souveraineté ( f. ) | អំណាចខ្ពស់បំផុតនៅក្នុងរដ្ឋ ដែលមានសិទ្ធិគ្រប់គ្រង កំណត់ និង ត្រួតពិនិត្យកិច្ចការនានារបស់រដ្ឋ ដោយគ្មានការជ្រៀតជ្រែកពីអ្នកដទៃ។ អធិបតេយ្យភាពនៃរដ្ឋមួយមានទិដ្ឋភាពពីរ គឺទិដ្ឋភាពខាងក្នុងនិងទិដ្ឋភាពខាងក្រៅ។ ទិដ្ឋភាពខាងក្នុងគឺរដ្ឋមានអំណាចពេញលេញក្នុងការគ្រប់គ្រងប្រជាជនទាំងអស់នៅក្នុងរដ្ឋ។ ទិដ្ឋភាពខាងក្រៅគឺរដ្ឋមានឯករាជ្យភាពឬមិនចំណុះការគ្រប់គ្រងរបស់បរទេសនិងទាមទារឱ្យមានការទទួលស្គាល់ពីរដ្ឋដទៃ។<br>ឱ. ក្រោយពីបានទទួលឯករាជ្យពីបារាំងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ប្រទេសកម្ពុជាមានអធិបតេយ្យភាពពេញលេញ។ |

| | |
|---|---|
| **២២- រដ្ឋធម្មនុញ្ញ**<br>**អ.** constitution<br>**បារ.** constitution ( f. ) | ច្បាប់កំពូលរបស់រដ្ឋ ដែលត្រូវបានប្រើជាមូលដ្ឋានសម្រាប់បង្កើតច្បាប់ផ្សេងៗ ដើម្បីគ្រប់-គ្រងរដ្ឋ។ ច្បាប់នេះកំណត់អំពីគោលការណ៍រួមនៃការបែងចែកអំណាចនៅក្នុងការគ្រប់-គ្រងរដ្ឋ ដំណើរប្រព្រឹត្តទៅនៃស្ថាប័នកំពូលរបស់រដ្ឋនិងសិទ្ធិនិងការទទួលខុសត្រូវជាមូល-ដ្ឋានរបស់ពលរដ្ឋគ្រប់រូប។<br>ឧ. រដ្ឋធម្មនុញ្ញដំបូងនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឱ្យប្រើជា ផ្លូវការដោយព្រះបាទនរោត្តមសីហនុនៅឆ្នាំ១៩៤៧ បន្ទាប់ពីសភាជាតិបានអនុម័តរួចមក។ |
| **២៣- អ្នកការទូត**<br>**អ.** diplomat<br>**បារ.** diplomate ( m. ) | អ្នកដែលធ្វើការងារទាក់ទងទៅនឹងការទូត ហើយ ដែលត្រូវបានបញ្ជូនពីប្រទេសឬស្ថាប័នសាមីណាមួយ ដើម្បីទៅបំពេញការងារការទូតនៅបរទេស។<br>ឧ. លោក **យ៉ាស៊ូស៊ី អាហ្កាស៊ី** ជាអ្នកការទូតតំណាងអង្គការសហប្រជាជាតិ ដែលមានបេសកកម្មសម្របសម្រួលការងារក្នុងការរៀបចំការបោះឆ្នោតសាកលតាមបែបប្រជា-ធិបតេយ្យនៅកម្ពុជា ចាប់ពីឆ្នាំ១៩៩១ ដល់ ១៩៩៣។<br>ឧ. លោកស្រី **ម៉ាដឺលែន អលប្រាយ** អតីតរដ្ឋមន្ត្រីការបរទេសសហរដ្ឋ អាម៉េរិក គឺជាអ្នកការទូតដ៏ល្បីល្បាញរបស់សហរដ្ឋអាម៉េរិកដែលទទួលបេសកកម្មក្នុងការបញ្ចុះ-បញ្ចូលសមាជិកអង្គការណាតូ ( NATO ) និង បណ្ដាប្រទេសដែលពាក់ព័ន្ធឱ្យចូលរួមធ្វើសង្គ្រាមនៅប្រទេសយូហ្គោស្លាវី នៅឆ្នាំ១៩៩៧។ |
| **២៤- អគ្គរដ្ឋទូត / អគ្គរាជទូត**<br>**( ឯកអគ្គរដ្ឋទូត/ឯកអគ្គរាជទូត )**<br>**អ.** ambassador<br>**បារ.** ambassadeur ( m. ) | អ្នកតំណាងខាងការទូតរបស់រដ្ឋមួយនៅបរទេស ដែលមានតំណែង ( ឋានន្តរសក្តិ ) ខ្ពស់ជាងគេបំផុត។<br>ឧ. ពីឆ្នាំ២០០៥ ដល់ ២០០៨ ឯកឧត្ដម ជូសេព ម៉ូសូមីលី ( JOSEPH A. MUSSOMELI ) ជាឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិកប្រចាំព្រះរាជាណាចក្រកម្ពុជា ។ |
| **២៥- អភ័យឯកសិទ្ធិដាច់ខាតការទូត**<br>**អ.** absolute diplomatic immunity<br>**បារ.** immunité diplomatique absolue | អភ័យឯកសិទ្ធិពុំមែនត្រឹមតែមិនអនុញ្ញាតឱ្យមានការកាត់ទោសឬការអនុវត្តសាលក្រមទៅលើអ្នកការទូតប៉ុណ្ណោះទេ ថែមទាំងបានហាមឃាត់ការចាប់ផ្ដើមនូវនីតិវិធីព្រហ្ម-ទណ្ឌចំពោះអ្នកការទូតផងដែរ ដូចជា ការចេញដីកាកោះអញ្ជើញអ្នកការទូតឱ្យមកចូលរួមការជំនុំជម្រះក្ដីឬកោះអញ្ជើញឱ្យមកធ្វើជាកសិណសាក្សី ជាដើម។ |
| **២៦- ស្ថានទូត**<br>អ. embassy<br>បារ. ambassade ( *f.* ) | ១- ការិយាល័យឬនិវេសដ្ឋានផ្លូវការរបស់អគ្គរដ្ឋទូតនៅបរទេស។<br>២- គោលជំហរ( ឥរិយាបថ ) មុខងារឬការងាររបស់អគ្គរដ្ឋទូត។<br>៣- បេសកកម្មការទូតដែលដឹកនាំដោយអគ្គរដ្ឋទូត។<br>៤- អគ្គរដ្ឋទូតនិងបុគ្គលិករបស់គាត់។<br>៥- មនុស្សមួយក្រុមដែលគេបញ្ជូនឱ្យទៅបំពេញបេសកកម្មការទូតនៅឯបរទេស។ |
| **២៧- បេសកកម្មការទូត**<br>អ. diplomatic mission<br>បារ. mission diplomatique | ស្ថានតំណាងផ្លូវការរបស់ប្រទេសមួយប្រចាំនៅធានីនៃប្រទេសមួយទៀត ហើយ បេសកកម្មនេះអាចបង្កើតឡើងបាន លុះត្រាតែមានការព្រមព្រៀងគ្នាជាមុនរវាងប្រទេសទាំងពីរ។<br>ឧ. នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៦ ព្រះរាជាណាចក្រកម្ពុជាបានព្រមព្រៀងជាមួយសាធារណរដ្ឋកូរ៉េ( កូរ៉េខាងត្បូង ) ដើម្បីស្ថាបនាឡើងវិញនូវបេសកកម្មការទូតដែលបានអាក់ខានអស់រយៈពេលជាង២០ឆ្នាំមកហើយ។ |

| | |
|---|---|
| **២៨- អភ័យឯកសិទ្ធិការទូត**<br>អ. diplomatic immunity<br>បារ. immunité diplomatique | សិទ្ធិទាំងឡាយដែលរដ្ឋម្ចាស់ផ្ទះផ្តល់ឱ្យដល់ស្ថានបេសកកម្មការទូតនិងបុគ្គលិកទាំងឡាយរបស់បេសកកម្មការទូតនោះឱ្យរួចផុតពីអំណាចយុត្តាធិការរបស់រដ្ឋម្ចាស់ផ្ទះ ដោយធានានូវភាពពុំអាចបំពារបំពានបាននិងការពារដល់ការអនុវត្តមុខងាររបស់បុគ្គលិកទាំងនោះ។ |
| **២៩- បុព្វសិទ្ធិការទូត**<br>អ. diplomatic privilege<br>បារ. privilèges diplomatiques | សិទ្ធិទាំងឡាយដែលរដ្ឋម្ចាស់ផ្ទះផ្តល់ជូនសកម្មភាពការងាររបស់បេសកកម្មការទូតទាំងនោះ ដើម្បីដោះស្រាយបំបាត់ភាពសាំញ៉ាំរដ្ឋបាលទូទៅនៅក្នុងរដ្ឋម្ចាស់ផ្ទះ ដូចជា ការលើកលែងការបង់ពន្ធដីរបស់ស្ថានទូត ពន្ធលើបៀវត្សរ៍របស់បុគ្គលិកស្ថានទូត ការនាំចូលសម្ភារៈនិងយានជំនិះសម្រាប់ស្ថានបេសកកម្មនិងបុគ្គលិកផ្ទាល់ខ្លួន ដោយការបង់ពន្ធជាបន្ទុករបស់រដ្ឋម្ចាស់ផ្ទះ។ |
| **៣០- ស្ថានកុងស៊ុល**<br>អ. Consulate<br>បារ. consulat ( m. ) | ការិយាល័យដែលបង្កើតឡើងដោយរដ្ឋមួយនៅក្នុងរាជធានីឬទីក្រុងសំខាន់ៗរបស់រដ្ឋមួយទៀតក្នុងគោលបំណងជួយគាំទ្រនិងការពារប្រជាពលរដ្ឋរបស់គេក្នុងការធ្វើដំណើរនិងស្នាក់នៅទីនោះ។ ការិយាល័យនេះទទួលបន្ទុកលើការងាររដ្ឋបាលសំខាន់ៗនានា ដូចជា ការចេញទិដ្ឋាការឱ្យប្រជាពលរដ្ឋនៅក្នុងប្រទេសនោះ ដែលមានបំណងធ្វើដំណើរទៅប្រទេសស្ថានកុងស៊ុលតំណាងនោះ។ ស្ថានកុងស៊ុលទាំងអស់ ទោះបីជា នៅតាមរាជធានីឬទីក្រុងសំខាន់ៗនានាក៏ដោយ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឯក-អគ្គរដ្ឋទូតឬស្ថានទូតរបស់ប្រទេសសាមី។ |
| **៣១- ភារធារី**<br>**អ.** chargé d' affaires<br>**បារ.** chargé d' affaires | ១- ប្រមុខបេសកកម្មការទូតថ្នាក់ទី៣ នៅជាអចិន្ត្រៃយ៍អមក្រសួងការបរទេស។<br>២- សមាជិកបេសកកម្មការទូតទទួលបន្ទុកទទួលខុសត្រូវជាប្រមុខបេសកកម្មការទូតស្តីទី ក្នុងករណីអវត្តមានរបស់ប្រមុខបេសកកម្មការទូត។<br>៣- តាមក្រមរដ្ឋប្រវេណីមានន័យថា មន្ត្រីការទូតដែលទទួលភារកិច្ចជាមន្ត្រីអគ្រានុ-កូលដ្ឋានប្រចាំស្ថានទូត។<br>មន្ត្រីការទូតជាន់ខ្ពស់ដែលមានឋានៈបន្ទាប់ពីឯកអគ្គរដ្ឋទូត ហើយទទួលភារកិច្ចជាប្រធានបេសកកម្មការទូត ដោយជំនួសឯកអគ្គរដ្ឋទូត នៅពេលដែលឯកអគ្គរដ្ឋទូតអវត្តមាន។<br>ឧ. លោក R. Eko Indiarto R ត្រូវបានតែងតាំងឱ្យមកធ្វើជាប្រធានបេសកកម្មការទូតឥណ្ឌូណេស៊ីបណ្តោះអាសន្នប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានឋានៈជាភារធារី បន្ទាប់ពីឯកឧត្តម Nurrachman Oerip អតីតឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌូណេស៊ីប្រចាំប្រទេសកម្ពុជាបានបញ្ចប់បេសកកម្មការទូតរបស់ខ្លួន។ |
| **៣២- សន្ធិសញ្ញា**<br>អ. treaty<br>បារ. traité ( m. ) | កិច្ចព្រមព្រៀងអន្តរជាតិដែលធ្វើឡើងរវាងរដ្ឋនិងរដ្ឋ នៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ហើយ ស្ថិតនៅក្រោមច្បាប់អន្តរជាតិ។ វាជាកិច្ចព្រមព្រៀងរវាងភាគីពីរឬច្រើនដែលជាប្រធាននៃនីតិអន្តរជាតិសំដៅបង្កើតឱ្យមានឥទ្ធិពលខាងផ្លូវច្បាប់ និង ស្ថិតនៅក្រៅច្បាប់អន្តរជាតិ។ សន្ធិសញ្ញាត្រូវធ្វើឡើងដោយស្ម័គ្រចិត្តពីភាគីទាំងអស់ ដែលក្នុងន័យនេះ សន្ធិសញ្ញាអាចត្រូវបានចាត់ទុកជាកិច្ចសន្យាគតិយុត្តិ ដែលមានអានុភាពអនុវត្តតាមផ្លូវច្បាប់ជាលក្ខណៈបង្ខំចំពោះគ្រប់ភាគីទាំងអស់ហើយ ដែលមានភាពខុស |

| | |
|---|---|
| | ប្លែកពីសេចក្តីប្រកាសធម្មតា។<br>ឧ. សន្ធិសញ្ញាសន្តិភាពទីក្រុងវែកសៃ (Versailles) ឆ្នាំ១៩១៩ គឺជាសន្ធិសញ្ញាមួយ ដែលបានបញ្ចប់សង្គ្រាមលោកលើកទី១ជាផ្លូវការ(១៩១៤-១៩១៨)។ សន្ធិសញ្ញានេះបានបង្កើតសង្គមប្រជាជាតិ ដែលបានកំណត់ពីសិទ្ធិកាតព្វកិច្ចរបស់មហាអំណាច ដែលឈ្នះនិងចាញ់សង្គ្រាម និង បានបង្កើតប្រព័ន្ធចាប់បង្ខំមួយ ដែលតាមរយៈនេះ ប្រជាជាតិរីកចម្រើនទទួលបានការគ្រប់គ្រងស្របច្បាប់ទៅលើប្រជាជន ដែលស្ថិតនៅក្រោមអាណានិគមរបស់ខ្លួន។ |
| **៣៣- អនុសញ្ញាអន្តរជាតិ**<br>**អ.** international convention<br>**បារ.** convention internationale | ជាទូទៅ ន័យនៃពាក្យអនុសញ្ញាអន្តរជាតិមានលក្ខណៈដូចគ្នានឹងន័យរបស់ពាក្យសន្ធិសញ្ញាដែរ។ លក្ខណៈវិនិច្ឆ័យនៃអនុសញ្ញាគឺ៖<br>- អនុសញ្ញាមានន័យនិងចាត់ទុកដូចជាច្បាប់សន្មត (ច្បាប់មានលក្ខណៈទូទៅ និងមានភាពប្រាកដប្រជា ដែលត្រូវបានប្រជាជាតិទាំងឡាយលើសាកលលោកសុខចិត្តទទួលយកថា ជាកាតព្វកិច្ចខាងផ្លូវច្បាប់)។<br>- អនុសញ្ញាត្រូវបើកឱ្យមានការចូលរួមពីសំណាក់សហគមន៍អន្តរជាតិទាំងមូលឬពីបណ្តារដ្ឋនានាមួយចំនួនធំ។<br>ឧ. អនុសញ្ញាស្តីពីការទប់ស្កាត់និងការដាក់ទណ្ឌកម្ម នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ១៩៥១ អនុសញ្ញាស្តីពីច្បាប់សមុទ្រ អនុសញ្ញាស្តីពីបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិឆ្នាំ១៩៤៦ អនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងការទូតឆ្នាំ១៩៦១។ |
| **៣៤- អន្តរាគមន៍ការទូត**<br>អ.diplomatic intervention<br>បារ. intervention diplomatique | អន្តរាគមន៍មួយដែលត្រូវបានធ្វើឡើងដោយអង្គការសហប្រជាជាតិឬអង្គការអន្តរជាតិនៅពេលមានជម្លោះអន្តរជាតិកើតឡើង។ អន្តរាគមន៍នេះ មិនមានប្រើអំពើហិង្សាដូចអន្តរាគមន៍យោធាទេ ហើយមានទម្រង់ចំនួន៤ ដូចខាងក្រោម៖<br>១- ការអង្កេត(inquiry)៖ ការស្វែងរកការពិត ដោយអ្នកអង្កេតការណ៍អព្យាក្រឹត។<br>២- ការសម្របសម្រួល(good offices)៖ ការលើកទឹកចិត្តភាគីនានាឱ្យ ចរចាគ្នាដោយប្រកាន់ជំហរអព្យាក្រឹតក្នុងការចរចា។<br>៣- សន្ធានកម្ម(Mediation)៖ ការស្នើឡើងជាដំណោះស្រាយ ដោយធ្វើជាអន្តរការីរវាងភាគីទាំងសងខាង។ ភ្នាក់ងារនេះមានតួនាទីសម្របសម្រួលឱ្យមានដំណោះស្រាយសន្តិវិធី ប៉ុន្តែគ្មានអំណាចចាប់បង្ខំឱ្យភាគីជម្លោះទទួលយកដំណោះស្រាយរបស់ខ្លួនឡើយ។ តួនាទីរបស់អ្នកសម្របសម្រួល គឺគ្រាន់តែផ្តល់ឱវាទតែប៉ុណ្ណោះ។<br>៤- ការសម្រុះសម្រួល(conciliation)៖ នីតិវិធីដែលត្រូវបានបង្កើតឡើង ដោយគណៈកម្មការមួយ ដែលទទួលបានការទុកចិត្តនិងមានការឯកភាពពីភាគីជម្លោះ ដើម្បីតម្រង់ទិសភាគីនានាក្នុងការស្វែងរកដំណោះស្រាយមួយ ដែលមិនចងកាតព្វកិច្ច និង ដើម្បីផ្សះផ្សាជម្លោះរវាងភាគីនានា។ |
| **៣៥- ផ្តាច់ការ**<br>អ. absolute<br>បារ. absolu | - បញ្ញត្តិដែលស្តែងពីបុគ្គលដែលធ្វើឡើងដោយមិនចំណុះទៅលើអ្វីមួយ។<br>- បញ្ញត្តិដែលស្តែងពីការគ្មានការបែងចែកអំណាច។ |

| | |
|---|---|
| **៣៦- ផ្តាច់ការនិយម**<br>អ. absolutism<br>បារ. absolutism ( m. ) | ទម្រង់ដឹកនាំរដ្ឋដែលអំណាចដឹកនាំស្ថិតនៅក្នុងកណ្តាប់ដៃមនុស្សម្នាក់នូវអំណាចទាំងបី គឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ។<br>ឧ. របបរាជានិយមផ្តាច់ការ។ |
| **៣៧- រដ្ឋាភិបាលផ្តាច់ការ**<br>អ. absolute government<br>បារ. gouvernement absolu | រដ្ឋាភិបាលដែលដឹកនាំដោយមនុស្សម្នាក់ឬមនុស្សមួយក្រុម ហើយគ្រប់ដណ្តប់លើអំណាចទាំងបី គឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ។ រដ្ឋាភិបាលប្រភេទនេះមិនអនុញ្ញាតឱ្យប្រជាជនមានសិទ្ធិបោះឆ្នោតតាមលទ្ធិប្រជាធិប-តេយ្យសេរីពហុបក្ស និង មានសិទ្ធិបញ្ចេញមតិក្នុងកិច្ចការរដ្ឋឡើយ។<br>ឧ. ប្រព័ន្ធដឹកនាំរដ្ឋបែបរាជានិយមផ្តាច់ការនិងកុម្មុយនីស្តនិយម តែងតែដឹកនាំរដ្ឋ ដោយរដ្ឋាភិបាលផ្តាច់ការ។ |
| **៣៨- សេចក្តីប្រកាសអន្តរ-ជាតិ**<br>អ. international declaration<br>បារ. déclaration internationale | លិខិតូបករណ៍អន្តរជាតិផ្សេងៗមានលក្ខណវិនិច្ឆ័យ ដូចជា៖<br>១- រាល់សេចក្តីប្រកាសមិនអាចចងភ្ជាប់ជាកាតព្វកិច្ចតាមផ្លូវច្បាប់ទាំងអស់នោះទេ។<br>២- សេចក្តីប្រកាសគឺគ្រាន់តែចង់បង្ហាញឱ្យដឹងពីគោលបំណងអ្វីមួយរបស់ភាគី ណាមួយ។<br>៣- ក្នុងករណីមួយចំនួន មានសេចក្តីប្រកាសខ្លះអាចមានឥទ្ធិពលចំពោះការអនុវត្តជា អន្តរជាតិ ហើយ អាចចងភ្ជាប់កាតព្វកិច្ចជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង ច្បាប់ អន្តរជាតិទូទៅ ក្នុងដំណាក់កាលក្រោយមកទៀត។<br>ឧ. - សេចក្តីប្រកាសសកលស្តីពីសិទ្ធិមនុស្ស ក្រោយមកបានក្លាយជាច្បាប់អន្តរជាតិ ដែលចងភ្ជាប់ប្រជាជាតិទាំងឡាយឱ្យគោរពតាម។<br>- សេចក្តីប្រកាសស្តីពីព្រែកជីកស៊ុយអេនិងការរៀបចំដើម្បីអនុវត្តនៅឆ្នាំ១៩៥៧។ |
| **៣៩- វិសោធនកម្ម**<br>អ. amendment<br>បារ. amendement ( m. ) | ការកែប្រែឬបន្ថែមទៅលើបទដ្ឋាននិងមាត្រានៃច្បាប់រដ្ឋធម្មនុញ្ញ ដូចជា ច្បាប់អន្តរជាតិ ឬរដ្ឋធម្មនុញ្ញ និង ច្បាប់ក្នុងស្រុកមួយឬច្រើន។<br>ឧ. រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើវិសោធនកម្មប្រាំមួយ លើក។ ការធ្វើវិសោធនកម្មលើកទី១ គឺកែប្រែមាត្រា២៨ ដែលត្រូវបានអនុម័ត នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤។ លើកទី២ នៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩។ លើកទី៣ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០១។ លើកទី៤ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៤។ លើកទី៥ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៥ និង លើកទី៦ នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០០៦។ |
| **៤០- អំណាចនីតិបញ្ញត្តិ**<br>អ. legislative<br>បារ. législative ( f. ) | - អំណាចក្នុងការតាក់តែង និង អនុម័តច្បាប់។<br>ឧ. នៅក្នុងប្រទេសសេរីពហុបក្ស ដូចនៅក្នុងប្រទេសកម្ពុជា អំណាចនីតិបញ្ញត្តិ ត្រូវ បានប្រគល់ជូនរដ្ឋសភា និង ព្រឹទ្ធសភា។<br>- អំណាចរបស់ស្ថាប័នសភាដែលមានកាតព្វកិច្ចបង្កើតនិងអនុម័តច្បាប់។ នៅក្នុងប្រទេស កម្ពុជា អង្គការនីតិបញ្ញត្តិ( សភា ) គឺមានរដ្ឋសភា និង ព្រឹទ្ធសភា។<br>ឧ. មាត្រា៩០ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិបញ្ញត្តិ ហើយ បំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់នៅក្នុង រដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាននិងតាមមាត្រា៩៩ថ្មីនៃរដ្ឋធម្មនុញ្ញបានចែងថាព្រឹទ្ធ-សភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូច បានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន។ |

| | |
|---|---|
| **៤១- អំណាចនីតិប្រតិបត្តិ**<br>អ. executive power<br>បារ. pouvoir executif | អំណាចមួយក្នុងចំណោមអំណាចទាំងបីរបស់រដ្ឋ ដែលទទួលបន្ទុកប្រតិបត្តិតាមច្បាប់ និង អនុវត្តច្បាប់។<br>ឧ. នៅប្រទេសកម្ពុជា អំណាចនីតិប្រតិបត្តិសំដៅដល់គណៈរដ្ឋមន្ត្រី ដែលជារាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយ ឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការជាសមាជិក។ |
| **៤២- អំណាចតុលាការ**<br>អ. judiciary power<br>បារ. pouvoir judiciaire | អំណាចមួយក្នុងចំណោមអំណាចទាំងបីរបស់រដ្ឋ ដែលទទួលបន្ទុកជម្រះក្តី។<br>ឧ. មាត្រា១២៨ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ បានចែងថា អំណាចតុលាការជានារក្សាអនាគតិនិងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង។ អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និង សាលាជម្រះក្តីគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់។ |
| **៤៣- សិទ្ធិស្វ័យសម្រេច**<br>អ. autodetermination<br>បារ. autodetermination (f.) | សិទ្ធិក្នុងការសម្រេចចិត្តដោយឯករាជ្យរបស់បុគ្គល ក្រុម សហគមន៍ ស្ថាប័ន ឬ ប្រទេសណាមួយ។<br>ឧ. ស្របតាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាកម្ពុជាឆ្នាំ១៩៩៣ ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិស្វ័យសម្រេចក្នុងការជ្រើសរើសតំណាងរាស្ត្រ ដែលខ្លួនពេញចិត្ត។<br>ឧ. នៅឆ្នាំ២០០២ ប្រជាជនទីម័រខាងកើតបានប្រើប្រាស់សិទ្ធិស្វ័យសម្រេចក្នុងការបង្កើតរដ្ឋឯករាជ្យមួយដោយខ្លួនឯង។ |
| **៤៤- ស្វ័យធនភាព**<br>អ. autarky<br>បារ. autarcie (f.) | ប្រព័ន្ធសេដ្ឋកិច្ចបិទជិតនៃប្រទេសមួយដែលមានការគ្រប់គ្រងដោយខ្លួនឯង ហើយរស់នៅដោយពឹងផ្អែកលើធនធានរបស់ខ្លួនផ្ទាល់។<br>ឧ. ក្រោយវិបត្តិសេដ្ឋកិច្ចពិភពលោកឆ្នាំ១៩២៩ **មូសូលីនី** បានអនុវត្តនយោបាយស្វ័យធនភាពនៅប្រទេសអ៊ីតាលី។ |
| **៤៥- លិខិតឆ្លងដែន**<br>អ. passport<br>បារ. passeport (m.) | ឯកសារផ្លូវការដែលបញ្ជាក់អំពីអត្តសញ្ញាណនិងសញ្ជាតិរបស់ពលរដ្ឋ ដែលអាជ្ញាធរមានសមត្ថកិច្ចផ្តល់ឱ្យសម្រាប់ធ្វើដំណើរទៅបរទេស ក្រោមការគាំពាររបស់រដ្ឋាភិបាលសាមី។ |
| **៤៦- លិខិតឆ្លងដែនការទូត**<br>អ. diplomatic passport<br>បារ. passeport diplomatique | លិខិតឆ្លងដែនដែលអាជ្ញាធរមានសមត្ថកិច្ចផ្តល់ឱ្យមន្ត្រីការទូតនិងឥស្សរជនជាន់ខ្ពស់សម្រាប់បំពេញបេសកកម្មនៅបរទេសតាមការកំណត់របស់រដ្ឋនីមួយៗ។<br>ឧ. យោងអនុក្រឹត្យលេខ២០២ អនក្រ-បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា លិខិតឆ្លងដែនការទូត ចេញថ្វាយ និង ជូនដល់ឥស្សរជនជាន់ខ្ពស់ និងមន្ត្រីការទូតខ្មែរទៅតាមលំដាប់នៃឋានន្តរសក្តិ និង មុខតំណែង ព្រមទាំងសហព័ទ្ធនិងកូន ដែលនៅក្នុងបន្ទុកនៅលីវ ហើយមានអាយុក្រោម១៨ឆ្នាំ ដូចខាងក្រោម៖<br>១- ព្រះមហាវីរក្សត្រ ព្រះវររាជមាតា ព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី ឬ សម្តេចព្រះរាជអគ្គមហេសី។<br>២- ព្រះរាជបុត្រា ព្រះរាជបុត្រី ព្រមទាំងព្រះរាជវង្សានុវង្ស ដែលបញ្ជាក់ដោយក្រសួងព្រះបរមរាជវាំង។ |

| | |
|---|---|
| | ៣- ប្រធាន អនុប្រធាន និង សមាជិកព្រឹទ្ធសភា ប្រធាន អនុប្រធាន និង សមាជិករដ្ឋសភា។<br>៤- ប្រធាន និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។<br>៥- នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ព្រមទាំង រដ្ឋលេខា-ធិការ(ដែលជាប្រធានស្ថាប័នរបស់រាជរដ្ឋាភិបាល) ទេសាភិបាលធនាគារជាតិនៃកម្ពុជា និង អគ្គលេខាធិការរាជរដ្ឋាភិបាល។<br>៦- ប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។<br>៧- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទនិងអគ្គស្នងការនគរបាលជាតិ។<br>៨- ឧត្តមប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រនិងឥស្សរជនដែលមានងារជាសម្តេច។<br>៩- អតីតប្រធានព្រឹទ្ធសភា អតីតប្រធានរដ្ឋសភា អតីតនាយករដ្ឋមន្ត្រី អតីតឧបនាយករដ្ឋមន្ត្រី និង អតីតរដ្ឋមន្ត្រីក្រសួងការបរទេស។<br>១០- នាយកខុទ្ទកាល័យព្រះមហាក្សត្រ នាយកខុទ្ទកាល័យ ប្រធានព្រឹទ្ធសភា នាយកខុទ្ទកាល័យប្រធានរដ្ឋសភា នាយកខុទ្ទកាល័យ នាយករដ្ឋមន្ត្រី ដែលតែងតាំងដោយព្រះរាជក្រឹត្យ។<br>១១- ប្រធានពិធីការរបស់ព្រះមហាក្សត្រ ប្រធានពិធីការរបស់ប្រធានព្រឹទ្ធសភា ប្រធានពិធីការរបស់រដ្ឋសភា និង ប្រធានពិធីការរបស់នាយករដ្ឋមន្ត្រី។<br>១២- មន្ត្រីការទូតចាប់ពីអនុព័ន្ធឡើងទៅ ដែលត្រូវទៅធ្វើការនៅស្ថានទូត និងកុងស៊ុលនៅបរទេស។<br>១៣- លិខិតឆ្លងដែនការទូតចេញថ្វាយនិងប្រគេនសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជទាំងពីរគណៈ និង មន្ត្រីសង្ឃដែលមានងារជាសម្តេច។ |
| **៤៧- លិខិតឆ្លងដែនផ្លូវការ**<br>**អ.** service passport<br>**បារ.** passeport de service | លិខិតឆ្លងដែនដែលអាជ្ញាធរមានសមត្ថកិច្ចផ្តល់ឱ្យមន្ត្រីរាជការទូទៅ សម្រាប់បំពេញបេសកកម្មជាផ្លូវការនៅបរទេស តាមការកំណត់របស់រដ្ឋនីមួយៗ។<br>ឧ. យោងតាមអនុក្រឹត្យលេខ៦៨ អនក្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ នៅព្រះរាជាណាចក្រកម្ពុជា លិខិតឆ្លងដែនផ្លូវការផ្តល់ជូនមន្ត្រីរាជការខ្មែរ សម្រាប់តែទៅបំពេញបេសកកម្មផ្លូវការនៅក្រៅប្រទេសប៉ុណ្ណោះ៖<br>១- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។<br>២- ទីប្រឹក្សាឬជំនួយការមានឋានៈស្មើប្រធាននាយកដ្ឋានដល់អនុរដ្ឋលេខាធិការ។<br>៣- អនុប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញារងសាលាឧទ្ធរណ៍ ចៅក្រមព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង។<br>៤- អនុប្រធានអាជ្ញាធរជាតិ អនុប្រធានគណៈកម្មាធិការជាតិ អនុប្រធានក្រុមប្រឹក្សាជាតិ និង អនុប្រធានស្ថាប័នថ្នាក់ជាតិនានា។<br>៥- ប្រធានសហគ្រាសសាធារណៈនិងគ្រឹះស្ថានសាធារណៈ របស់រដ្ឋ។<br>៦- មន្ត្រីដែលមានមុខតំណែងចាប់ពីអនុប្រធានការិយាល័យឡើងទៅ។<br>៧- មន្ត្រីយោធានិងនគរបាល ឋានៈចាប់ពីវរសេនីយ៍ត្រីឡើងទៅ។<br>៨- បុគ្គលិកបម្រើសេវាស្ថានបេសកកម្មការទូត និង កុងស៊ុល នៅក្រៅប្រទេស។ |

| | |
|---|---|
| | ៩- អង្គរក្សអមដំណើរគណៈប្រតិភូថ្នាក់ដឹកនាំជាន់ខ្ពស់ នៃព្រឹទ្ធសភា រដ្ឋសភា និង រាជរដ្ឋាភិបាល។<br>១០- លិខិតឆ្លងដែនផ្លូវការប្រគេនមន្ត្រីសង្ឃទាំងពីរគណៈចាប់ពីអនុគណ ឡើងទៅ។ |
| **៤៨- លិខិតឆ្លងដែនធម្មតា**<br>**អ.** normal passport<br>**បារ.** passeport normal | លិខិតឆ្លងដែនដែលអាជ្ញាធរមានសមត្ថកិច្ចផ្តល់ឱ្យពលរដ្ឋខ្មែរទាំងពីរភេទ សម្រាប់ធ្វើដំណើរទៅបរទេស តាមការកំណត់របស់រដ្ឋនីមួយៗ។<br>ឧ. យោងតាមអនុក្រឹត្យលេខ៦៨ អនក្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ នៅព្រះរាជាណាចក្រកម្ពុជា លិខិតឆ្លងដែនធម្មតាសម្រាប់ផ្តល់ជូនពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ សម្រាប់ធ្វើដំណើរទៅបរទេស។<br>កុមារអាយុតិចជាង១៨ឆ្នាំ អាចស្នើសុំលិខិតឆ្លងដែននេះផ្ទាល់ខ្លួនបាន បើមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីឪពុកម្តាយឬអាណាព្យាបាលដោយមានភ្ជាប់បណ្ណសម្គាល់គ្រួសារឬសំបុត្រកំណើតភ្ជាប់មកជាមួយពាក្យសុំលិខិតឆ្លងដែនរបស់សាមីខ្លួន។ ក្នុងករណីមានអាយុតិចជាង១២ឆ្នាំ ហើយ ធ្វើដំណើររួមជាមួយឪពុកម្តាយឬអាណាព្យាបាលកុមារទាំងនោះត្រូវចុះក្នុងលិខិតឆ្លងដែន ឬ ឯកសារធ្វើដំណើររបស់ឪពុកម្តាយឬអាណាព្យាបាល។ |
| **៤៩- ស្វ័យគ្រប់គ្រង**<br>អ. self-goverment<br>បារ. libre-administration | របៀបគ្រប់គ្រងដោយស្វ័យតរបស់បុគ្គល គ្រួសារ សហគមន៍ អង្គការ ស្ថាប័ន សហគ្រាស<br>ឧ. អគ្គិសនីកម្ពុជាទទួលបានស្វ័យគ្រប់គ្រងពីរាជរដ្ឋាភិបាលកម្ពុជា។ |
| **៥០- អាណានិគមនិយម**<br>អ. colonialism<br>បារ. colonialism (m.) | ទម្រង់ដោយឡែកមួយនៃប្រព័ន្ធនយោបាយឬលទ្ធិ និង ការអនុវត្តជាក់ស្តែង ដែលនៅក្នុងនោះមហាអំណាចមានលក្ខណៈរឹងប៉ឹងទៅបានដោយសារការឈ្លានពាន ការកាន់កាប់ទឹកដី និង ប្រជាជននៃប្រទេសដែល គេហៅថា ប្រទេសអាណានិគម។<br>ឧ. នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ បារាំងបានដាក់អាណាព្យាបាលនៅ ប្រទេសកម្ពុជា តាមរយៈការចុះនូវសន្ធិសញ្ញាជាមួយព្រះបាទនរោត្តម។ ក្រោយមកទៀត រូបភាពអាណាព្យាបាលនេះត្រូវបានដូរមកជាអាណានិគមវិញ តាមរយៈការចុះសន្ធិសញ្ញាមួយថ្មីទៀត នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤។ |
| **៥១- អាណាព្យាបាល**<br>អ. protectorate<br>បារ. protectorat (m.) | របបគតិយុត្តដោយសន្ធិសញ្ញាមួយដែលរដ្ឋឬទឹកដីមួយ ត្រូវបានដាក់ឱ្យនៅក្រោមការគ្រប់គ្រង និង ការការពារនៃរដ្ឋមួយទៀតដែលមានអំណាចខ្លាំងជាង។ រដ្ឋដែលនៅក្រោមអាណាព្យាបាល មានសិទ្ធិរក្សារដ្ឋាភិបាលឬរដ្ឋបាលរបស់ខ្លួនបាន។<br>ឧ. នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ បារាំងបានមកដាក់អាណាព្យាបាលនៅប្រទេសកម្ពុជា តាមរយៈការចុះសន្ធិសញ្ញាជាមួយនឹងព្រះបាទនរោត្តម។ |
| **៥២- អធិការបតី**<br>អ. chancellor<br>បារ. chancelier (m.) | ប្រមុខរដ្ឋាភិបាលនៃប្រទេសមួយចំនួន។<br>ឧ. ប្រមុខដឹកនាំរដ្ឋាភិបាលនៃប្រទេសអាល្លឺម៉ង់ មានងារជាអធិការបតី។ |
| **៥៣- ប្រជាជាតិ**<br>អ. nation<br>បា. nation (f.) | ក្រុមមនុស្សដែលរស់នៅលើទឹកដីមួយ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលមួយមានសញ្ជាតិនិងភាសាផ្លូវការតែមួយ មានវប្បធម៌ដូចគ្នាឬផ្សេងៗគ្នា ទំនៀមទម្លាប់ប្រហាក់ប្រហែលគ្នា មានប្រវត្តិសាស្ត្រទាក់ទងរវាងជាតិសាសន៍ដែលរស់នៅជាមួយគ្នា។ |

| | |
|---|---|
| | ឧ. មុនខែមិថុនា ឆ្នាំ១៩៩១ អតីតប្រទេសយូហ្គោស្លាវីជារដ្ឋសហព័ន្ធដែលមានប្រជាជាតិ៦ជាផ្លូវការ រួមមាន ស៊ែប៊ី៣៦%, ក្រូអាត២០%, អាល់បានី៩%, ស្លូវេនី៨%, ម៉ាសេដូន៦% និង ម៉ុងតេណេក្រូ ២,៦%។ |
| **៥៤- មូលធននិយម**<br>អ. capitalism<br>បារ. capitalism (m.) | ប្រព័ន្ធនយោបាយនិងសេដ្ឋកិច្ច ដែលតាមរយៈនោះ ឯកជនរៀបចំនិងគ្រប់គ្រងវិស័យពាណិជ្ជកម្មនិងឧស្សាហកម្ម។ |
| **៥៥- អាណានិគម**<br>អ. colony<br>បារ. colonie (f.) | ប្រទេសឬតំបន់មួយដែលត្រូវបានគ្រប់គ្រងដោយប្រទេសផ្សេងមួយទៀតដែលមានអំណាចខ្លាំងជាង។<br>ឧ. ប្រទេសកម្ពុជាធ្លាប់ជាអាណានិគមរបស់ប្រទេសបារាំងពីឆ្នាំ១៨៨៤ដល់ឆ្នាំ១៩៥៣។ |
| **៥៦- ឯករាជ្យ**<br>អ. independence<br>បារ. indépendance (f.) | ភាពនៃរដ្ឋឬប្រទេសដែលមានសិទ្ធិនិងសេរីភាពពេញបរិបូរក្នុងការគ្រប់គ្រងប្រទេសខ្លួនឯង មិនចំណុះប្រទេសដទៃ។<br>ឧ. ប្រទេសកម្ពុជាបានទទួលឯករាជ្យពីប្រទេសបារាំងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ |
| **៥៧- សញ្ជាតិ**<br>អ. nationality<br>បារ. nationalité (f.) | ចរិតឬលក្ខណៈរបស់ប្រជាជាតិមួយដែលរស់នៅរួមគ្នាក្នុងក្របខណ្ឌនៃសហគន៍មួយដែលមានទឹកដី ភាសា ទំនៀមទម្លាប់ និង សេចក្ដីប៉ងប្រាថ្នារួម។ លក្ខណៈពិសេសនៃសញ្ជាតិរបស់ប្រជាជាតិមួយអាចកើតមានឡើងតាមរយៈកំណើតឬធម្មជាតិនីយកម្ម, **សញ្ជាតូបនីយកម្ម** អត្តសញ្ញាណកម្ម អាពាហ៍ពិពាហ៍ ការសុំកូនមកចិញ្ចឹម, នីតិនីយកម្ម និង ការផ្ទេរ ការគ្រប់គ្រងដែនដីពីរដ្ឋមួយទៅរដ្ឋមួយទៀត។<br>ឧ. នៅក្នុងសម័យកាលសង្គ្រាមនៃប្រទេសកម្ពុជាពីឆ្នាំ១៩៧០-១៩៧៩ ប្រជាជនខ្មែរមួយចំនួនបានភៀសខ្លួនទៅរស់នៅបរទេស ដូចជា ប្រទេសបារាំង អាម៉េរិក អូស្ត្រាលី ។ល។ ហើយក្រោយមកពួកគេបានទទួលសញ្ជាតិបារាំង អាម៉េរិក និង អូស្ត្រាលី តាមរយៈនីតិនីយកម្ម។ |
| **៥៨- អាណានិគមនិយមបែបថ្មី**<br>អ. neo-colonialism<br>បារ. néo-colonialisme(m.) | ទម្រង់ថ្មីនៃអាណានិគមនិយមដែលប្រើសម្ពាធផ្នែកសេដ្ឋកិច្ច នយោបាយ វប្បធម៌ ឬ សម្ពាធផ្សេងៗទៀត ដោយប្រទេសដែលមានអំណាចខ្លាំងជាង ដើម្បីត្រួតត្រាឬមានឥទ្ធិពលទៅលើប្រទេសដែលមានការអភិវឌ្ឍតិចតួច។ |
| **៥៩- អព្យាក្រឹតនិយម**<br>អ. neutralism<br>បារ. neutralism (m.) | លទ្ធិឬប្រព័ន្ធនយោបាយដែលប្រទេសមួយប្រកាន់យកគោលការណ៍អព្យាក្រឹតក្នុងទំនាក់ទំនងជាមួយប្រទេសណាមួយ ឬ ក្រុមប្រទេសណាមួយក្នុងគោលបំណងគេចពីការជ្រៀតជ្រែករបស់ប្រទេសមហាអំណាចនិងដើម្បីរក្សាសន្តិភាព។ លទ្ធិនេះបាននាំមកដល់ការបង្កើតចលនាមិនចូលបក្សសម្ព័ន្ធ។ |
| **៦០- អនុស្សរណៈនៃការយោគយល់គ្នា**<br>អ. memorandum of understanding<br>បារ. mémorandum d'entente | លិខិតូបករណ៍អន្តរជាតិទាំងឡាយណាដែលមានទម្រង់ជាលិខិតទោល ហើយមិនតម្រូវឱ្យមានការផ្ដល់សច្ចាប័ន។<br>ឧ. អនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្ដីពីការវាស់វែងនិងខណ្ឌព្រំសីមាព្រំដែនគោក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០០។ |

| | |
|---|---|
| **៦១- លិខិតប្តូរសារ**<br>**អ.** exchange of notes<br>**បារ.** échange (m.) de notes (f.) | លិខិតព្រមព្រៀងរវាងភាគីរដ្ឋនានា ដែលមានលក្ខណៈមិនដូចកិច្ចព្រមព្រៀងឬសន្ធិ-សញ្ញាទេ។ លិខិតប្តូរសារអាចជាការព្រមព្រៀងរវាងរដ្ឋ និង រដ្ឋមុនពេលសម្រេចធ្វើកិច្ចព្រមព្រៀងឬសន្ធិសញ្ញានៅជំហានបន្ទាប់ទៀត។<br>ឧ. អ្នកតំណាងឱ្យរដ្ឋមួយសរសេរលិខិតប្តូរសារផ្ញើទៅរដ្ឋមួយទៀត ក្នុងលិខិតនោះ ម្ចាស់លិខិតលើកឡើងពី«ខ» ទាំងឡាយដែលខ្លួនមានបំណងចង់បង្កើតឡើង។ ប្រសិនបើភាគីម្ខាងទៀតយល់ព្រមតាម«ខ» ទាំងឡាយនោះ គេនឹងឆ្លើយតបជាលិខិតប្តូរសារមួយមកវិញ។ |
| **៦២- ចលនាមិនចូលបក្សសម្ព័ន្ធ**<br>អ. non-aligned movement<br>បារ. mouvement des non-alignés | និន្នាការនយោបាយនៃប្រទេសកំពុងអភិវឌ្ឍមួយចំនួន ដែលប្រកាសថាមិនចូលក្នុងប្លុកនយោបាយណាមួយ។<br>ចលនានេះត្រូវបានបង្កើតជាផ្លូវការនៅទីក្រុងបែលក្រាដ (Belgrade) នៅឆ្នាំ១៩៦១ ក្រោមគំនិតផ្តួចផ្តើមរបស់ប្រធានាធិបតីយូហ្គូស្លាវី Sosip Broz Tito នាយករដ្ឋមន្ត្រីឥណ្ឌា Jawaharlal Nehru ប្រធានាធិបតី អេហ្ស៊ីប Gamal Abdel Nasser ប្រធានាធិបតីហ្គាណា Kwame Nkrumah ប្រធានាធិបតីឥណ្ឌូណេស៊ី Achmed Sukarno និង អធិរាជ អេត្យូពី Haile Selassie។ ចលនានេះមានគោលបំណងធានាឯករាជ្យជាតិ អធិបតេយ្យភាព បូរណភាពទឹកដី និង សន្តិសុខនៃបណ្តារដ្ឋជាសមាជិក ក្នុងការតស៊ូប្រឆាំងចក្រពត្តិនិយម អាណានិគមនិយម អាណានិគមនិយមបែបថ្មី ការប្រកាន់ពូជសាសន៍និយមនិងរាល់ទម្រង់នៃការឈ្លានពាន ការកាន់កាប់ ការគ្រប់គ្រង ការជ្រៀត-ជ្រែក ឬ អនុត្តរភាព ក៏ដូចជាការប្រឆាំងនឹងមហាអំណាច និង ប្លុកនយោបាយ។ |
| **៦៣- អំពើប្រល័យពូជសាសន៍**<br>អ. genocide<br>បារ. genocide (m.) | អំពើមួយក្នុងចំណោមអំពើដូចខាងក្រោម ហើយ ដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬ មួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាមួយ ដូចជា៖<br>- ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម<br>- ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយឬសតិបញ្ញាសមាជិកនៃក្រុម<br>- ការធ្វើដោយចេតនាឱ្យក្រុមនេះ ទទួលរងនូវស្ថានភាពរស់នៅមួយដែលរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុងឬមួយផ្នែក<br>- ការដាក់នូវវិធានការនានា ដែលបំណងរារាំងមិនឱ្យមានការផ្តល់កំណើតទារក<br>- ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយទៅឱ្យក្រុមមួយទៀត។ |
| **៦៤-ឧក្រិដ្ឋជនសង្គ្រាម**<br>អ. war criminal<br>បារ. criminel de guerre | ជនណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម។ |
| **៦៥- សង្គ្រាមត្រជាក់**<br>**អ.** cold war<br>បា. guerre froide (f.) | ការប្រឈមមុខតឹងតែងលើវិស័យការទូត សេដ្ឋកិច្ច ចិត្តសាស្ត្រ ច្រើនជាងការប្រើអាវុធរវាងក្រុមប្រទេសសេរីនិយមឬមូលធននិយម និង ប្រទេសសង្គមនិយម ឬ កុម្មុយនីស្ត ក្រោយសង្គ្រាមលោកលើកទី២។ |
| **៦៦- ហ្វាស៊ីសនិយម**<br>អ. fascism<br>បារ. fascism (m.) | លទ្ធិឬប្រព័ន្ធនយោបាយដែលនាំទៅដល់ការបង្កើតរបបផ្តាច់ការជាតិនិយមជ្រុល ការក្តាប់អំណាចដោយក្រុមអ្នកជំនួញ ដែលដឹកនាំដោយ **មូសូលីនី** នៅក្នុងឆ្នាំ១៩២២ នៅប្រទេសអ៊ីតាលី។ |

| | |
|---|---|
| **៦៧- ស្តាំនិយម**<br>អ. rightism<br>បារ. droitisme ( m. ) | និន្នាការឬមនោគមន៍វិជ្ជានយោបាយ ដែលនិយមការរក្សាទុកឬអភិរក្ស ការបែងចែកអំណាចនិងទ្រព្យសម្បត្តិតាមរយៈប្រព័ន្ធដែលមានស្រាប់ ឬ ការបែរទៅរកការគ្រប់-គ្រងតាមបែបប្រពៃណី។ គេអាចកំណត់ថា ស្តាំនិយមបាន តាមរយៈការដឹកនាំសង្គម ការគ្រប់គ្រងរដ្ឋ សេដ្ឋកិច្ច និង នយោបាយ តាមបែបខាងលើ។<br>៙. ក្នុងអំឡុងសតវត្សរ៍ទី១៩ ការបែងចែកនិន្នាការឆ្វេងនិយម និង ស្តាំនិយម គឺសំដៅលើការបែងចែករវាងអ្នកគាំរបបសាធារណរដ្ឋនិយម និង អ្នកគាំទ្ររបបរាជានិយម។ |
| **៦៨- វៀតកុង**<br>អ. vietcong<br>បារ. viet-cong ( m. ) | យុទ្ធជនកុម្មុយនីស្ត ដែលតស៊ូនៅប្រទេសវៀតណាមខាងត្បូងក្នុងចន្លោះឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៧៥។ |
| **៦៩- វៀតមិញ**<br>អ. vietminh<br>បារ. viet-minh ( m. ) | រណសិរ្សទាមទារឯករាជ្យវៀតណាម ដែលបង្កើតឡើងដោយ ហូ ជីមិញ នៅឆ្នាំ ១៩៤១។ រណសិរ្សនេះប្រមូលផ្តុំជនកុម្មុយនីស្ត និង អ្នកជាតិយម ហើយ កំណត់គោលដៅដេញជនជាតិជប៉ុននិងបារាំងចេញពីប្រទេសវៀតណាម។ |
| **៧០- សង្គ្រាមចៃដន្យ**<br>អ. accidental war<br>**បារ.** guerre accidentelle ( f. ) | <u>**ន័យទី១**</u> ៖ សង្គ្រាមដែលកើតឡើងដោយថាហេតុឥតគ្រោងទុកផ្អែកលើមូលដ្ឋានពីរ ទី១ កំហុសខាងបច្ចេកទេស និង ទី២ ការយល់ខុស ឬ ការវាយតម្លៃស្ថានភាពខុស។<br><u>**ន័យទី២**</u> ៖ ការវាយតម្លៃខុសខាងផ្នែកការទូតនិងយោធា ដែលកំហុសនេះនាំទៅរកស្ថានការណ៍អាក្រក់និងធ្វើឱ្យមានការព្យាករខុសទៅលើលទ្ធផលនៃចំណាត់ការយោធា។ |
| **៧១- អង្គការលើកលែងទោសអន្តរជាតិ**<br>អ. amnesty international<br>បារ. amnistie international ( f. ) | អង្គការនេះធ្វើយុទ្ធនាការអន្តរជាតិក្នុងការគាំទ្រចំពោះអ្នកទាំងឡាយណាដែលជាប់ឃុំឃាំង ដោយជំនឿខាងសាសនា និង នយោបាយទូទាំងពិភពលោក។ អង្គការនេះបានអនុវត្តនូវគោលនយោបាយសំខាន់ៗចំនួនបី ៖<br>- ទីមួយ៖ ដោះលែងអ្នកទោសមនសិការ<br>- ទីពីរ ៖ បញ្ឈប់ការធ្វើទារុណកម្មរាល់ទម្រង់ទាំងអស់រួមទាំងទោសប្រហារជីវិត<br>- ទីបី ៖ ស្វែងរកយុត្តិធម៌និងភាពត្រឹមត្រូវក្នុងការកាត់សេចក្តីចំពោះអ្នកទោសនយោបាយទាំងអស់។<br>អង្គការនេះមានទីតាំងនៅក្រុងឡុងដ៍ប្រទេសអង់គ្លេស មានតំណាងនៅអង្គការសហប្រជាជាតិ ហើយ បានទទួលពានរង្វាន់សិទ្ធិមនុស្សអង្គការសហប្រជាជាតិក្នុងឆ្នាំ ១៩៧៨។ អង្គការនេះទទួលស្គាល់ជាផ្លូវការដោយសហភាពអឺរ៉ុប ក្រុមប្រឹក្សានៃអឺរ៉ុប អង្គការនៃរដ្ឋអាមេរិកនិងអង្គការឯកភាពអាហ្វ្រិក និង ក្នុងឆ្នាំ១៩៧៧ អង្គការនេះបានទទួលពានរង្វាន់ណូបែលសន្តិភាព។ |
| **៧២- សារតាំង**<br>អ. credentials<br>បារ. lettres de créance | លិខិតដែលប្រមុខរដ្ឋនៃរដ្ឋមួយ ផ្តល់ជូនឯកអគ្គរដ្ឋទូតរបស់ខ្លួន ដើម្បីប្រគល់ជូនប្រមុខរដ្ឋនៃប្រទេសដែលស្ថានទូតរបស់ខ្លួនតាំងនៅ។ |

## II.2.1.2- បច្ចេកសព្ទនៃគណៈកម្មការវប្បធម៌

| | |
|---|---|
| ១- ស្រាក់ *ន.* | ខ្នាតឯកតាខ្មែរពីបុរាណដែលដាក់អ្វីៗតម្រួតលើគ្នា ហើយ ចងរុំឱ្យនៅក្នុងដុំតែមួយ ដូចជាស្លាផែនឬចាន ជាដើម។ ចំពោះស្រាក់ស្លាផែន គេខ្ចប់ចងរុំដោយស្លឹកត្នោត មាន ១០ផែនឬ២០ផែន ឬ ក៏ច្រើនជាងនេះ ហៅមួយស្រាក់។ រីឯចានវិញ គេចងរុំ ចំនួន ១០ឬចំនួន១២ ហៅមួយស្រាក់ដែរ។<br>ឧ. ស្លាផែនពីរស្រាក់, ចានបីស្រាក់ ។ |
| ២- បំពង់ *ន.* (បំពង់ឫស្សី) | ខ្នាតរង្វាល់ខ្មែរពីបុរាណ ធ្វើពីបំពង់ឫស្សីស្រុក ប្រើសម្រាប់វាលទឹកត្នោត ដែលមាន ចំណុះរវាង ២លីត្រ ទៅ ៣លីត្រ។<br>ឧ. ទឹកត្នោតពីរបំពង់។<br>ប្រដាប់ឬឧបករណ៍ធ្វើពីបំពង់ឫស្សី ប្រើសម្រាប់វាល់វត្ថុរាវ ដូចជា ទឹកត្នោត ជាដើម។ |
| ៣- កញ្ជើ *ន.* | ខ្នាតរង្វាល់ខ្មែរពីបុរាណ សម្រាប់វាល់គ្រាប់ធញ្ញជាតិ វត្ថុល្អិតៗ ជាដើម ដែលត្បាញ ដោយបន្ទោះឫស្សីខាងលើមានរាងមូល ហៅថា មាត់ក្ដាប់ នឹងបន្ទោះផ្ដៅ ខាងក្រោម រាបហៅថាបាត។<br>ឧ. អង្ករមួយកញ្ជើ។ |
| ៤- ល្អី *ន.* | ខ្នាតរង្វាល់ខ្មែរពីបុរាណ ដូចកញ្ជើដែរ តែមានរាងស្មើលើស្មើក្រោម សម្រាប់វាល់គ្រាប់ ធញ្ញជាតិ វត្ថុល្អិតៗ ជាដើម។<br>ឧ. ស្រូវមួយល្អី។ |
| ៥- កន្ដាំង *ន.* | ខ្នាតរង្វាល់ខ្មែរពីបុរាណ (មានរាងដូចល្អី )សម្រាប់វាល់គ្រាប់ធញ្ញជាតិ មានស្រូវ អង្ករជាដើម ជារង្វាល់អនុភាគ ដែលមានចំណុះពីរភាគឬបីភាគ ឬក៏បួនភាគនៃតៅ។ អ្នកខ្លះហៅថា ខ្ទឹង។ ឧ. ស្រូវបីកន្ដាំង។ |
| ៦- តក់ *ន.* | ខ្នាតរង្វាល់ខ្មែរពីបុរាណ ធ្វើពីត្រឡោកដូងតក់ ឬដូងក្លៀប ឬក៏ដូងស្ដ មានទំហំតូច ជាងនាឡិបន្តិច ប្រើសម្រាប់វាល់អង្ករ។ ជួនកាលគេហៅ នាឡិតូចក៏បាន។<br>ឧ. អង្ករបីតក់។ |
| ៧- កម្បង់ *ន.* | ខ្នាតរង្វាល់ខ្មែរពីបុរាណ ប្រើបាតដៃទាំងពីរផ្គុំគ្នាហើយផ្ងារ ធ្វើឱ្យដក់បន្តិច សម្រាប់ ក្បង់គ្រាប់ធញ្ញជាតិតូចៗឬវត្ថុអ្វីៗមានទំហំតូចល្អិតៗ ឬក៏ម៉ដ្ឋៗ ដាក់ពេញថ្នក់បាត ដៃទាំងពីរនោះ។<br>ឧ. អង្ករពីរកម្បង់។ |
| ៨- ទូកដៃ *ន.* | ខ្នាតរង្វាល់ខ្មែរពីបុរាណ ប្រើបាតដៃម្ខាងដាក់ផ្ងារធ្វើឱ្យដក់បន្តិច សម្រាប់ចូកវាល់គ្រាប់ ធញ្ញជាតិតូចៗឬវត្ថុអ្វីៗមានទំហំតូចល្អិតៗ ឬក៏ម៉ដ្ឋៗ ដាក់ពេញថ្នក់បាតដៃនោះ។<br>ឧ. គ្រាប់ល្ងមួយទូកដៃ។ |
| ៩- ក្ដាប់ *ន.* | ខ្នាតរង្វាល់ខ្មែរពីបុរាណ ប្រើម្រាមដៃម្ខាងរួបក្រសោបបិទ សម្រាប់ចាប់គ្រាប់ធញ្ញជាតិ តូចៗឬវត្ថុអ្វីៗមានទំហំតូចល្អិតៗ ឬក៏ម៉ដ្ឋៗ។<br>ឧ. អង្ករមួយក្ដាប់។ |

| | |
|---|---|
| **១០- ចឹប** *ន.* | ខ្នាតរង្វាល់ខ្មែរពីបុរាណ ប្រើចុងម្រាមដៃម្ខាងរួបប្រួមផ្ដុំគ្នា ច្បិចគ្រាប់ធញ្ញជាតិតូចៗ ឬវត្ថុអ្វីៗមានទំហំតូចល្អិតៗ ឬក៏ម្ជុៗ។<br>ឧ. អំបិលមួយចឹប។ |
| **១១- លី** *ន.* | ខ្នាតខ្មែរពីបុរាណ ដែលមានទម្ងន់ ១/១០ហ៊ុន  ប្រមាណ ០,០៣៧៥ក្រាម។<br>ឧ. មាសបីលី។ |
| **១២- តយ** *ន.* | ប្រដាប់ឬឧបករណ៍ធ្វើពីបំពង់ឬស្សី ប្រើសម្រាប់វាល់វត្ថុរាវ ហើយ ដែលមានចំណុះ ១/៤ លីត្រ ឬ ១/២លីត្រ។<br>ឧ. ទឹកត្នោតជូរឬផ្អែមពីរ តយ។ |

## II.2.1.3- បច្ចេកសព្ទនៃគណៈកម្មការវិចិត្រសិល្បៈ

| | |
|---|---|
| **១- ក្បាច់** *ន.*<br>អ. decoration<br>បារ. ornement | រូបរចនាដែលមានលក្ខណៈវិចិត្របង្កើតចេញពីទិដ្ឋភាពឬរូបភាពអ្វីមួយសម្រាប់តុបតែងលម្អស្ថាបត្យកម្មឬវត្ថុផ្សេងៗ។<br>ឧ. ក្បាច់ភ្ញីភ្លើង ក្បាច់ចក ក្បាច់ពងត្រី ក្បាច់ធ្មេញក្របី ។ល។ |
| **២- ក្បាច់ខ្សែទឹក** *ន.* | ក្បាច់ម្យ៉ាងប្រើប្រាស់សម្រាប់លម្អស្ថាបត្យកម្ម  ដែលធ្វើពីសម្ភារៈផ្សេងៗមានសណ្ឋានជាល្បាក់ខ្សែ ជ្រុង ឆ្នូតវែង ដាក់ផ្ដេក ឬ បញ្ឈរ ទៅតាមលក្ខណៈនៃអគារ ដោយយកភាពស្មើគ្នានៃកម្រិតទឹកជាគោល។<br>គេប្រើក្បាច់ខ្សែទឹកដាក់នៅខាងក្រៅឬខាងក្នុងអគារ ជាទូទៅនៅលើផ្ទៃ ជញ្ជាំង ពិតាន វត្ថុផ្សេងៗ ឬ ឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃ។ ខ្មែរនិយម ប្រើក្បាច់ខ្សែ ទឹកផ្ដេក បញ្ឈរ និង ព័ទ្ធវ័ណ្ឌ (ព័ទ្ធជុំ)។ |
| |  |
| **៣- នព្វសូល៍** *ន.* | ប្រភេទនៃគ្រឿងរចនាម្យ៉ាងសម្រាប់លម្អស្ថាបត្យកម្ម មានសណ្ឋានផ្សេងៗ ជួនកាលជាក្បាច់កន្ទុបកន្ទុលឬវែងស្រួច  ផ្ទាំងក្បាច់  ផ្ទាំងលេខ  ផ្ទាំងចម្លាក់សត្វ  ដែលជាផ្ចិតសមប្បមាណ  ស្ថិតនៅចំកណ្ដាលព្រំផ្ទះ  ឬ  ចំមណ្ឌលប្រាង្គប្រាសាទបុរាណដែលជានិមិត្តរូបនៃផ្កាយព្រះគ្រោះទាំងប្រាំបួន គឺព្រះអាទិត្យ ព្រះចន្ទ ព្រះអង្គារ ព្រះពុធ ព្រះព្រហស្បតិ៍ ព្រះសុក្រ ព្រះសៅរ៍  ព្រះកេតុ និង រាហុ។<br>ទំនៀមទម្លាប់ខ្មែរ  មានជំនឿថា  ជីវិតមនុស្សឬសត្វ  គឺសុទ្ធតែទទួលឥទ្ធិពលពីផ្កាយនព្វគ្រោះ  ដូច្នេះ  ដើម្បីមានសិរីសួស្ដីនិងជាការដឹងគុណចំពោះផ្កាយទាំងប្រាំបួននេះ |

| | |
|---|---|
| | គេបានធ្វើវត្ថុតំណាងមួយហៅថា «នព្វសូល៍» ដាក់នៅលើព្រំដំបូលផ្ទះចំពីខាងលើនៃល្វែងចន្ទ ឬ ចំមណ្ឌលប្រាង្គ។<br><br> |
| **៤- ព្រំ** *ន.* | គ្រឿងបង្ហើនៃដំបូលអគារសម្រាប់ប្រក់ក្តិតដំបូលសំណង់ត្រង់ប្រទល់ក្បាលកណ្តប ក្បឿង ស័ង្កសី ដោយប្រើសម្ភារៈផ្សេងៗ ដូចជា ក្បឿង បាយអ ស្លឹកកណ្តប ស័ង្កសី ជាដើម។<br>ឧ. ព្រំដំបូលផ្ទះ ព្រំដំបូលអគារ។ |
| **៥- ក្បាច់ប៉ប្រក** *ន.* | ក្បាច់លម្អដំបូលអគារមួយប្រភេទ មានទម្រង់ជា ស្លែក្តោប ភ្នែកមាន់ សម្រាប់ដាក់នៅចុងចែងសំយាបព្រំ (អ្នកស្រុកខ្លះហៅក្បាច់នេះថា ក្បាច់ ភ្នែកមាន់)។<br>ឧ. គេដាក់ក្បាច់ប៉ប្រកឬក្បាច់ភ្នែកមាន់នៅចុងចែងនៃព្រំអគារ។ |
| **៦- បាំងខ្លោង** *ន.* | គ្រឿងលម្អស្ថាបត្យកម្មដែលមានទម្រង់ផ្សេងៗ សម្រាប់តុបតែងលម្អនៅលើខ្លោងទ្វារ ឬ គោបុរៈប្រាសាទបុរាណ វត្តអារាមនិងអគារសាធារណៈ។ នៅកម្ពុជា ជាទូទៅ បាំងខ្លោងច្រើនមានទម្រង់ដូចស្លឹករកា (បច្ចុប្បន្នស្ថាបត្យកររចនាឱ្យមានទម្រង់ផ្សេងៗ)។<br>ឧ. បាំងខ្លោងនៅលើច្រកចេញចូលរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។<br>បាំងខ្លោងវត្តជីបាល ស្ថិតក្នុងភូមិជីបាល ឃុំជីបាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។<br>  |
| **៧- បាំងខ្លែង** *ន.* | ក្បាច់លម្អស្ថាបត្យកម្មមួយប្រភេទ មានសណ្ឋានបែបបាំងខ្លោង ច្រើនភ្ជាប់នឹងប៉ែកដំបូលអគារ ទ្វារ បង្អួច មណ្ឌប ជាដើម។<br>ឧ. បាំងខ្លែងនៅលើប៉ែកដំបូលអគារទីស្តីការគណៈរដ្ឋមន្ត្រី។ |

| | |
|---|---|
| | <br> |
| **៨- បាយអ** *ន.*<br>អ. mortar<br>បារ. mortier ( m. ) | ល្បាយម្យ៉ាងមានធាតុផ្សំដូចជាស៊ីម៉ងត៍ ខ្សាច់ ទឹក ជាដើម ជួនកាលគេបន្ថែមសារធាតុផ្សេងៗសម្រាប់បង្កើនគុណភាព។<br>បាយអបុរាណ មានធាតុផ្សំដូចជា កំបោរ ខ្សាច់ ស្ករ ទឹក ជាដើម។ |
| **៩- បាយអគោម័យ** *ន.* | ល្បាយម្យ៉ាងមានធាតុផ្សំដូចជា ដីឥដ្ឋឬដីដំបូក អង្កាម ចំបើង អាចម៍ គោស្រស់ ទឹក ជាដើម។ |
| **១០- កំបោរប្រេង** *ន.* | ល្បាយម្យ៉ាងដែលផ្សំពីស៊ីម៉ងត៍ខ្មៅនិងទឹក សម្រាប់បន្សុំបេតុងចាស់និងបេតុងថ្មី ឬបាយអចាស់និងបាយអថ្មី ជាដើម។<br>ឧ.ជាងពុម្ពលាយកំបោរប្រេងចាក់ក្នុងពុម្ពសសរមុននឹងចាក់ល្បាយបេតុងបន្តទៀត។ |
| **១១- ពណ៌** *ន.*<br>**អ.** color/colour<br>បារ. couleur ( f. ) | លក្ខណៈសម្គាល់វត្ថុឬបាតុភូតដែលកំណត់ដោយចក្ខុវិញ្ញាណតាមរយៈពន្លឺជាប្រភេទផ្សេងៗ ដូចជា ក្រហម លឿង ខៀវ ជាដើម។<br>ឧ. ព្រះអាទិត្យបញ្ចេញពន្លឺចម្រុះពណ៌។ |
| **១២- តំបន់វប្បធម៌** ន.<br>អ. cultural area<br>បារ. air culturelle ( f. ) | ទីតាំងភូមិសាស្ត្រឬទីតាំងស្រាវជ្រាវដែលបង្ហាញឱ្យឃើញពីនានាភាពនៃវប្បធម៌។<br>ឧ. អង្គរគឺជាតំបន់វប្បធម៌នៃប្រទេសកម្ពុជានិងជាបេតិកភណ្ឌពិភពលោក។ |
| **១៣- បរិវត្តន៍វប្បធម៌** ន. | ការប្រែប្រួលភស្តុតាងបុរាណវត្ថុវិទ្យា ដោយសារសកម្មភាពមនុស្ស នាសម័យក្រោយៗ ដូចជា ការជីកកកាយ ការជួសជុល ការប្រើប្រាស់ និង សកម្មភាពផ្សេងៗទៀត។ |
| **១៤- វិធីប្រវត្តិវប្បធម៌** *ន.*<br>អ. culture-historical approach<br>បារ. approch ( f. ) culturo-historique | របៀបសិក្សាស្រាវជ្រាវបុរាណវត្ថុវិទ្យាដោយប្រើវិធីអនុមានរួម ក្នុងការបកស្រាយអំពីគំរូវប្បធម៌និងសង្គមមនុស្សនៅក្នុងអតីតកាល ដោយផ្អែកលើភស្តុតាងបុរាណវត្ថុវិទ្យាដែលបានរកឃើញ ឬ ដោយផ្អែកលើការបកស្រាយរបស់អ្នកស្រាវជ្រាវមុនៗ។<br>របៀបសិក្សាស្រាវជ្រាវបុរាណវត្ថុវិទ្យាដោយប្រើវិធីអនុមានរួមក្នុងការបកស្រាយអំពីគំរូវប្បធម៌និងសង្គមមនុស្សនៅក្នុងអតីតកាល ដោយផ្អែកតាមភស្តុតាងបុរាណវត្ថុវិទ្យាដែលបានរកឃើញ ឬ ដោយផ្អែកតាមការបកស្រាយរបស់អ្នកស្រាវជ្រាវមុនៗ។ |

| | |
|---|---|
| **១៥- បុរាណវត្ថុវិទ្យាទេសភាព ន.**<br>អ. landscape archaeology<br>បារ. paysage (m.) archéologique | បុរាណវត្ថុវិទ្យាដែលសិក្សាអំពីសំណល់សកម្មភាពនិងទំនាក់ទំនងរបស់មនុស្សជាលក្ខណៈរូបីនិងអរូបីជាមួយនឹងបរិស្ថានដែលស្ថិតជុំវិញភូមិឋានឬក្នុងទីកន្លែងណាមួយ ដើម្បីបកស្រាយអំពីវប្បធម៌ សាសនា សង្គមនយោបាយ សេដ្ឋកិច្ច ដែលមានក្នុងសម័យអតីតកាល។ |
| **១៦- បុរាណវត្ថុវិទ្យាប្រព័ន្ធគំនិត ន.**<br>អ. cognitive archaeology/ structural archaeology<br>បារ. archéologie cognitive | បុរាណវត្ថុវិទ្យាដែលប្រើវិធីសាស្ត្របែបទ្រឹស្តីរបស់បុរាណវត្ថុវិទ្យាដែលប្រើសម្រាប់ស្រាវជ្រាវនិងបកស្រាយអំពីទំនាក់ទំនងវប្បធម៌របស់មនុស្សដោយផ្អែកលើមូលដ្ឋានក្បួនខ្នាតនៃទំនៀមទម្លាប់ ប្រពៃណីផ្សេងៗ។ |
| **១៧- បុរាណវត្ថុវិទ្យាបុរេប្រវត្តិសាស្ត្រ**<br>អ. prehistoric archaeology<br>បារ. archeologie (f.) préhistorique | បុរាណវត្ថុវិទ្យាដែលសិក្សាអំពីសង្គមវប្បធម៌និងបរិស្ថាន ដែលកើតមានឡើងតាំងពីសម័យកាលមិនទាន់មានអក្សរសម្រាប់កត់ត្រា ដោយផ្អែកលើសំណល់ផ្សេងៗ ដូចជា សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ សំណល់ផ្ទះបាយ សំណល់រុក្ខជាតិ ឆ្អឹងមនុស្ស ឆ្អឹងសត្វ ទីជម្រក ទីបញ្ចុះសព ជាដើម។<br>ឧ. ការសិក្សាបុរាណវត្ថុវិទ្យាបុរេប្រវត្តិសាស្ត្រ នៅស្ថានីយល្អាងស្ពាន ធ្វើឱ្យយើងយល់ដឹងនិងបកស្រាយបានថា ខ្មែរយើងបានតាំងទីលំនៅក្នុងតំបន់នោះ តាំងពីប្រាំពីរពាន់ឆ្នាំមុនគ្រិស្តសករាជ។ |
| **១៨- បុរាណវត្ថុវិទ្យាប្រវត្តិ-សាស្ត្រ**<br>**អ.** historic archaeology<br>បារ. archeologie (f.) historique | បុរាណវត្ថុវិទ្យាដែលសិក្សាអំពីប្រវត្តិសាស្ត្រ ដោយផ្អែកលើភស្តុតាងបុរាណវត្ថុវិទ្យា ដូចជា សិលាចារឹក ឯកសារសំណេរ សំណង់បុរាណ សិល្បៈចម្លាក់ក្នុងសម័យកាលដែលជាតិសាសន៍មួយមានអក្សរ សម្រាប់កត់ត្រា។ |
| **១៩- បុរាណវត្ថុវិទ្យាក្រោមទឹក / បុរាណវត្ថុវិទ្យាជលបាត**<br>អ. underwater archaeology<br>បារ. archéologie sous-marine | បុរាណវត្ថុវិទ្យាដែលសិក្សាអំពីតឹកតាងបុរាណវត្ថុទាំងឡាយដែលបន្សល់នៅបាតសមុទ្រ ទន្លេ បឹង ស្ទឹង ។ល។ មានដូចជា នាវា សំណង់អគារ ទីក្រុងបុរាណ **កំពង់ផែ** បុរាណ ឬវត្ថុផ្សេងៗ ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប ដើម្បីបកស្រាយពីទំនាក់ទំនងរវាងជីវិតនៅក្នុងទឹកនិងលើគោក។<br>ឧ. ការសិក្សាបុរាណវត្ថុវិទ្យាជលបាតនៅប្រទេសកម្ពុជាបានចាប់ផ្តើម ឡើងបន្ទាប់ពីព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ក្រោមទឹកនៅឆ្នាំ២០០៧។ |
| **២០- បុរាណវត្ថុវិទ្យាសង្គ្រោះ**<br>អ. salvage archaeology/ rescue archaeology/ preventive archaeology<br>បារ. archéologie (f.) de sauvetage (m.) | បុរាណវត្ថុវិទ្យាដែលស្រាវជ្រាវនិងប្រមូលភស្តុតាង ឬ ទិន្នន័យដើម តាមរយៈការធ្វើកំណាយសង្គ្រោះ នៅក្នុងស្ថានីយបុរាណវត្ថុវិទ្យាណាមួយ ដែលទទួលរងការគំរាមកំហែងពីគ្រោះធម្មជាតិ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាលក្ខណៈឯកជនឬសាធារណៈ ដូចជា ការសាងសង់ពង្រីកទីក្រុង ការស្ថាបនាបណ្តាញគមនាគមន៍ ការសាងសង់សំណង់អគារធំៗ ទំនប់ទឹក វារីអគ្គិសនី ព្រលានយន្តហោះនិងមូលដ្ឋានយោធា ជាដើម។ |

| | |
|---|---|
| **២១- កំណាយសង្គ្រោះ**<br>**អ.** salvage excavation<br>**បារ.** fouille (f.) de sauvetage (m.) | បច្ចេកទេសស្រាវជ្រាវរបស់បុរាណវត្ថុវិទ្យាសង្គ្រោះ តាមរយៈការធ្វើ កំណាយនៅលើស្ថានីយបុរាណវត្ថុវិទ្យាណាមួយ ដើម្បីប្រមូលទិន្នន័យដើមឱ្យបានមុនការបាត់បង់ដោយប្រការណាមួយ។ |
| **២២- បុរាណវត្ថុវិទ្យាឧស្សាហកម្ម**<br>**អ.** industrial archaeology<br>**បារ.** archéologie (f.) industrielle | បុរាណវត្ថុវិទ្យាដែលសិក្សាអំពីតឹកតាងនៃការវិវឌ្ឍឧស្សាហកម្ម សម័យបុរាណ ដូចជា រចនាសម្ព័ន្ធសំណង់ឧស្សាហកម្មកន្លែងស្លដែកឬរ៉ែផ្សេងៗទៀត សំណង់ស្ថានីយអយស្ម័យាន ម៉ាស៊ីនដើរដោយកម្លាំងខ្យល់នៅក្នុងសម័យកាលនៃការវិវត្តឧស្សាហកម្ម ឬ ក្រោយសម័យនោះ។ |
| **២៣- សន្លុង** *ន.* | ឡបុរាណធ្វើពីដីឥដ្ឋសម្រាប់ចម្រាញ់យកដែក។ គេនិយមប្រើពាក្យនេះ នៅក្នុងតំបន់ភាគខាងជើងប្រទេសកម្ពុជាក្នុងខេត្តកំពង់ធំ ព្រះវិហារ សៀមរាប ឧត្តរមានជ័យ និងតំបន់មួយចំនួនទៀត នៅភាគខាងលិចទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែង។<br>ឧ. ក្រុមអ្នកស្រាវជ្រាវរាជបណ្ឌិត្យសភាកម្ពុជាបានស្រាវជ្រាវឃើញសន្លុងធំៗនៅក្នុងស្រុករវៀង ជ័យសែន ឆែប សង្គមថ្មី ក្នុងខេត្តព្រះវិហារ និង ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។ |
| **២៤- តាឡែក** *ន.* | បំពង់ខ្យល់ធ្វើពីដីឥដ្ឋ ប្រើសម្រាប់បញ្ចូលខ្យល់ទៅក្នុងសន្លុង។<br>ឧ. តាមការស្រាវជ្រាវ តាឡែកមាន៣ប្រភេទ ៖<br>- ប្រភេទទី១ បំពង់មានអង្កត់ផ្ចិតប្រហែល ២,៥ ស.ម. ទៅ ៣,៥ ស.ម.<br>- ប្រភេទទី២ បំពង់មានអង្កត់ផ្ចិត ៤,០ ស.ម. ទៅ ៦,០ ស.ម.<br>- ប្រភេទទី៣ បំពង់មានអង្កត់ផ្ចិតប្រហែលពី ៧,០ ស.ម. ទៅ ៤០ ស.ម.។ |
| **២៥- បុរាណវត្ថុវិទ្យានគរូបនីយកម្ម**<br>អ. urban archaeology<br>**បារ.** archeology (f.) urbaine | បុរាណវត្ថុវិទ្យាដែលសិក្សាអំពីរចនាសម្ព័ន្ធក្រុង សំណល់ឬស្នាមនៃលំនៅឋាន សំណង់អគារនៅក្នុងក្រុងផ្សេងៗ ជាទីកន្លែងដែលមនុស្សបានតាំងទីលំនៅក្នុងរយៈពេលនៃសម័យកាលណាមួយ។ |
| **២៦- ការពិនិត្យសង្កេតបុរាណវត្ថុវិទ្យាបឋម**<br>អ. archaeological reconnaissance<br>បារ. reconnaissance archéologique | ការសិក្សាពិនិត្យសង្កេតជាប្រព័ន្ធជាដំបូងដើម្បីកំណត់ទីតាំង កំណត់អត្តសញ្ញាណ និង កត់ត្រារបាយទីតាំងស្ថានីយបុរាណវត្ថុវិទ្យាដែលមាននៅលើនិងក្នុងដីក្នុងបរិស្ថាននៃភូមិសាស្ត្រធម្មជាតិ។ |
| **២៧- ការអង្កេតផ្ទៃលើ** *ន.*<br>**អ.** surface survey<br>**បារ.** enquête de surface | វិធីសាស្ត្រមួយរបស់បុរាណវត្ថុវិទ្យាក្នុងការសិក្សាពិនិត្យសង្កេតវត្ថុគំហើញ មានដូចជា បុរាណវត្ថុសិល្បៈ រចនាសម្ព័ន្ធសំណង់បុរាណ អចលនវត្ថុ ជាដើម ដែលស្ថិតនៅលើផ្ទៃដីនៃស្ថានីយណាមួយ។ |
| **២៨- ស្រទាប់វប្បធម៌** *ន.*<br>**អ.** cultural layer<br>**បារ.** strate culturelle (f.) | ស្រទាប់ដីដែលមានសំណល់សកម្មភាពមនុស្ស មានដូចជា បុរាណវត្ថុសិល្បៈ បុរាណអចលនវត្ថុ បុរាណជីវវត្ថុ បុរាណភូគព្ភវត្ថុ រចនាសម្ព័ន្ធសំណង់ ជាដើម ដែលអាចឱ្យយើងយល់ដឹងនិងបែងចែកសម័យកាលនីមួយៗជាប់ដោយឡែកៗពីគ្នា។ |

## II.2.1.4- បច្ចេកសព្ទនៃគណៈកម្មការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

| | |
|---|---|
| **១- កូដវិទ្យា** *ន.*<br>អ. cryptography<br>បារ. crypographie (f.) | ការសិក្សាពីវិធីបំប្លែងទិន្នន័យទៅជាកូដ។ |
| **២- កូដការ** *ន.*<br>អ. encodement<br>បារ. encodage (m.) | ការបំប្លែងទិន្នន័យដែលបានបញ្ចូល (ដូចជា អក្សរ សញ្ញា ពាក្យបញ្ជា) ទៅជាកូដ ឬទៅក្នុងទម្រង់ជាលេខ (១ ឬ ០) ដែលអាចស្គាល់បានដោយកុំព្យូទ័រ។ |
| **៣- អាប់ដេត** *ន.*<br>អ. update<br>បារ. mise (f.) à jour | ការបន្ថែមព័ត៌មាន លក្ខណៈទម្រង់ថ្មី ចូលទៅក្នុងកម្មវិធីឬផលិតផលដែលបានចេញផ្សាយរួច ឬ ដែលមានស្រាប់។ |
| **៤- វិសិដ្ឋកម្ម (អាប់ក្រេដ)** *ន.*<br>អ. upgrade<br>បារ. actualisation (f.) | ការជំនួសសមាសភាគចាស់នៃប្រព័ន្ធ(ផលិតផលកម្មវិធី)ដោយសមាសភាគថ្មីបំផុត។ |
| **៥- ក្រាហ្វ / ក្រាប**<br>អ. graph<br>បារ. graphe (m.) | សម្ព័ន្ធវត្ថុដែលកើតចេញពីចំណុចកំពូលមួយទៅចំណុចកំពូលមួយទៀតនិងខ្សែដែលភ្ជាប់កំពូលចូលគ្នា។ |
| **៦- គំនូសតាង**<br>អ. graphic<br>បារ. graphique (m.) | គំនូសដែលបង្កើតដោយដំណើរការមួយ ដូចជា ការគូស ការបោះពុម្ព។ |
| **៧- ក្រាហ្វិក** *ន.*<br>អ. graphics<br>បារ. infographie (f.) | ទម្រង់ រូបភាព បន្ទាត់ ដែលគេអាចបង្ហាញលើអេក្រង់បោះពុម្ពក្នុងទម្រង់ជារូបភាព ឬសញ្ញា។ |
| **៨- ការប៉ះទង្គិច** *ន.*<br>អ. collision<br>បារ. collision (f.) | ការប្រជ្រៀតគ្នានៃសញ្ញាពីរឬច្រើននៅក្នុងបណ្ដាញមួយ ដែលអាចធ្វើឱ្យទិន្នន័យមានភាពល្អៀងឬបាត់បង់។ |
| **៩- កែសម្រួល** *កិ.*<br>អ. edit<br>បារ. éditer | ផ្លាស់ប្ដូរ កែតម្រូវ ឬ កែប្រែអ្វីមួយ (ឃ្លាឬក៏សុសវែរ...)។ |
| **១០- បញ្ជាប់ចូល** *ន.*<br>អ. login / logon<br>បារ. entrée (f.) dans la système | ដំណើរភ្ជាប់ចូលទៅក្នុងកម្មវិធី កុំព្យូទ័រ បណ្ដាញកុំព្យូទ័រ ឬ ទៅក្នុងតំបន់សុវត្ថិភាពណាមួយ តាមរយៈអត្តនាមនិងលេខសម្ងាត់។ |
| **១១- បណ្ដាច់ចេញ** *ន.*<br>អ. logoff / logout<br>បារ. sortie (f.) du système | ការផ្ដាច់ ឬ បញ្ចប់ពីការចូលក្នុងកម្មវិធី កុំព្យូទ័រ បណ្ដាញកុំព្យូទ័រ។ |

| | |
|---|---|
| **១២- ការពន្លឿន / សំទុះ** *ន.*<br>អ. acceleration<br>បារ. accélération ( f. ) | ការធ្វើឱ្យស្ទុះលឿន។ ( ប្រើនៅឧត្តមសិក្សា ) |
| **១៣- កាតពន្លឿន** *ន.*<br>អ. accelerator card<br>បារ. carte accélératrice | កាតសម្រាប់ពន្លឿនដំណើរការកុំព្យូទ័រឱ្យបានលឿនជាងមុន។ |
| **១៤- កាណាល់** *ន.*<br>អ. channel<br>បារ. canal ( m. ) | ១- គន្លងឬស្ប៉ិចអេឡិចត្រូម៉ាញេទិកដែលគេរៀបចំប្រើក្នុងលក្ខណៈពិសេសណាមួយ។<br>២- ស្រទាប់មួយនៃរូបភាពដែលគេអាចប្រើដោយឡែកឬប្រើសម្រាប់បង្កើត អ្វីដែលគេចង់បាន។ |
| **១៥- កាណាល់ទិន្នន័យ** *ន.*<br>អ. data channel<br>បារ. canal de données | កាណាល់នៃកុំព្យូទ័រដែលប្រើនៅពេលបញ្ជូនទិន្នន័យពីឧបករណ៍មួយទៅឧបករណ៍ មួយទៀត។ |
| **១៦- កាណាល់កូដសម្ងាត់** *ន.*<br>អ. encrypted channel<br>បារ. canal encrypté ? | កាណាល់នៃកុំព្យូទ័រដែលកូដសម្ងាត់ព័ត៌មានឆ្លងកាត់រវាងឧបករណ៍ពីរ។ |
| **១៧- ក្លក** *ន.*<br>អ. clock<br>បារ. horloge ( f. ) | គ្រឿងមួយដែលបង្កើតសញ្ញាទៀងទាត់និងច្បាស់លាស់ ដើម្បីប្រើប្រាស់ក្នុងគោល បំណងអ្វីមួយ ដូចជាការកំណត់ពេលវេលា។ |
| **១៨- ក្លូន** *ន.*<br>អ. clone<br>បារ. clone ( m. ) | កុំព្យូទ័រមួយដែលត្រូវបានចម្លងចេញពីកុំព្យូទ័រដើម តែដំណើរការដូចគ្នាបេះបិទ។ |
| **៨- ក្រាម** *ន.*<br>អ. crystal<br>បារ. cristal ( m. ) | ដុំនៃសារធាតុដែលបានក្លាយជារឹងដោយមានទ្រង់ទ្រាយស្មើសាច់។<br>( ប្រើនៅឧត្តមសិក្សា ) |
| **១៩- ខ្សែកាប** *ន.*<br>អ. cable<br>បារ. câble ( m. ) | បណ្ដុំសរសៃខ្សែដែលដាក់នៅក្នុងបំពង់ការពារមួយ។ |
| **២០- ខ្សែទិន្នន័យ** *ន.*<br>អ. data stream<br>បារ. flux de données ? | ទិន្នន័យដែលបញ្ជូនបន្តគ្នាម្ដងមួយបៃ ម្ដងមួយបៃ។ |
| **២១- រឹម** *ន.*<br>អ. margin<br>បារ. marge ( f. ) | ផ្នែកទំនេររវាងជាយទំព័រឬតារាង និង អត្ថបទ។ |
| **២២- គមនាគមន៍** *ន.*<br>អ. communication<br>បារ. communication ( f. ) | ការបញ្ជូនឬប្ដូរព័ត៌មានទៅវិញទៅមក ពីឧបករណ៍មួយទៅឧបករណ៍មួយ។ |

| | |
|---|---|
| **២៣- គមនាគមន៍ទិន្នន័យ** *ន.*<br>អ. data communication<br>បារ. communication de données | គមនាគមន៍ដែលសម្គាល់ទៅលើការបញ្ជូនទិន្នន័យជាលក្ខណៈឌីជីថល។ |
| **២៤- គូសបន្ទាត់ពីក្រោម** *កិ.*<br>អ. underline<br>បារ. souligner | ដឹកបន្ទាត់ពីក្រោមអក្សរដែលបន្ទាត់ទាំងនោះ អាចជាបន្ទាត់ទោលឬច្រើន។ |
| **២៥- ចុច** *កិ.*<br>អ. click / press<br>បារ. cliquer | សង្កត់ហើយលែងឆ្នុចនៃឧបករណ៍ចង្អុល (ដូចជា កណ្ដុរ ប៊ិកចង្អុល...) ដោយមិនផ្លាស់ទី។ |
| **២៦- ចុចផ្ទួន** *កិ.*<br>អ. double-click<br>បារ. double-cliquer | សង្កត់ហើយលែងឆ្នុចនៃឧបករណ៍ចង្អុល (ដូចជា កណ្ដុរ ប៊ិកចង្អុល...) ពីរដងភ្លាមៗ ដោយមិនផ្លាស់ទី។ |
| **២៧- ចម្លង** *កិ.*<br>អ. copy<br>បារ. copier | ផ្ដិតយកផ្នែកខ្លះឬទាំងមូលនៃអត្ថបទ រូបភាព ព័ត៌មាន ឬ ឯកសារណាមួយឱ្យដូចគ្នានឹងច្បាប់ដើម។ |
| **២៨- អាក់សេស** *ន.*<br>អ. access<br>បារ. accès (m.) | ១- ការបញ្ជូនទិន្នន័យទៅវិញទៅមកក្នុងមេម៉ូរី។<br>២- លទ្ធភាពក្នុងការចូលទៅប្រើប្រព័ន្ធកុំព្យូទ័រ ឬ កម្មវិធីកុំព្យូទ័រ។ |
| **២៩- សិកទ័រ** *ន.*<br>អ. sector<br>បារ. secteur (m.) | ផ្នែកតូចបំផុតនៃឧបករណ៍ផ្ទុកទិន្នន័យ។ |
| **៣០- ឆែត** *ន.*<br>អ. chat<br>បារ. le bavardage(m.) | ការសន្ទនាគ្នាលេង ដោយប្រើអក្សរ សំឡេង...តាមរយៈបណ្ដាញកុំព្យូទ័រ បណ្ដាញសកល ឬ អ៊ីនធឺណិត។ |
| **៣១- ជញ្ជាំងភ្លើង** *ន.*<br>អ. firewall<br>បារ. pare-feu (m.) | ប្រព័ន្ធសុវត្ថិភាព (ហាដវែរ សុសវែរ) ដែលត្រួតពិនិត្យលំហូរទិន្នន័យពីកុំព្យូទ័រមួយទៅកុំព្យូទ័រមួយទៀតឬពីបណ្ដាញកុំព្យូទ័រមួយទៅបណ្ដាញកុំព្យូទ័រ មួយទៀត ឬ ពីអ៊ីនធឺណិត ប្រឆាំងនឹងអាក់សេសខុសច្បាប់(Access) ពីខាង ក្រៅ ឬ ប្រឆាំងនឹងការខូចហាដវែរ នៅកន្លែងណាមួយ។ |
| **៣២- ទ្រៀង** *ន.ឬ គុ.*<br>អ. italic<br>បារ. italique (m.) | *ន.* ប្រភេទតួអក្សរដែលទ្រេតឬផ្អៀងទៅខាងស្ដាំ។<br>*គុ.* ដែលទ្រេតទៅខាងស្ដាំ។ |
| **៣៣- ជំនួយ** *ន.*<br>អ. help<br>បារ. aide(f.) | អនុគមន៍(បែបជំនួយ), សេចក្ដីពន្យល់ណែនាំអ្វីៗសម្រាប់សម្រួលការប្រើកម្មវិធី។ |

| | |
|---|---|
| **៣៤- ឈ្មោះដែន** *ន.*<br>អ. domain name<br>បារ. nom du domaine ( m. ) | នាមឬអាសយដ្ឋានសម្រាប់សម្គាល់ស្ថាប័នក្នុងបណ្ដាញអ៊ីនធឺណិត។ ជាទូទៅ មានទម្រង់ Server.Organization.Type ដែលក្នុងនោះ Type សម្គាល់ឱ្យប្រភេទស្ថាប័ន Organization សម្គាល់ឱ្យឈ្មោះស្ថាប័ន និង Server សម្គាល់ឱ្យសេវូបករណ៍របស់ស្ថាប័ន។ ឧទាហរណ៍ក្នុងយូអរអិល http://www. rac-academy.edu.kh ឈ្មោះដែនគឺ rac-academy.edu.kh ឬ www.rac-academy.edu.kh។ |
| **៣៥- ដាល** *កិ.ឬ ន.*<br>អ. dial<br>បារ. composer | *កិ.* បង្កើតតំណភ្ជាប់កុំព្យូទ័រនឹងឧបករណ៍ទូរគមនាគមន៍។<br>*ន.* ឧបករណ៍បញ្ចូលទិន្នន័យរបស់កុំព្យូទ័រដែលបង្កលក្ខណៈឱ្យអ្នកប្រើប្រាស់បញ្ចូលតម្លៃប៉ារ៉ាម៉ែត្រ។ វាជាប្រភេទមួយនៃឧបករណ៍ផ្ដល់តម្លៃស្កាលែ។ |
| **៣៦- ដែន** *ន.*<br>អ. domain<br>បារ. domaine ( m. ) | ១- ក្រុមកុំព្យូទ័រ និង ក្រុមឧបករណ៍ក្នុងបណ្ដាញមួយ ដែលគ្រប់គ្រងដោយសេវូបករណ៍ ដែលមានច្បាប់និងនីតិវិធីរួម។<br>២- សំណុំតម្លៃដែលអាចមានសម្រាប់មូលទិន្នន័យ ដូចជាលេខកូដតំបន់នៃប្រព័ន្ធទូរស័ព្ទ។ |
| **៣៧- ថាស** *ន.*<br>អ. disk<br>បារ. disque ( m. ) | ឧបករណ៍មានរាងជាបន្ទះមូលស្ដើង ធ្វើពីលោហធាតុឬប្លាស្ទិក... ដោយប្រើដែនម៉ាញេទិក អុបទិក... សម្រាប់ផ្ទុកទិន្នន័យ ព័ត៌មានជាអចិន្ត្រៃយ៍។<br>ឧទាហរណ៍ ថាសចម្រៀង ថាសវីដេអូ។ |
| **៣៨- ដិតក្រាស់** *គុ.*<br>អ. bold<br>បារ. gras | ដែលដិតច្បាស់ក្រាស់លើសពីធម្មតា។ |
| **៣៩- ឌីជីថល** *គុ.ឬ ន.*<br>អ. digital<br>បារ. numérique | *គុ.* ដែលទាក់ទងនឹងគ្រឿងដែលតំណាងឱ្យទិន្នន័យ អំពីទុតជាលេខ។<br>*ន.* សញ្ញាដែលតំណាងដោយលេខ។ |
| **៤០- តម្រឹម** *កិ.*<br>អ. align<br>បារ. aligner | រៀបអត្ថបទឱ្យត្រឹមគ្នាខាងឆ្វេង ស្ដាំ លើ ក្រោម សងខាង ឬ ចំកណ្ដាល។ |
| **៤១- តារាង** *ន.*<br>អ. table<br>បារ. tableau *(m.)* | បញ្ជីទិន្នន័យតម្រៀបតាមជួរដេកនិងជួរឈរភាគច្រើនខណ្ឌដោយក្រឡាបន្ទាត់។ |
| **៤២- បាហ្វ័រ** *ន.*<br>អ. buffer<br>បារ.tampon *(m.)* | ទីតាំងបណ្ដោះអាសន្ន ( ជាទូទៅ រ៉េម RAM )ដែលប្រើសម្រាប់ផ្ទុកទិន្នន័យក្នុងពេលកំពុងបញ្ជូនឬដំណើរការរវាងឧបករណ៍ពីរដែលមានល្បឿនផ្សេងគ្នា។ |
| **៤៣- ថត** *ន.*<br>អ. folder / directory<br>បារ. dossier *(m.)* | កន្លែងផ្ទុកឯកសារក្នុងកុំព្យូទ័រ។ |
| **៤៤-ទ្រនិច** *ន.*<br>អ. cursor<br>បារ. curseur *(m.)* | ១- សញ្ញាពិសេសមួយនៅលើអេក្រង់ មានរូបសណ្ឋានដូចជា ក្បាលព្រួញ, បន្ទាត់, ប្រអប់, ចតុកោណ... លោតភ្លឹបភ្លែតៗ។<br>២- សញ្ញាព្រួញឬរូបដែលផ្លាស់ទីលើអេក្រង់តាមចលនាកណ្ដុរ។ |

| | |
|---|---|
| **៤៥- ទ្វេទិស** *ន.ឬ គុ.*<br>អ. duplex<br>បារ. duplex *(m.)* | *ន.* ការបញ្ជូនទិន្នន័យ(គមនាគមន៍)រវាងប្រព័ន្ធឧបករណ៍ពីរក្នុងទិសដៅទៅវិញទៅមក។<br>*គុ.* នៃទ្វេទិស។ |
| **៤៦- ទ្វេទិសពេញលេញ** *ន.*<br>អ. full-duplex<br>បារ. plein duplex | ទ្វេទិសក្នុងពេលតែមួយព្រមគ្នា។ |
| **៤៧- ជាតុចូល** *ន.*<br>អ. input<br>បារ. entrée *(f.)* | ព័ត៌មានដែលបានបញ្ចូលទៅក្នុងកុំព្យូទ័រ ឬ ទៅក្នុងកម្មវិធី សម្រាប់ដំណើរការ ឬរក្សាទុក។ |
| **៤៨- ជាតុចេញ** *ន.*<br>អ. output<br>បារ. sortie *(f.)* | ព័ត៌មានដែលកុំព្យូទ័របានបង្កើតចេញ ដោយការគណនាឬដំណើរការ។ |
| **៤៩- ទូរគមនាគមន៍** *ន.*<br>អ. telecommunication<br>បារ.telecommunication *(f.)* | គមនាគមន៍ដែលសម្គាល់ទៅលើការបញ្ជូនពីចម្ងាយនូវទិន្នន័យ សំឡេង វីដេអូ និងព័ត៌មានផ្សេងៗ ទាំងអាណាឡូកនិងឌីជីថល ។ |
| **៥០- នាំចេញ** *កិ*<br>អ. export<br>បារ. exporter | បង្កើតឯកសារប្រភេទថ្មីមួយចេញពីទិន្នន័យក្នុងឯកសារដើមដែលកំពុងប្រើ។ |
| **៥១- នាំចូល** *កិ.*<br>អ. import<br>បារ. importer | ទាញយកទិន្នន័យនៃឯកសារប្រភេទផ្សេងទៀតដាក់ក្នុងកម្មវិធីដែលកំពុងប្រើ។ |
| **៥២- ទ្វេទិសពាក់កណ្ដាល** *ន.*<br>អ. half-duplex<br>បារ. semi-duplex *(m.)* | ការបញ្ជូនទិន្នន័យ(គមនាគមន៍)រវាងប្រព័ន្ធឧបករណ៍ពីរក្នុងទិសដៅទៅវិញទៅមកក្នុងពេលផ្សេងគ្នា។ |
| **៥៣- ឯកទិស** *ន.* ឬ *គុ.*<br>អ. simplex<br>បារ. simplex *(m.)* | *ន.* ការបញ្ជូនទិន្នន័យ (គមនាគមន៍)<br>តាមទិសដៅតែមួយគត់ពីឧបករណ៍បញ្ជូនទៅឧបករណ៍ទទួល។<br>ឧទាហរណ៍ : ការផ្សាយតាមប្រព័ន្ធទូរទស្សន៍ ឬ វិទ្យុ។<br>*គុ.* នៃឯកទិស។ |
| **៥៤- បិទភ្ជាប់** *កិ.*<br>អ. paste<br>បារ. coller | បញ្ចេញទិន្នន័យដែលបានចម្លងទុកឬកាត់ទុកភ្ជាប់មកត្រង់ទ្រនិច។ |
| **៥៥- បិទ(ឯកសារ)** *កិ.*<br>អ. close<br>បារ. fermer | បញ្ឈប់ការប្រើប្រាស់ឯកសារដែលបានបើក។ |
| **៥៦- បើក (ឯកសារ)** *កិ.*<br>អ. open<br>បារ. ouvrir | ទាញយកឯកសារដែលមានស្រាប់មកប្រើប្រាស់។ |

| | |
|---|---|
| **៥៧- ស៊ក** *កិ.*<br>អ. insert<br>បារ. insérer | ដាក់អ្វីមួយ (វត្ថុ ទិន្នន័យ...) ចូលទៅក្នុងអ្វីមួយផ្សេងទៀត។ |
| **៥៨- ប្រព័ន្ធគមនាគមន៍** *ន.*<br>អ. communication system<br>បារ. système de communication (f.) | បណ្តុំសមាសធាតុគមនាគមន៍ ដែលមានហាដវែរ សុសវែរ និង កាណាល់។ |
| **៥៩- ប៊ូត** *កិ.*<br>អ. boot<br>បារ. initialiser | បើក ឬ បើកកុំព្យូទ័រឡើងវិញ ហើយ ដាក់ប្រព័ន្ធប្រតិបត្តិការឱ្យដំណើរការ។ |
| **៦០- ប្រតិបត្តិ** *កិ.*<br>អ. execute / run<br>បារ. exécuter | ១- ធ្វើសកម្មភាពឬធ្វើកិច្ចការ ដែលកំណត់ឬបញ្ជាដោយកម្មវិធីកុំព្យូទ័រ។<br>២- ទាញយកកូដនៃកម្មវិធីបញ្ចូលទៅក្នុងមេម៉ូរី បន្ទាប់មកបំពេញកិច្ចការនោះ (នៅក្នុងភាសាសរសេរកម្មវិធី)។ |
| **៦១- បញ្ជាប់** *ន.*<br>អ. link<br>បារ. lien (m.) | ១- កាណាល់រវាងគ្រឿង ឬ ឧបករណ៍ពីរក្នុងប្រព័ន្ធគមនាគមន៍។<br>២- ការភ្ជាប់ផ្ទាល់ទៅអាសយដ្ឋាន (វេប...)មួយទៀត តាមរយៈការបង្ហាញជាពាក្យ ប្រយោគ រូបភាព ឬ និមិត្តសញ្ញាណាមួយ។<br>៣- ផ្នែកមួយនៃកម្មវិធីកុំព្យូទ័រដែលបញ្ជូនប៉ារ៉ាម៉ែត្រទាំងឡាយទៅផ្នែកផ្សេងៗគ្នានៃកម្មវិធីនោះ។ |

## II.3- អក្ខរាវិរុទ្ធនិងអំណាន

គណៈកម្មការអក្ខរាវិរុទ្ធនិងអំណាននៃ ក.ជ.ភ.ខ. បានស្នើមក ក.ជ.ភ.ខ. ឱ្យកំណត់សូរអាននៃពាក្យ «**កម្ពុជា**», «**នាយកដ្ឋាន**», «**ប្រពៃណី**», និង ពាក្យដែលមាន «**ទស្ស-/-ទស្សន៍**» ទាំងអស់។

ក្រោយពីបានជជែក ពិភាក្សា ផ្តល់យោបល់គ្នាទៅវិញទៅមកយ៉ាងល្អិតល្អន់ទៅលើសំណើរបស់គណៈកម្មការនេះ រួចមក អង្គប្រជុំរបស់ក.ជ.ភ.ខ.បានអនុម័តដូចតទៅ៖

១- ពាក្យ «**កម្ពុជា**» យើងអានថា **[កាំ ពុ ជា]**,

២- ពាក្យ «**នាយកដ្ឋាន**» យើងអានថា **[នា យក់ ក្ឋាន]**,

៣- ពាក្យ «**ប្រពៃណី**» យើងអានថា **[ប្រ ពៃ នី]**,

៤- ពាក្យដែលមាន «**ទស្ស-/-ទស្សន៍**» ទាំងអស់ យើងអានថា **[ទស់- / -ទស់]**,

ឧទាហរណ៍:

- ពាក្យ «**ទស្សនៈ**» យើងអានថា **[ទស់ សៈ ន៉ះ]**,
  «**ទស្សន៍ទាយ**» យើងអានថា **[ទស់ ទាយ]**,
  «**ទស្សនីយភាព**» យើងអានថា **[ទស់ សៈ នី យៈ ភាប]**, ...។
- ពាក្យ «**ទូរទស្សន៍**» យើងអានថា **[ទូ រៈ ទស់]**,
  «**សោតទស្សន៍**» យើងអានថា **[សោ តៈ ទស់]**, ...។

# III- សំណើពីមជ្ឈដ្ឋានខាងក្រៅ

## III-1- បច្ចេកសព្ទស្នើដោយលោក Michel Antelme

លោក Michel Antelme បានស្នើមក ក.ជ.ភ.ខ. ឱ្យជួយបកប្រែជាផ្លូវការនូវពាក្យមួយចំនួនជាភាសាបារាំងមកជាភាសាខ្មែរ។

ក្រោយពីពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានសម្រេច ដូចតទៅ៖

| | |
|---|---|
| **១- អនិស្សរវាទ**<br>អ. Agnosticism<br>បារ. Agnosticisme (n.m.) | លទ្ធិដែលចាត់ទុកបរមត្ថ (l'absolu) ថាជាអ្វីដែលពុទ្ធិរបស់យើងមិនអាចយល់បាន ឬលទ្ធិដែលប្រានចោលការជញ្ជឹងគិតតាមបែបបរមត្ថវិជ្ជាថា ឥតប្រយោជន៍។ |
| **២- ឋានានុក្រមកម្ម/ ឋានានុក្រមនីយកម្ម**<br>**អ.** hierarchization<br>**បារ.**hiérarchisation (n.f.) | ការបែងចែកឬរៀបចំតាមឋានានុក្រម។<br>ការបែងចែកឬការរៀបចំជាឋានានុក្រម។ |
| **៣- ប្រភេទវិទ្យា**<br>អ. typology<br>**បារ.** typologie (n.f.) | វិទ្យាសាស្ត្រនៃការបែងចែកទៅតាមប្រភេទទូទៅ ដើម្បីសម្រួលដល់ការធ្វើវិភាគនៃតថ-ភាពស្មុគស្មាញ។ |
| **៤- សូចនា**<br>អ. index<br>បារ. index (n.m.) | តារាងអក្ខរក្រមនៃពាក្យបច្ចេកសព្ទដែលទាក់ទងទៅនឹងប្រធានបទនិងឈ្មោះ ដែលគេដកស្រង់ពីសៀវភៅណាមួយ... ដើម្បីឱ្យងាយរកឃើញ។ |
| **៥- ស៊ីចឹង(គុ.កិ.)**<br>អ. sic<br>បារ. sic (adv.) | ពាក្យដែលគេដាក់ក្នុងវង់ក្រចក បន្ទាប់ពីឃ្លាឬសំនួនវោហារដែលគេដកស្រង់ដោយឥតកែប្រែ ទោះបីឃ្លាឬសំនួនវោហារនោះហាក់ដូចជាប្លែកក៏ដោយ។ |
| **៦- ប្រតិចារឹកអក្សរ**<br>អ. transliteration<br>បារ.translittération (n.f.) | ការកត់ត្រាអក្សរមួយទៅអក្សរមួយនៃប្រព័ន្ធអក្ខរក្រមនៃភាសាណាមួយទៅប្រព័ន្ធអក្ខរក្រមនៃភាសាណាមួយទៀត។ |

## III-2- សំណើរបស់លោក ភាព វិចិត្រ

លោក ភាព វិចិត្រ បានស្នើមក ក.ជ.ភ.ខ. ឱ្យជួយបកស្រាយពាក្យដូចខាងក្រោម ៖

១- តើពាក្យ«ពាក្យបណ្ដឹង» និង «ពាក្យប្ដឹង» មួយណាត្រឹមត្រូវ?

២- តើពាក្យ«ប្រឡង់ដៃ» និង «ប៉ានដៃ» មួយណាត្រឹមត្រូវ?

៣- ពាក្យ «អសន្យាណ្ឌ»។

ក្រោយពីពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានសម្រេច ដូចតទៅ៖

១- «ពាក្យបណ្ដឹង» និង «ពាក្យប្ដឹង»។ ដំបូងគេប្រើតែ «ពាក្យប្ដឹង»ទេ ប៉ុន្តែ «ពាក្យបណ្ដឹង» ត្រូវបានគេប្រើនៅតុលាការ។ អាស្រ័យហេតុនេះ ពាក្យទាំងពីរនេះអាចប្រើបានដូចគ្នា។

២- ពាក្យ«ប្រឡង់ដៃ» និង «ប៉ានដៃ» មិនមានពាក្យណាមួយខុសឬត្រូវទេ ប៉ុន្តែ គេប្រើក្នុងផ្សេងគ្នា ៖

- **ប្រឡង់ដៃ** គឺផ្ទាំងសំពត់ដែលដេរជាពាងបំពង់សម្រាប់ស៊កឬពាក់នៅដើមដៃ ហើយ អាចដោះចេញបាន។
- ចំពោះពាក្យ «ប៉ានដៃ» មានន័យពីរបែប :
- **ប៉ានដៃ** ជាគ្រឿងលម្អមួយប្រភេទដែលគុបតែងរចនាដោយ ត្បូង អង្គាំ ឱន សម្រាប់បំពាក់ត្រង់កំភួនដៃ

នៃតួសម្ដែងក្នុង ល្ខោនបាសាក់ និង ល្ខោនយីកេ។

- **ប៉ានដៃ** សំដៅលើផ្ទាំងសំពត់ដែលគេដេរភ្ជាប់ឬខ្ទាស់នៅលើដៃអាវ។

៣- ចំពោះពាក្យ **អសន្យាណូ** ត្រូវនឹងពាក្យបារាំង «électron» អង្គប្រជុំសុំឱ្យប្រើពាក្យ **«អេឡិចត្រុង»** តាមខេមរយានកម្មវិញ។

## III-3- សំណើរបស់ឯកឧត្ដមទេសរដ្ឋមន្ត្រី យឹម ណុលឡា

ឯកឧត្ដមទេសរដ្ឋមន្ត្រី **យឹម ណុលឡា** បានស្នើសុំរៀបចំប្រជុំមន្ត្រីជំនាញរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរជាមួយគណៈកម្មការសាងសង់អគារសារមន្ទីរសព្វទស្សន៍អង្គរនៅខេត្តសៀមរាប(Angkor Panorama Museum) និង អាជ្ញាធរអប្សរា ដើម្បីពិនិត្យ និង កែតម្រូវកំហុសអក្ខរាវិរុទ្ធលើឈ្មោះប្រាសាទមួយចំនួនក្នុងអគារសារមន្ទីរសព្វទស្សន៍អង្គរ។

ក្រោយពីពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានសម្រេច ដូចតទៅ៖

| ល.រ. | ឈ្មោះជាភាសាខ្មែរ | ឈ្មោះជាអក្សរឡាតាំង |
|---|---|---|
| ១ | **ប្រាសាទបាគង**<br>ព្រះមហាក្សត្រ : ឥន្ទ្រវរ្ម័នទី១<br>សម័យកាល : ចុងសតវត្សរ៍ទី៩<br>រចនាបថ : ព្រះគោ<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ២ | **ប្រាសាទក្រវ៉ាន់**<br>ព្រះមហាក្សត្រ : ឦសានវរ្ម័នទី១<br>សម័យកាល : សតវត្សរ៍ទី៧<br>រចនាបថ : សម្បូរណ៍ព្រៃគុក<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៣ | **ប្រាសាទព្រះគោ**<br>ព្រះមហាក្សត្រ : ឥន្ទ្រវរ្ម័នទី១<br>សម័យកាល : ចុងសតវត្សរ៍ទី៩<br>រចនាបថ : ព្រះគោ<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៤ | **ភ្នំគូលែន**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី២<br>សម័យកាល : សតវត្សរ៍ទី៩<br>រចនាបថ : គូលែន<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៥ | **ប្រាសាទយាយព័ន្ធ**<br>ព្រះមហាក្សត្រ : ឦសានវរ្ម័នទី១<br>សម័យកាល : សតវត្សរ៍ទី៧<br>រចនាបថ : សម្បូរណ៍ព្រៃគុក<br>សាសនា : ព្រហ្មញ្ញសាសនា | |

| | | |
|---|---|---|
| ៦ | **ប្រាសាទតោ**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី២<br>សម័យកាល : សតវត្សរ៍ទី៩<br>រចនាបថ : គូលែន<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៧ | **ប្រាសាទគុប**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១៣<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ៨ | **ប្រាសាទបន្ទាយឆ្មារ**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២ ដើមសតវត្សរ៍ទី១៣<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ៩ | **ព្រះលានជល់ដំរី**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ១០ | **ប្រាសាទព្រហ្មកិល**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ១១ | **ប្រាសាទតានៃ**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ១២ | **ប្រាសាទប្រី**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២ ដើមសតវត្សរ៍ទី១៣<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ១៣ | **ព្រះលានស្តេចគម្លង់**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧ | |

| | | |
|---|---|---|
| | សម័យកាល : ចុងសតវត្សរ៍ទី១២<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ១៤ | **ប្រាសាទតាសោម**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ១៥ | **ប្រាសាទតាព្រហ្ម**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២ ដើមសតវត្សរ៍ទី១៣<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ១៦ | **ប្រាសាទព្រះខ័ន**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ១៧ | **ប្រាសាទនាគព័ន្ធ**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ១៨ | **ស្រះស្រង់**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ១៩ | **ក្បាលស្ពាន**<br>ព្រះមហាក្សត្រ : ឧទយាទិត្យវរ្ម័នទី២<br>សម័យកាល : ចុងសតវត្សរ៍ទី១១ ដើមសតវត្សរ៍ទី១២<br>រចនាបថ : បាពួន<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ២០ | **ប្រាសាទតាកែវ**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៥ សូរ្យវរ្ម័នទី១ | |

| | | |
|---|---|---|
| | សម័យកាល : ចុងសតវត្សរ៍ទី១០ ដើមសតវត្សរ៍ទី១១<br>រចនាបថ : ឃ្លាំង<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ២១ | **ប្រាសាទឃ្លាំង**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៥ សូរ្យវរ្ម័នទី១<br>សម័យកាល : ចុងសតវត្សរ៍ទី១០ ដើមសតវត្សរ៍ទី១១<br>រចនាបថ : ឃ្លាំង<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ២២ | **មេបុណ្យខាងកើត**<br>ព្រះមហាក្សត្រ : រាជេន្ទ្រវរ្ម័ន<br>សម័យកាល : ពាក់កណ្តាលសតវត្សរ៍ទី១០<br>រចនាបថ : ប្រែរូប<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ២៣ | **ប្រាសាទបន្ទាយស្រី**<br>ព្រះមហាក្សត្រ : រាជេន្ទ្រវរ្ម័ន<br>សម័យកាល : សតវត្សរ៍ទី១០<br>រចនាបថ : ប្រែរូប<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ២៤ | **ប្រាសាទបាពួន**<br>ព្រះមហាក្សត្រ : ឧទយាទិត្យវរ្ម័នទី២<br>សម័យកាល : ពាក់កណ្តាលសតវត្សរ៍ទី១១<br>រចនាបថ : បាពួន<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ២៥ | **ភិមានអាកាស**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៥ រាជេន្ទ្រវរ្ម័នទី២ សូរ្យវរ្ម័នទី១<br>សម័យកាល : ចុងសតវត្សរ៍ទី១០ ដើមសតវត្សរ៍ទី១១<br>រចនាបថ : ឃ្លាំង<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ២៦ | **ប្រាសាទប្រែរូប**<br>ព្រះមហាក្សត្រ : រាជេន្ទ្រវរ្ម័ន<br>សម័យកាល : ពាក់កណ្តាលសតវត្សរ៍ទី១០<br>រចនាបថ : ប្រែរូប<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ២៧ | **ប្រាសាទបាទជុំ**<br>ព្រះមហាក្សត្រ : រាជេន្ទ្រវរ្ម័ន<br>សម័យកាល : ពាក់កណ្តាលសតវត្សរ៍ទី១០ | |

| | | |
|---|---|---|
| | រចនាបថ : ប្រែរូប<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ២៨ | **ប្រាសាទក្រចាប់**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៤<br>សម័យកាល : សតវត្សរ៍ទី១០<br>រចនាបថ : កោះកេរ<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ២៩ | **ប្រាសាទបាយ័ន**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ៣០ | **ប្រាសាទក្រោលគោ**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ៣១ | **ប្រាសាទបន្ទាយព្រៃ**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២ ដើមសតវត្សរ៍ទី១៣<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ៣២ | **ក្រុមប្រាសាទព្រះពិធូរ**<br>ព្រះមហាក្សត្រ : សូរ្យវរ្ម័នទី២ ជ័យវរ្ម័នទី៨<br>សម័យកាល : ដើមសតវត្សរ៍ទី១២ ដល់សតវត្សរ៍ទី១៣<br>រចនាបថ : បាពួន និង អង្គរវត្ត<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៣៣ | **ប្រាសាទបន្ទាយសំរែ**<br>ព្រះមហាក្សត្រ : សូរ្យវរ្ម័នទី២<br>សម័យកាល : ដើមសតវត្សរ៍ទី១២<br>រចនាបថ : អង្គរវត្ត<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៣៤ | **ប្រាសាទធម្មនន្ទ**<br>ព្រះមហាក្សត្រ : សូរ្យវរ្ម័នទី២<br>សម័យកាល : ដើមសតវត្សរ៍ទី១២ | |

| | | |
|---|---|---|
| | រចនាបថ : អង្គរវត្ត<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៣៥ | **ខ្លោងទ្វារទន្លេអុំ ( ទ្វារខាងត្បូង )**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២ ដើមសតវត្សរ៍ទី១៣<br>រចនាបថ : បាយ័ន<br>សាសនា : ពុទ្ធសាសនា | |
| ៣៦ | **ប្រាសាទបន្ទាយក្ដី**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២ ដើមសតវត្សរ៍ទី១៣<br>រចនាបថ : អង្គរវត្ត<br>សាសនា : ពុទ្ធសាសនា | |
| ៣៧ | **ប្រាសាទចៅសាយទេវតា**<br>ព្រះមហាក្សត្រ : សូរ្យវរ្ម័នទី២<br>សម័យកាល : ពាក់កណ្ដាលសតវត្សរ៍ទី១២<br>រចនាបថ : អង្គរវត្ត<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៣៨ | **ប្រាសាទអង្គរវត្ត**<br>ព្រះមហាក្សត្រ : សូរ្យវរ្ម័នទី២<br>សម័យកាល : ដើមសតវត្សរ៍ទី១២<br>រចនាបថ : អង្គរវត្ត<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៣៩ | **ប្រាសាទវត្តអធ្វារ**<br>ព្រះមហាក្សត្រ : សូរ្យវរ្ម័នទី២<br>សម័យកាល : ចុងសតវត្សរ៍ទី១១<br>រចនាបថ : អង្គរវត្ត<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៤០ | **ប្រាសាទនាងខ្មៅ**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៤<br>សម័យកាល : សតវត្សរ៍ទី១០<br>រចនាបថ : កោះកេរ<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៤១ | **ប្រាសាទធ្នឹង**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៤<br>សម័យកាល : សតវត្សរ៍ទី១០<br>រចនាបថ : កោះកេរ<br>សាសនា : ព្រហ្មញ្ញសាសនា | |

| | | |
|---|---|---|
| ៤២ | **ប្រាសាទក្រវាន់**<br>ព្រះមហាក្សត្រ : ហស៌វរ្ម័នទី១ ឦសានវរ្ម័នទី២<br>សម័យកាល : ដើមសតវត្សរ៍ទី១០<br>រចនាបថ : បាខែង<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៤៣ | **ប្រាសាទបី**<br>ព្រះមហាក្សត្រ : យសោវរ្ម័នទី១<br>សម័យកាល : សតវត្សរ៍ទី១០<br>រចនាបថ : បាខែង<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៤៤ | **ប្រាសាទភ្នំបាខែង**<br>ព្រះមហាក្សត្រ : យសោវរ្ម័នទី១<br>សម័យកាល : ចុងសតវត្សរ៍ទី៩ ដើមសតវត្សរ៍ទី១០<br>រចនាបថ : បាខែង<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៤៥ | **បន្ទាយពីរជាន់**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៤<br>សម័យកាល : សតវត្សរ៍ទី១០<br>រចនាបថ : កោះកេរ<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៤៦ | **ប្រាសាទប្រាំ**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៤<br>សម័យកាល : សតវត្សរ៍ទី១០<br>រចនាបថ : កោះកេរ<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៤៧ | **ប្រាសាទធំ**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៤<br>សម័យកាល : សតវត្សរ៍ទី១០<br>រចនាបថ : កោះកេរ<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៤៨ | **ប្រាសាទបក្សីចាំក្រុង**<br>ព្រះមហាក្សត្រ : ហស៌វរ្ម័នទី១ រាជេន្ទ្រវរ្ម័នទី២<br>សម័យកាល : ពាក់កណ្តាលសតវត្សរ៍ទី១០<br>រចនាបថ : បាខែង ប្រែរូប<br>សាសនា : ព្រហ្មញ្ញសាសនា | |

| | | |
|---|---|---|
| ៤៩ | **ប្រាសាទក្តីស្វរ**<br>ព្រះមហាក្សត្រ : ហស៌វរ្ម័នទី១<br>សម័យកាល : សតវត្សរ៍ទី៩ និង សតវត្សរ៍ទី១០<br>រចនាបថ : ព្រះគោ ប្រែរូប<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៥០ | **ប្រាសាទលលៃ**<br>ព្រះមហាក្សត្រ : យសោវរ្ម័នទី១<br>សម័យកាល : ចុងសតវត្សរ៍ទី៩<br>រចនាបថ : បាខែង<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៥១ | **មន្ទីរពេទ្យ / អារោគ្យសាលា**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៧<br>សម័យកាល : ចុងសតវត្សរ៍ទី១២<br>រចនាបថ : បាយ័ន<br>សាសនា : ព្រះពុទ្ធសាសនា | |
| ៥២ | - **ប្រាសាទបឹងមាលា**<br>ព្រះមហាក្សត្រ : សូរ្យវរ្ម័នទី២<br>សម័យកាល : ដើមសតវត្សរ៍ទី១២<br>រចនាបថ : អង្គរវត្ត<br>សាសនា : ព្រហ្មញ្ញសាសនា | |
| ៥៣ | **ប្រាសាទកោះកេរ**<br>ព្រះមហាក្សត្រ : ជ័យវរ្ម័នទី៤<br>សម័យកាល : សតវត្សរ៍ទី១០<br>រចនាបថ : កោះកេរ<br>សាសនា : ព្រហ្មញ្ញសាសនា | |

## III-4- សំណើរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្ប:

ក្រសួងវប្បធម៌និងវិចិត្រសិល្ប:បានស្នើមក ក.ជ.ភ.ខ. ឲ្យជួយបកស្រាយពាក្យ «**ល្បុក្កតោ**» ។

ក្រោយពីពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានសម្រេចថា ពាក្យ«**ល្បុក្កតោ**»នេះជាពាក្យខ្មែរសុទ្ធ គឺជាការផ្សំរវាងពាក្យ **ល្បុក** + **តោ** > **ល្បុក្កតោ**។ ពាក្យ **លុក** > **ល្បុក** មានន័យថា *ការវាយលុក* ផ្សំនឹងពាក្យ **តោ** មានន័យថា *ដើរទោរៗ ដើរឱនៗ ឬ ជាសត្វតោ* ។

## III-5- សំណើរបស់លោកបណ្ឌិត ធុយ ចាន់ធួន

លោកបណ្ឌិត ធុយ ចាន់ធួនបានស្នើមក ក.ជ.ភ.ខ. ឲ្យជួយកំណត់ឈ្មោះឧទ្យានជាតិ «**ឧទ្យានជាតិសម្តេចតេជោ ហ៊ុន សែន ឫស្សីត្រឹប**» ។

ក្រោយពីពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានសម្រេចយកឈ្មោះឧទ្យាននេះថា «**ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែន ឫស្សីត្រឹប**»។

## III-6- សំណើរបស់ឯកឧត្តម ង៉ែត បូរី នាយរងខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ឯកឧត្តម **ង៉ែត បូរី** នាយរងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានស្នើមក ក.ជ.ភ.ខ. ឲ្យជួយពិនិត្យនិងកំណត់ចំណងជើងសៀវភៅប្រវត្តិនៃវិមានសន្តិភាព។ ឯកឧត្តមមានសំណើចំនួន៤ ដូចខាងក្រោម៖

វិមានសន្តិភាព<br>ទីស្តីការនាយករដ្ឋមន្ត្រី<br>នៃព្រះរាជាណាចក្រកម្ពុជា<br>និង មជ្ឈមណ្ឌលសន្និសីទអន្តរជាតិ<br>(ឆ្នាំ២០១០)<br>ត្រីមាសទី០៤ ឆ្នាំ២០១០

វិមានសន្តិភាព<br>ទីស្តីការនាយករដ្ឋមន្ត្រី<br>នៃព្រះរាជាណាចក្រកម្ពុជា<br>និង មជ្ឈមណ្ឌលសន្និសីទអន្តរជាតិ<br>ត្រីមាសទី០៤ ឆ្នាំ២០១០

វិមានសន្តិភាព<br>ទីស្តីការនាយករដ្ឋមន្ត្រី<br>នៃព្រះរាជាណាចក្រកម្ពុជា<br>ត្រីមាសទី០៤ ឆ្នាំ២០១០

វិមានសន្តិភាព<br>ទីស្តីការនាយករដ្ឋមន្ត្រី<br>ត្រីមាសទី០៤ ឆ្នាំ២០១០

ក្រោយពីពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានសម្រេចយកចំណងជើង ដូចខាងក្រោម៖

**វិមានសន្តិភាព**<br>**ទីស្តីការនាយករដ្ឋមន្ត្រី**<br>**ព.ស. ២៥៥៤ - គ.ស. ២០១០**

## III-7- សំណើរបស់ឯកឧត្តម ហ៊ុន ម៉ានី

ឯកឧត្តម **ហ៊ុន ម៉ានី** បានស្នើមក ក.ជ.ភ.ខ. សុំការផ្តល់យោបល់និងបកស្រាយអត្ថន័យនៃឈ្មោះកម្មវិធី «**អង្គរសង្ក្រាន្ត**»។

ក្រោយពីពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានសម្រេចយកពាក្យ «**អង្គរសង្ក្រាន្ត**» និង ដោយផ្តល់និយមន័យ ដូចខាងក្រោម៖

«**អង្គរសង្ក្រាន្ត**» ជាពាក្យផ្សំរវាងពាក្យ «**អង្គរ**» និង «**សង្ក្រាន្ត**» ៖

- **អង្គរ** ជាពាក្យប្រើក្លាយមកពីពាក្យ **នគរ** ដែលមានន័យថា **ក្រុង, រាជធានី** (ជួន ណាត វចនានុក្រមខ្មែរ ទំព័រ ១៥៧៣)។
- **សង្ក្រាន្ត** មានន័យថា ដំណើរឃ្លាតចាកទី, ការឈានចូលដល់, ដំណើរដែលព្រះអាទិត្យចរចូលដល់ទីចួបជុំរាសិចក្រ គឺដំណើរដែលដើមនិងចុងនៃរាសិចក្រចួបគ្នា ពេញគ្រប់ជាមួយឆ្នាំ (ដំណើរដាច់ឆ្នាំចាស់ផ្លាស់ឆ្នាំថ្មី) (ជួន ណាត វចនានុក្រមខ្មែរ ទំព័រ១២៣៧) ដូច្នេះ «**អង្គរសង្ក្រាន្ត**» ក្នុងន័យថា *ការចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ នៅទីក្រុងវប្បធម៌ប្រវត្តិសាស្ត្រ* ***អង្គរ*** *នៃព្រះរាជាណាចក្រកម្ពុជា*។

# IV- លិខិតទំនាក់ទំនង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិភាសាខ្មែរ
ចូល
មកដល់ថ្ងៃ ១៩ ខែ ... ម៉ោង 3:00
លេខ 021/11 គជភខ

នាយកក្រុមហ៊ុន **CADE ADVERTISING AGENCY**

**សូមគោរពជូន**

**ឯកឧត្តមបណ្ឌិត ព្រុំ ម៉ុល**

**អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការភាសា**

**សូមទានជ្រាប ។**

<u>កម្មវត្ថុ</u>៖ សំណើរសុំប្រើពាក្យ “**ចរបុរស**” នៅក្នុងកម្មវិធីទូរទស្សន៍ “**អ្នកជាបុរសពិត**” ដែលផលិតឡើងដោយក្រុមហ៊ុន CADE ADVERTISING AGENCY ក្រោមជំនួយថវិកាពី អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI) ដើម្បីអប់រំ និងកែតម្រង់ បុរសកម្ពុជាមួយចំនួនអោយមានភាពទទួលខុសត្រូវ យល់ដឹងពីការបង្ការខ្លួនពីការឆ្លងមេរោគអេដស៍ កុំទទួលទានគ្រឿងស្រវឹងហួសប្រមាណ កុំបើកបរនៅពេលស្រវឹង ចេះផ្តល់តម្លៃចំពោះស្ត្រី ។ល។

តាមកម្មវត្ថុខាងលើ អង្គការសុខភាពគ្រួសារអន្តរជាតិ និង ក្រុមហ៊ុន **CADE ADVERTISING AGENCY** សូមការអនុញ្ញាតិប្រើពាក្យ “**ចរបុរស**” នៅក្នុងចំណងជើងនៃកម្មវិធីប្រកួតដែលមានឈ្មោះថា “**ការប្រកួតស្វែងរកចរបុរស**” សំរាប់វគ្គនេះ ដែលនឹងចាប់ផ្តើមចាក់ផ្សាយតាមទូរទស្សន៍ប៉ុស្តិ៍លេខ ៥ នៅរៀងរាល់ថ្ងៃអាទិត្យ វេលាម៉ោង ២០៖៣០នាទី ដល់ម៉ោង ២១៖៣០នាទី ចាប់ពី ខែមករា ឆ្នាំ ២០១២ ដល់ ខែមីនា ឆ្នាំ ២០១២ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គមជាតិ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមឯកឧត្តមបណ្ឌិតមេត្តាជួយសម្រួល និងអនុញ្ញាតិដោយអនុគ្រោះ។

សូមឯកឧត្តមរាជបណ្ឌិតទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ភ្នំពេញ, ថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១១

នាយកក្រុមហ៊ុន **CADE ADVERITISING AGENCY**

ព្រះរាជាណាចក្រកម្ពុជា
ឃេត
អេដវើថាយស៊ីង អេជេនស៊ី
CADE ADVERTISING AGENCY Ltd.

**ចន គៀត**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាជាតិភាសាខ្មែរ**
National Council of Khmer Language
Conseil National de la Langue Khmère
អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
គេហទំព័រ : www.nckl.gov.kh, ទូរសព្ទ :០១២ ៤៧៣ ៧០១,០១២ ៩០៦ ៥៨៥,០៩២ ៨៩២ ៣៤៣ ទូរសារ : ០២៣ ៨៦៦ ២០៧, អ៊ីមែល : info@nckl.gov.kh

លេខ:.........................

ភ្នំពេញ, ថ្ងៃសុក្រ ទី១២ ខែសីហា ឆ្នាំ២០១១

**គោរពជូន**

លោក **ទិន គៀត** នាយកក្រុមហ៊ុន CADE ADVERTISING AGENCY

លោកនាយក,

សហការីខ្ញុំ លោក ជួរ គារី បានយកលិខិតរបស់លោក១ច្បាប់ទៅឱ្យខ្ញុំ កាលពីថ្ងៃព្រហស្បតិ៍ ទី១១ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង១៤និង២៥នាទីរសៀល។ សំបុត្រដែលអ្នកស្រី ប៉ាន សូលីដា សហការិនីរបស់លោកបានកាន់ផ្ទាល់ទៅលោក ជួរ គារី។ ខ្ញុំឥតបានទទួលអ្នកស្រី ប៉ាន សូលីដា ពីព្រោះខ្ញុំរៀបចូលប្រជុំក្នុងគណៈកម្មការបច្ចេកសព្ទមួយ។ ខ្ញុំសូមជម្រាបលោកថា ខ្ញុំជាប់ជាប្រធានឬជាសមាជិកគណៈកម្មការជាច្រើន : ខ្ញុំទៅរាជបណ្ឌិត្យសភាកម្ពុជាមិនបានទៀងទាត់រាល់ថ្ងៃទេ ហើយ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ខ្ញុំត្រូវអវត្តមាន ដោយខ្ញុំត្រូវចូលរួមក្នុងសន្និសីទមួយ។ អាស្រ័យហេតុនេះ ខ្ញុំបានព្យាយាមផ្ញើទូរសារ(Fax)មួយមកលោក ប៉ុន្តែម៉ាស៊ីន Fax របស់លោកមិនដើរ។ ខ្ញុំគ្មានពេលវេលាគ្រប់គ្រាន់ដើម្បីឱ្យសហការីខ្ញុំរៀបចំបែបបទឆ្លើយមកលោកជាផ្លូវការទេ(ខ្ញុំឆ្លើយផ្ទាល់មកលោកដោយឥតឆ្លងផ្នែករដ្ឋបាលដើម្បីឱ្យចំណេញពេល)។

ខ្ញុំត្រេកអរណាស់ដោយឃើញក្រុមហ៊ុនរបស់លោកចង់ចេះប្រើពាក្យឱ្យបានត្រឹមត្រូវ ប៉ុន្តែសូមលោកជ្រាបផងដែរថា បើសំណួរឬពាក្យពិបាក ខ្ញុំត្រូវដាក់ជូនក្រុមប្រឹក្សាជាតិភាសាខ្មែរ(ដែលបន្តវេនពីអតីតគណៈកម្មាធិការជាតិភាសាខ្មែរ) ឱ្យសមាជិកទាំងអស់ជួយពិនិត្យ : នេះមានន័យថា យើងត្រូវការពេលវែង។ ចំពោះពាក្យ "*វីរបុរស*" ខ្ញុំអាចឆ្លើយមកលោកដោយមិនចាំបាច់ដាក់ចូលក្រុមប្រឹក្សាជាតិភាសាខ្មែរទេ។

នៅក្នុងវចនានុក្រមរបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត យើងមានទាំងបុព្វបទ /*វីរ-*/ និង /*វរ-*/ ដែលគេយកទៅបង្កើតពាក្យ វីរជន, វីរបុរស, វីរភាព, ... វរជន, វរបុរស, វរមិត្ត, ...។ វីរជន, វីរបុរស គឺជាបុរសក្លាហានមិនខ្លាចស្លាប់ដើម្បីការពារប្រទេសជាតិឬឧត្តមគតិរបស់គេ(បើនិយាយពីទាហាន គឺទាហានដែលក្លាហានលើសពីទាហានធម្មតា ដែលក្នុងភាសាបារាំង គេហៅថា Héros)។ ចំពោះ វរជន, វរបុរស, វរមិត្ត, ... គឺជាជនដ៏ប្រសើរ គួរជ្រើសយក។

តាមសេចក្ដីដែលមាននៅក្នុងកម្មវត្ថុនៃលិខិតរបស់លោកនាយក ខ្ញុំគិតថា ពាក្យដែលត្រូវប្រើ គឺពាក្យ "*វរបុរស*" (មិនមែនពាក្យ "*វីរបុរស*" ដែលសម្គាល់អ្នកក្លាហានមិនខ្លាចស្លាប់នោះទេ)។

សូមលោកនាយកមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ ពៅ ម៉ល់

## សំណួរតាមអ៊ីមែលរបស់លោក ធន់ រិទ្ធី

Date : Mon, 17 Jun 2013
From : ធន់ រិទ្ធី <thonnrithy@hotmail.com>
To : info@nckl.gov.kh

Subject: www.nckl.gov.kh: ការប្រើប្រាស់ពាក្យ និង

នេះជាអ៊ីមែលសាកសួរមួយច្បាប់តាមរយៈ: http://www.nckl.gov.kh/ ពី:
ធន់ រិទ្ធី thonnrithy@hotmail.com

សូមគោរពចូលមកក្រុមប្រឹក្សាជាតិភាសាខ្មែរ

ខ្ញុំបាទមានសេចក្ដីត្រេកអរណាស់ ដែលបានស្គាល់គេហទំព័រនេះដែលខ្ញុំបានទន្ទឹងជាយូរមកហើយ។ ខ្ញុំមានចម្ងល់ជាច្រើនក្នុងការប្រើប្រាស់ពាក្យពេចន៍ខ្មែរយើង។ ថ្ងៃនេះខ្ញុំបាទសូមសួរសំណួរមួយ គឺពាក្យ និង។ តើគួរសរសេរថា៖

ក- ចេកនិងម្នាស់,
ខ- ចេក និងម្នាស់,
គ- ចេក និង ម្នាស់,
ឃ- មួយណាក៏បាន

ខ្ញុំបាទសង្ឃឹមថានឹងបានយល់ច្បាស់ក្នុងពេលឆាប់ៗនេះ។

សូមអរគុណ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
គេហទំព័រ : www.nckl.gov.kh, ទូរសព្ទ :០១២ ៤៧៣ ៧០១,០១២ ៩០៦ ៥៨៥,០៩២ ៨៩២ ៣៤៣

National Council of Khmer Language
Conseil National de la Langue Khmère
ទូរសារ : ០២៣ ៨៦៦ ២០៧. អ៊ីមែល : info@nckl.gov.kh

លេខ : ២០៣/១៣ កជភខ/សលក

**សូមជម្រាប**

**លោក ចន់ រិទ្ធី**

កម្មវត្ថុ : ការប្រើពាក្យ "និង" ក្នុងល្បះ

យោង : អ៊ីមែលរបស់លោកចេញថ្ងៃចន្ទ ១៧-០៦-២០១៣

មុនដំបូង ខ្ញុំសូមលោកអនុគ្រោះដោយខ្ញុំឆ្លើយដោយយឺតយ៉ាវ ហើយ ខ្ញុំជម្រាបលោកថា ក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.) ដែលមានភារកិច្ចរកការឯកភាពជូនភាសាខ្មែរ បានឱ្យអាទិភាពទៅការប្រើពាក្យពេចន៍ អក្ខរាវិរុទ្ធ និង អំណាន។

ចំពោះការប្រើពាក្យ "និង" ដែលជាឈ្នាប់ចង វាទាក់ទងនឹងវេយ្យាករណ៍។ ក្រុមប្រឹក្សាជាតិក៏កំពុងធ្វើវេយ្យាករណ៍មួយដើម្បីឱ្យមានសំឡេងតែមួយ ប៉ុន្តែការធ្វើវេយ្យាករណ៍ត្រូវការពេលវែង។

សព្វថ្ងៃ គេប្រើ "និង" ដោយប្រើដំណាក់ឃ្លាផ្សេងៗគ្នា។ ដូច្នេះ ខ្ញុំមិនអាចឆ្លើយថា ដំណាក់ឃ្លាបែបណាជាដំណាក់ឃ្លាខុស ដំណាក់ឃ្លាបែបណាជាដំណាក់ឃ្លាត្រូវ យ៉ាងខ្លីបានទេ។ ខ្ញុំនឹងអាចផ្តល់ចម្លើយផ្លូវការ លុះណាវេយ្យាករណ៍របស់ ក.ជ.ភ.ខ. ត្រូវបានធ្វើចប់។ ក្នុងពេលរង់ចាំ សូមលោកអានអត្ថបទរបស់ខ្ញុំសិនចុះ (វាជាមតិរបស់អ្នកស្រាវជ្រាវម្នាក់)។

*ជូនភ្ជាប់ជាមួយនូវ : អត្ថបទខាងលើ១ច្បាប់ជា PDF ។*

សូមលោកទទួលការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃព្រហស្បតិ៍ ទី២២ ខែសីហា ឆ្នាំ២០១៣

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ ព្រំ ម៉ល់

## សំណួរតាមអ៊ីម៉ែលរបស់លោក Nathan Wells

Date : Sat, 11 May 2013
From : Nathan Wells <sungkhum@gmail.com>
To : info@nckl.gov.kh

Subject: www.nckl.gov.kh: Question on the spelling of Email in Khmer

នេះជាអ៊ីមែលសាកសួរមួយច្បាប់តាមរយៈ: http://www.nckl.gov.kh/ ពី:

Nathan Wells sungkhum@gmail.com

To Whom it May Concern,

Should "email" be written as អ៊ីម៉ែល or អ៊ីម៉ែល ?

With with old KhmerOS Khmer Unicode fonts it was អ៊ីម៉ែល, but now with the new Google web fonts for Khmer, it must be written as អ៊ីម៉ែល .I was under the impression that អ៊ីម៉ែល is the correct way (as the author of the fonts has told me), but I wanted to write and ask if the Council has made any decision about this spelling.

Thank you,

Nathan Wells

for sbbic.org

## ចម្លើយតាមអ៊ីម៉ែលរបស់ក.ជ.ភ.ខ.តបទៅលោក Nathan Wells

Date : Thu, 29 Aug 2013
From : info@nckl.gov.kh
To : Nathan Wells <sungkhum@gmail.com>

Subject: Re: www.nckl.gov.kh: Question on the spelling of Email in Khmer

ចំពោះសញ្ញាត្រីសព្ទនិងមូសិទន្ត វេយ្យាករណ៍ខ្មែរបានសម្រេចជំនួសសញ្ញានេះដោយសញ្ញាបុកជើង( ុ )វិញ បើមានទើសខាងលើដូចស្រៈ ិ ី ឹ ឺ... លើកលែងតែជាមួយព្យញ្ជនៈខ្លះដែលមានប្រើជាមួយត្រីសព្ទផង និងមូសិកទន្តផង : ឧ. ប៉ ី > ប៉ី តែ ប៉ី នៅដដែល។ ចំពោះ E-mail គេអាចអនុវត្តក្បួនវេយ្យាករណ៍បាន គឺ អ៊ីមែល(ដែលគេប្រើជាទូទៅ)។

ត.ប. ប្រធាននៃក.ជ.ភ.ខ.
ប្រធានផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល

សេ អឿន

## សំណួរតាមអ៊ីមែលរបស់លោក យុន ប៊ុនធៀង

Date : Tue, 25 Jun 2013
From : យុន ប៊ុនធៀង <ybunthieng@gmail.com>
To : info@nckl.gov.kh

Subject: www.nckl.gov.kh: អក្សរសាស្ត្រខ្មែរ

នេះជាអ៊ីមែលសាកសួរមួយច្បាប់តាមរយៈ: http://www.nckl.gov.kh/ ពី:
យុន ប៊ុនធៀង ybunthieng@gmail.com

សូមឱ្យក្រុមប្រឹក្សាជាតិភាសាខ្មែរផ្សព្វផ្សាយឯកសារទាំងឡាយឱ្យបានទូលំទូលាយជាងនេះទៀត ព្រោះមានមនុស្សតិចណាស់ដែលបានដឹងអំពីការកែប្រែខ្លះដែលទាក់ទងនឹងអក្សរខ្មែរ។

## ចម្លើយតាមអ៊ីមែលរបស់ក.ជ.ភ.ខ.តបទៅលោក យុន ប៊ុនធៀង

Date : Thu, 29 Aug 2013
From : info@nckl.gov.kh
To : យុន ប៊ុនធៀង <ybunthieng@gmail.com>

Subject: Re: www.nckl.gov.kh: អក្សរសាស្ត្រខ្មែរ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)បានចែកគ្រប់មជ្ឈដ្ឋាននូវព្រឹត្តិបត្រមួយលេខ១ ប៉ុន្តែបានតិចក្នុងមួយកន្លែង១។ ក.ជ.ភ.ខ.មានគេហទំព័រមួយ ដែលអាចបញ្ជូនឯកសារទៅគ្រប់ទិសទី(ទាំងក្នុងនិងក្រៅប្រទេស) ប៉ុន្តែវាអាចបម្រើបានតែសាធារណជនដែលមានចំណេះវិជ្ជាខ្ពស់ ចេះបើកគេហទំព័រ។ ក្រៅពីព្រឹត្តិបត្រនិងគេហទំព័រ ក.ជ.ភ.ខ.ក៏បានបោះពុម្ពកូនសៀវភៅរាប់ម៉ឺនច្បាប់ចែកផ្សព្វផ្សាយអក្ខរាវិរុទ្ធត្រឹមត្រូវទាក់ទងនឹង ៣០៨ពាក្យទៅគ្រប់មជ្ឈដ្ឋាន(លើកលែងតែនៅក្រសួងអប់រំ យុវជននិងកីឡាដែលបានចាត់ចែងផ្ទាល់)។

បន្តិចទៀត ក.ជ.ភ.ខ.នឹងដាក់លក់សទ្ទានុក្រមតាមជំនាញនៅគ្រប់បណ្ណាគារធំៗ។

ត.ប. ប្រធាននៃក.ជ.ភ.ខ.
ប្រធានផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល

សេ អឿន

# V- សមតុល្យ

# តារាងសមតុល្យខាងចំណូលនិងចំណាយ
# ថវិកាសប្បុរសជន

ដើម្បីឱ្យមានតម្លាភាព ក.ជ.ភ.ខ. សូមចុះផ្សាយនូវសមតុល្យនៃថវិកាដែលទទួលបានពីសប្បុរសជនដូចមានខាងក្រោម ៖

| ល.រ | កាលបរិច្ឆេទ | ប្រភពចំណូល | ចំនួនទឹកប្រាក់ | ផ្សេងៗ |
|---|---|---|---|---|
| 1 | មិថុនា-០៧ | ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ | 20,488,000 | |
| 2 | មិថុនា-០៧ | ព្រះគ្រូ ប៊ុត សាវង្ស | 2,290,000 | |
| 3 | មីនា-ឧសភា-០៨ | លោកតា មាស តាំ | 1,425,000 | |
| 4 | មីនា-ឧសភា-០៨ | ព្រះគ្រូ ប៊ុត សាវង្ស | 1,425,000 | |
| 5 | មិថុនា-កញ្ញា-០៨ | លោកតា មាស តាំ | 1,000,000 | |
| 6 | មិថុនា-កញ្ញា-០៨ | ព្រះគ្រូ ប៊ុត សាវង្ស | 1,900,000 | |
| 7 | កក្កដា-០៨ | ព្រះគ្រូ ប៊ុត សាវង្ស | 1,600,000 | |
| 8 | ២-កញ្ញា-០៨ | ឯកឧត្តមបណ្ឌិត ហ៊ាន សាហ៊ីប | 2,000,000 | |
| 9 | តុលា-វិច្ឆិកា-០៨ | ព្រះគ្រូ ប៊ុត សាវង្ស | 950,000 | |
| 10 | តុលា-វិច្ឆិកា-០៨ | លោកតា មាស តាំ | 500,000 | |
| 11 | ធ្នូ-០៨-មករា-០៩ | ព្រះគ្រូ ប៊ុត សាវង្ស | 940,000 | |
| 12 | កុម្ភៈ-០៩ | ព្រះគ្រូ ប៊ុត សាវង្ស | 400,000 | |
| 13 | កុម្ភៈ-មីនា-០៩ | ព្រះគ្រូ ប៊ុត សាវង្ស | 940,000 | |
| 14 | កុម្ភៈ-មីនា-០៩ | លោក មាស តាំ | 400,000 | |
| 15 | ១៦-សីហា-០៩ | ឯកឧត្តមបណ្ឌិត ហ៊ាន សាហ៊ីប | 4,000,000 | |
| 16 | មេសា-មិថុនា-០៩ | ព្រះគ្រូ ប៊ុត សាវង្ស | 1,425,000 | |
| 17 | ២៧-មករា-១០ | លោក Doug Cooper | 3,000,000 | |
| 18 | ២៣-មីនា-១០ | ព្រះគ្រូ ប៊ុត សាវង្ស | 1,780,000 | |
| 19 | ៨-ធ្នូ-១០ | ព្រះតេជគុណ យស ហ៊ុត | 3,076,000 | |
| 20 | ២៦-មករា-១១ | ព្រះគ្រូ ប៊ុត សាវង្ស | 2,830,000 | |
| 21 | ២៦-មករា-១១ | ជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា | 1,230,000 | |
| 22 | ២៦-មករា-១១ | ឯកឧត្តមបណ្ឌិត ហ៊ាន សាហ៊ីប | 2,460,000 | |
| 23 | ២៦-មករា-១១ | បណ្ឌិត ហ៊្សឺ សុមេធ | 2,460,000 | |
| 24 | ២៦-មករា-១១ | បណ្ឌិត អ៊ាប បុណ្ណា | 1,230,000 | |

| | | | | |
|---|---|---|---|---|
| 25 | ២៦-មករា-១១ | ព្រះគ្រូ ប៊ិត សាវង្ស | 1,385,000 | |
| 26 | ១៥-មិថុនា-១១ | ព្រះគ្រូ ប៊ិត សាវង្ស | 1,380,000 | |
| 27 | ៣១-សីហា-១១ | ព្រះគ្រូ ប៊ិត សាវង្ស | 1,400,000 | |
| 28 | ៥-តុលា-១១ | ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន | 8,000,000 | |
| 29 | ៥-តុលា-១១ | ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ | 12,000,000 | |
| 30 | ៥-តុលា-១១ | ឯកឧត្តម ម៉ៅ សុផាន់ | 8,000,000 | |
| 31 | ៥-តុលា-១១ | ឯកឧត្តម ឆ បូណារី | 8,000,000 | |
| 32 | ៥-តុលា-១១ | ឯកឧត្តមបណ្ឌិត ហ៊ាន សាហ៊ីប | 5,000,000 | |
| 33 | ៥-តុលា-១១ | ឯកឧត្តម ប៉ែន បួនពីរ | 1,000,000 | |
| 34 | ៥-តុលា-១១ | ជំទាវ ស៊ីវណ្ណ បុទុម | 400,000 | |
| 35 | ១២-តុលា-១១ | ព្រះគ្រូ ប៊ិត សាវង្ស | 1,390,000 | |
| 36 | ២៣-វិច្ឆិកា-១១ | ព្រះគ្រូ ប៊ិត សាវង្ស | 1,385,000 | ប្រចាំខែឧសភា--ដល់-កក្កដា-២០១១ |
| 37 | ១៩-មករា-១២ | ជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា | 12,000,000 | |
| 38 | ១៩-មករា-១២ | ឯកឧត្តមបណ្ឌិតសភាចារ្យ តិច សំណាង | 12,000,000 | |
| 39 | ៣-កុម្ភៈ-១២ | ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន | 20,000,000 | |
| 40 | ១៨-មេសា-១២ | ព្រះគ្រូ ប៊ិត សាវង្ស | 1,385,000 | ប្រចាំខែសីហា-កញ្ញា-តុលា-២០១១ |
| 41 | ២៣-ឧសភា-១២ | ព្រះគ្រូ ប៊ិត សាវង្ស | 920,000 | ប្រចាំខែវិច្ឆិកា-ធ្នូ-២០១១ |
| 42 | ២០-សីហា-១២ | ព្រះគ្រូ ប៊ិត សាវង្ស | 1,900,000 | ប្រចាំខែមករា-មេសា-២០១២ |
| 43 | ២០-សីហា-១២ | ព្រះតេជគុណ ហ៊ុល សុវណ្ណ | 1,900,000 | ប្រចាំខែមករា-មេសា-២០១២ |
| 44 | ៥-វិច្ឆិកា-១២ | ព្រះគ្រូ ប៊ិត សាវង្ស | 2,850,000 | ប្រចាំខែឧសភា តុលា-២០១២ |
| 45 | ២១-កញ្ញា-១២ | ឯកឧត្តមបណ្ឌិតហ៊ាន សាហ៊ីប | 5,000,000 | ប្រចាំខែមករា-មិថុនា -២០១២ |
| 46 | ២១-កញ្ញា-១២ | ឯកឧត្តម គាត ឈន់ | 2,850,000 | ប្រចាំខែមករា-មិថុនា -២០១២ |
| 47 | ២៤-ធ្នូ-១២ | ព្រះតេជគុណ ហ៊ុល សុវណ្ណ | 2,850,000 | ប្រចាំខែឧសភា-តុលា-២០១២ |
| 48 | ១៨-មករា-១៣ | ឯកឧត្តម គាត ឈន់ | 1,900,000 | ប្រចាំខែកក្កដា-តុលា -២០១២ |
| 49 | ២៩-មករា-១៣ | ឯកឧត្តម ម៉ៅ សុផាន់ | 4,750,000 | ប្រចាំខែមករា-តុលា -២០១២ |
| 50 | ២៩-មករា-១៣ | ឯកឧត្តម ម៉ៅ សុផាន់ | 475,000 | ប្រចាំខែវិច្ឆិកា-ធ្នូ -២០១២ |
| 51 | ២៩-មករា-១៣ | ឯកឧត្តម ម៉ៅ សុផាន់ | 475,000 | ប្រចាំខែមករា-កុម្ភៈ -២០១៣ |
| 52 | ២៩-មករា-១៣ | ព្រះគ្រូ ប៊ិត សាវង្ស | 1,900,000 | ប្រចាំខែវិច្ឆិកា-ធ្នូ២០១២-មករា-កុម្ភៈ -២០១៣ |
| 53 | ២៩-មករា-១៣ | ព្រះតេជគុណ ហ៊ុល សុវណ្ណ | 1,900,000 | ប្រចាំខែវិច្ឆិកា-ធ្នូ២០១២-មករា-កុម្ភៈ -២០១៣ |
| 54 | ១៧-មិថុនា-១៣ | ឯកឧត្តម ម៉ៅ សុផាន់ | 475,000 | ប្រចាំខែមីនា-មេសា -២០១៣ |
| 55 | ១៧-មិថុនា-១៣ | ព្រះគ្រូ ប៊ិត សាវង្ស | 950,000 | ប្រចាំខែមីនា-មេសា -២០១៣ |

| | | | | |
|---|---|---|---|---|
| 56 | ១៧-មិថុនា-១៣ | ព្រះតេជគុណ ហ៊ុល សុវណ្ណ | 950,000 | ប្រចាំខែមីនា-មេសា -២០១៣ |
| 57 | ១៧-មិថុនា-១៣ | លោកបណ្ឌិត សួន ឱសថ | 1,890,000 | ប្រចាំខែមីនា-មេសា -២០១៣ |
| **សរុប** | | | 188,409,000 | |

| ល.រ | កាលបរិច្ឆេទ | ប្រភេទចំណាយ | ចំនួនទឹកប្រាក់ | សមតុល្យ |
|---|---|---|---|---|
| 1 | មិថុនា/2007 | រៀបចំកែបន្ទប់គ.ជ.ភ.ខ. | 20,488,000 | 167,921,000 |
| 2 | មេសា/2008 | បង្គ្រប់ថ្លៃទិញLCD | 2,290,000 | 165,631,000 |
| 3 | កក្កដា/2008 | បង្គ្រប់បោះពុម្ពព្រឹត្តិបត្រលេខ១ | 1,425,000 | 164,206,000 |
| 4 | កក្កដា/2008 | បង្គ្រប់តម្លៃថតចម្លងសទ្ទានុក្រមខេមរយានកម្ម | 1,600,000 | 162,606,000 |
| 5 | 7/កញ្ញា/2008 | វចនានុក្រមបារាំងខ្មែរ-តិប យក់ ថាវ គុណ | 50,400 | 162,555,600 |
| 6 | 7/កញ្ញា/2008 | វចនានុក្រមបារាំងខ្មែរ-តិប យក់ ថាវ គុណ-លី វូអុង | 50,400 | 162,505,200 |
| 7 | 7/កញ្ញា/2008 | វចនានុក្រមខ្មែរ-បារាំងភាគ១+២ | 155,400 | 162,349,800 |
| 8 | 7/កញ្ញា/2008 | សទ្ទានុក្រមបច្ចេកសព្ទទំនើប | 25,200 | 162,324,600 |
| 9 | 7/កញ្ញា/2008 | វិចារណ៍អំពីអក្ខរក្រម និង វេយ្យាករណ៍ខ្មែរ | 25,200 | 162,299,400 |
| 10 | 27/កញ្ញា/2008 | ទូដាក់ឯកសារ | 1,344,000 | 160,955,400 |
| 11 | 14/តុលា/2008 | វចនានុក្រមខ្មែរ ជួន ណាត | 151,200 | 160,804,200 |
| 12 | 10/វិច្ឆិកា/2008 | ថតចម្លងសទ្ទានុក្រមខេមរយានកម្មភាគ១ | 81,000 | 160,723,200 |
| 13 | 17/ធ្នូ/2008 | ថតចម្លងវចនានុក្រមបាឡី-អង់គ្លេស | 35,700 | 160,687,500 |
| 14 | 12/មករា/2009 | ថតចម្លងសទ្ទានុក្រមខេមរយានកម្មភាគ២ | 54,000 | 160,633,500 |
| 15 | ច.26/មករា/2009 | ធ្វើកូប៉ុនសពឯ.ឧ.ឆយ យីហ៊ាង | 205,000 | 160,428,500 |
| 16 | ព.11/កុម្ភៈ/2009 | វចនានុក្រមLarouse,2008 | 300,000 | 160,128,500 |
| 17 | ព.11/កុម្ភៈ/2009 | វចនានុក្រមHachette,2007 | 312,000 | 159,816,500 |
| 18 | ព.11/កុម្ភៈ/2009 | វចនានុក្រមLerobert Junior,1999 | 41,000 | 159,775,500 |
| 19 | ព.11/កុម្ភៈ/2009 | វចនានុក្រមវេជ្ជសាស្ត្រភាគ១,១៩៩១ | 50,000 | 159,725,500 |
| 20 | ព.11/កុម្ភៈ/2009 | វចនានុក្រមពាក្យបច្ចេកទេសពេទ្យ | 25,000 | 159,700,500 |
| 21 | ព.18/កុម្ភៈ/2009 | ឧបត្ថម្ភ សាំងក្រុមចែកព្រឹត្តិបត្រ | 90,000 | 159,610,500 |
| 22 | អ.3/មីនា/2009 | ថតចម្លងឯកសារប្រជុំ | 30,100 | 159,580,400 |
| 23 | ព.4/មីនា/2009 | Petit Larouse de la médecine,2007 | 304,000 | 159,276,400 |
| 24 | ព.4/មីនា/2009 | Harrap's de poche Dictionaire Anglais-Français | 24,000 | 159,252,400 |
| 25 | ព.4/មីនា/2009 | Politique Mouscou | 88,500 | 159,163,900 |

| | | | | |
|---|---|---|---|---|
| 26 | ព.4/មីនា/2009 | វចនានុក្រមខ្មែរ-អង់គ្លេសទំនើប២០០៦ | 46,000 | 159,117,900 |
| 27 | ព.4/មីនា/2009 | វចនានុក្រមបច្ចេកទេសខ្មែរ-អង់គ្លេស យុន សូគ្រីន | 50,000 | 159,067,900 |
| 28 | ព.4/មីនា/2009 | វចនានុក្រមនយោបាយ-រដ្ឋាភិបាល កែវ សំណាង | 40,000 | 159,027,900 |
| 29 | ព.4/មីនា/2009 | វចនានុក្រមខ្មែរ-អង់គ្លេស២០០៧ ឌីវ ស៊ាន | 102,000 | 158,925,900 |
| 30 | ព.4/មីនា/2009 | វចនានុក្រមខ្មែរ-អង់គ្លេស Headley 1977 | 46,000 | 158,879,900 |
| 31 | ព.4/មីនា/2009 | វចនានុក្រមច្បាប់ការទូត ស៊ាន កុសល ១៩៩៩ | 14,000 | 158,865,900 |
| 32 | អ.17/មីនា/2009 | វចនានុក្រមបារាំង-អង់គ្លេស-អង់គ្លេស-បារាំង | 318,000 | 158,547,900 |
| 33 | សុ.3/មេសា/2009 | ឌីហ្សង់ទ័រ | 40,000 | 158,507,900 |
| 34 | អ.7/មេសា/2009 | ត្រួតពិនិត្យចរន្តអគ្គិសនី | 10,000 | 158,497,900 |
| 35 | ច.20/មេសា/2009 | ខ្សែភ្លើងនិងឈ្នួល | 300,000 | 158,197,900 |
| 36 | ច.20/មេសា/2009 | ប្រអប់ស្រោបខ្សែភ្លើងនិងឈ្នួលពលកម្ម | 518,560 | 157,679,340 |
| 37 | ព.22/មេសា/2009 | Longman Dictionary Language | 72,000 | 157,607,340 |
| 38 | ព.22/មេសា/2009 | វចនានុក្រមអង់គ្លេសសុទ្ធHarapp's Chambers | 18,000 | 157,589,340 |
| 39 | 15/មិថុនា/2009 | វចនានុក្រមខ្មែរ ជួន ណាត | 113,400 | 157,475,940 |
| 40 | ព.22/កក្កដា/2009 | សេវាទូរសព្ទ | 40,000 | 157,435,940 |
| 41 | អ.11/សីហា/2009 | សៀវភៅភាសាខ្មែរទី៤-៧ | 12,000 | 157,423,940 |
| 42 | អ.11/សីហា/2009 | បញ្ចូលទឹកព្រីនធ័រSumsung | 34,000 | 157,389,940 |
| 43 | ព្រ.11/សីហា/2009 | ធ្វើហ្វុនអក្សរ | 60,000 | 157,329,940 |
| 44 | ព.2/កញ្ញា/2009 | sticker បិតម៉ាស៊ីនត្រជាក់ | 16,000 | 157,313,940 |
| 45 | ព.2/កញ្ញា/2009 | សៀវភៅវេយ្យាករណ៍បាឡី | 24,000 | 157,289,940 |
| 46 | ព.26/កញ្ញា/2009 | ទិញម៉ាស៊ីនត្រជាក់ | 2,420,000 | 154,869,940 |
| 47 | ព.26/កញ្ញា/2009 | ទុយោនិងឈ្នួលដាក់ម៉ាស៊ីនត្រជាក់ | 730,000 | 154,139,940 |
| 48 | ព.14/តុលា/2009 | ថតចម្លងវចនានុក្រមខ្មែរ ជួន ណាតនិងសៀវភៅថៃ | 620,000 | 153,519,940 |
| 49 | ព.11/វិច្ឆិកា/2009 | ចូលបុណ្យនិងកម្រងផ្កាបុណ្យសពលោក ប្រាក់ ព្រុំ | 520,000 | 152,999,940 |
| 50 | អ.16/វិច្ឆិកា/2009 | បញ្ចូលទឹកព្រីនធ័រ Sumsung | 33,600 | 152,966,340 |
| 51 | ព.18/វិច្ឆិកា/2009 | កម្មវិធីកំចាត់មេរោគ និង format computer | 71,400 | 152,894,940 |
| 52 | អ.24/វិច្ឆិកា/2009 | ថតចម្លងសៀវភៅថៃទាក់ទងសង្រ្គាមជាមួយប្រ/ទជិតខាង | 135,400 | 152,759,540 |
| 53 | ព.9/ធ្នូ/2009 | ផ្ញើព្រឹត្តិបត្រទៅប្រទេសបារាំង | 83,800 | 152,675,740 |
| 54 | ព.9/ធ្នូ/2009 | Microphone ២ខ្សែ | 665,700 | 152,010,040 |
| 55 | ព.9/ធ្នូ/2009 | កាតទូរសព្ទ | 60,000 | 151,950,040 |
| 56 | ព្រ.24/ធ្នូ/2009 | សៀវភៅក្រសួងអប់រំគ្រប់មុខពីថ្នាក់១០-១១ | 121,200 | 151,828,840 |

| | | | | |
|---|---|---|---|---|
| 57 | 25/ធ្នូ/2009 | ចូលបុណ្យសពឪពុកក្មេក ឯ.ឧ បណ្ឌិត ហ៊ាន សាហ៊ីប | 200,000 | 151,628,840 |
| 58 | 27/មករា/2010 | ទឹកថ្នាំម៉ាស៊ីនថតចម្លង | 252,000 | 151,376,840 |
| 59 | ព.3/កុម្ភៈ/2010 | បន្ថែមបោះពុម្ពព្រឹត្តិបត្រលេខ២ | 3,000,000 | 148,376,840 |
| 60 | 1/មីនា/2010 | ឌីហ្សង់ទ័រ១០០ អំពែរ | 114,000 | 148,262,840 |
| 61 | 19/មីនា/2010 | Flash និងផ្ញើព្រឹត្តិបត្រទៅលោក Doung Cooper | 115,500 | 148,147,340 |
| 62 | 21/មីនា/2010 | ផ្សាយពាណិជ្ជកម្មតាមកោះសន្តិភាព | 84,000 | 148,063,340 |
| 63 | 7/មេសា/2010 | ថ្មី Microphone ២៨ កូន | 58,800 | 148,004,540 |
| 64 | 7/មេសា/2010 | ប្រដាប់លុបក្តារខៀននិងទឹកជូតកញ្ចក់ | 12,000 | 147,992,540 |
| 65 | 10/មេសា/2010 | CD រូបភាពសម្តេចហ៊ុន សែន បូកសរុបការងារអប់រំ | 84,000 | 147,908,540 |
| 66 | 5/ឧសភា/2010 | វចនានុក្រមILustraited oxford Dictionary | 86,100 | 147,822,440 |
| 67 | 5/ឧសភា/2010 | Collin Cobuil English Dictionary | 147,000 | 147,675,440 |
| 68 | 5/ឧសភា/2010 | Dictionary of Contemporary Longman | 136,500 | 147,538,940 |
| 69 | 5/ឧសភា/2010 | រៀបចំធ្វើព្រះរាជក្រឹត្យ | 200,000 | 147,338,940 |
| 70 | 13/ឧសភា/2010 | បញ្ចូលទឹកព្រីនធ័រពណ៌ | 120,000 | 147,218,940 |
| 71 | 18/ឧសភា/2010 | ថតចម្លងនិងទិញក្រូណូ | 10,800 | 147,208,140 |
| 72 | 12/មិថុនា/2010 | ថតចម្លងសៀវភៅកម្មសិទ្ធិបញ្ញា | 52,000 | 147,156,140 |
| 73 | 12/មិថុនា/2010 | រៀបចំព្រះរាជក្រឹត្យ-អនុក្រឹត្យ | 410,000 | 146,746,140 |
| 74 | 12/មិថុនា/2010 | វចនានុក្រមអក្ខរាវិរុទ្ធ | 32,760 | 146,713,380 |
| 75 | 16/មិថុនា/2010 | រៀបចំធ្វើព្រះរាជក្រឹត្យ-អនុក្រឹត្យ | 400,000 | 146,313,380 |
| 76 | 23/មិថុនា/2010 | ថ្មពិលនិងផ្ទាំងសាកថ្ម | 124,700 | 146,188,680 |
| 77 | 27/មិថុនា/2010 | ថតចម្លងវចនានុក្រមសំស្ក្រឹតនិងកម្រងច្បាប់ពាណិជ្ជកម្ម | 144,600 | 146,044,080 |
| 78 | 30/មិថុនា/2010 | ធ្វើក្បាលមីក្រូFM | 20,000 | 146,024,080 |
| 79 | 2/កក្កដា/2010 | ទំនាក់ទំនងការងាររៀបចំព្រះរាជក្រឹត្យ -អនុក្រឹត្យ | 129,000 | 145,895,080 |
| 80 | 19/កក្កដា/2010 | ធ្វើLogo | 102,400 | 145,792,680 |
| 81 | 28/កក្កដា/2010 | ថតចម្លងឯកសារ | 28,000 | 145,764,680 |
| 82 | 28/កក្កដា/2010 | សេវាបង្ហោះគេហទំព័រ | 200,000 | 145,564,680 |
| 83 | 28/កក្កដា/2010 | ថតចម្លងព្រះរាជក្រឹត្យ-អនុក្រឹត្យ | 30,000 | 145,534,680 |
| 84 | 7/សីហា/2010 | រៀបចំប្រជុំពិនិត្យអនុក្រឹត្យ | 140,300 | 145,394,380 |
| 85 | 11/សីហា/2010 | រៀបចំអនុក្រឹត្យ | 100,000 | 145,294,380 |
| 86 | 18/សីហា/2010 | វចនានុក្រមអក្ខរាវិរុទ្ធដាក់ក្នុងបណ្ណាល័យគជភខ | 99,450 | 145,194,930 |
| 87 | 20/សីហា/2010 | ឌីហ្សង់ទ័រ៨០ អំពែរ+ឈ្នួល | 339,700 | 144,855,230 |

| | | | | |
|---|---|---|---|---|
| 88 | 18/កញ្ញា/2010 | ថតចម្លងសំណៅព្រឹត្តិបត្រ | 55,900 | 144,799,330 |
| 89 | 14/តុលា/2010 | សៀវភៅក្រសួងអប់រំ | 157,000 | 144,642,330 |
| 90 | 20/តុលា/2010 | ព្រីដោតភ្លើង | 75,250 | 144,567,080 |
| 91 | 29/តុលា/2010 | សេវាទូរសព្ទនិងថតចម្លងឯកសារ | 84,000 | 144,483,080 |
| 92 | 29/តុលា/2010 | ជូនលោក មៀច ប៉ុណ្ណ ឈឺ | 400,000 | 144,083,080 |
| 93 | 8/វិច្ឆិកា/2010 | បង្គប់បោះពុម្ពព្រឹត្តិបត្រលេខ៣ | 170,000 | 143,913,080 |
| 94 | 10/វិច្ឆិកា/2010 | ថតចម្លងព្រះរាជក្រឹត្យ-អនុក្រឹត្យ | 21,600 | 143,891,480 |
| 95 | 5/មករា/2011 | វចនានុក្រម១៣ ក្បាល | 3,076,000 | 140,815,480 |
| 96 | 5/មករា/2011 | អ៊ុតក្របវចនានុក្រម | 70,000 | 140,745,480 |
| 97 | 12/មករា/2011 | បង្គប់បើកឱ្យកម្មករ | 80,000 | 140,665,480 |
| 98 | 26/មករា/2011 | បោះពុម្ពព្រឹត្តិបត្រលេខ៣ | 9,840,000 | 130,825,480 |
| 99 | 9/កុម្ភៈ/2011 | កម្មវិធីកំចាត់មេរោគ | 60,000 | 130,765,480 |
| 100 | 15/មិថុនា/2011 | បង្គប់បើកឱ្យកម្មករខែ ៨-១០-២០១០ | 440,000 | 130,325,480 |
| 101 | 13/កក្កដា/2011 | ចូលបុណ្យនិងជួយឧបត្ថម្ភកម្មករឈឺ | 400,000 | 129,925,480 |
| 102 | 10/សីហា/2011 | វចនានុក្រមតិប យក់ ថាវគន្ធ | 98,400 | 129,827,080 |
| 103 | 10/សីហា/2011 | ហ្វឺត សរសេរ | 8,200 | 129,818,880 |
| 104 | 21/កញ្ញា/2011 | ឱ្យសន្តិសុខ | 100,000 | 129,718,880 |
| 105 | 22/កញ្ញា/2011 | ធ្វើត្រា | 300,000 | 129,418,880 |
| 106 | 5/តុលា/2011 | ដាក់ទូរសព្ទលើតុ៣ គ្រឿង | 540,000 | 128,878,880 |
| 107 | 7/តុលា/2011 | ថតចម្លងសេចក្តីសម្រេចគណៈកម្មការបច្ចេកសព្ទ | 83,000 | 128,795,880 |
| 108 | 9/តុលា/2011 | បង្គប់បើកឱ្យកម្មករ | 160,000 | 128,635,880 |
| 109 | 12/តុលា/2011 | បង្គប់បើកឱ្យកម្មករ | 360,000 | 128,275,880 |
| 110 | 16/តុលា/2011 | បង្ហោះគេហទំព័រ | 300,000 | 127,975,880 |
| 111 | 17/តុលា/2011 | តុប្រជុំ | 23,452,000 | 104,523,880 |
| 112 | 18/តុលា/2011 | កម្មករលើកតុនិងរៀបចំតុ | 160,000 | 104,363,880 |
| 113 | 16/វិច្ឆិកា/2011 | ឌីហ្សាញឡូហ្គូ | 42,000 | 104,321,880 |
| 114 | 16/វិច្ឆិកា/2011 | ក្រដាសរ៉ាម | 450,000 | 103,871,880 |
| 115 | 16/វិច្ឆិកា/2011 | ទឹកសុទ្ធសម្រាប់ប្រជុំ | 134,400 | 103,737,480 |
| 116 | 16/វិច្ឆិកា/2011 | បញ្ចូលទឹកព្រីនធ័រ | 100,000 | 103,637,480 |
| 117 | 16/វិច្ឆិកា/2011 | ធ្វើកូនសោបន្ទប់ប្រជុំ | 30,000 | 103,607,480 |
| 118 | 16/វិច្ឆិកា/2011 | ជួសជុលម៉ាស៊ីនថតចម្លង | 528,888 | 103,078,592 |

| | | | | |
|---|---|---|---|---|
| 119 | 16/វិច្ឆិកា/2011 | កម្មវិធីកំចាត់មេរោគ | 140,000 | 102,938,592 |
| 120 | 16/វិច្ឆិកា/2011 | ស្រោមសំបុត្រ | 40,000 | 102,898,592 |
| 121 | 7/ធ្នូ/2011 | Microphone និង Sticker | 15,548,000 | 87,350,592 |
| 122 | 7/មករា/2012 | ចងក្រងព្រឹត្តិបត្រនិងប្រព័ន្ធលេខគំរូ | 250,000 | 87,100,592 |
| 123 | 7/មករា/2012 | កម្មករលើកទូដែក | 40,000 | 87,060,592 |
| 124 | 9/មករា/2012 | រ៉ូឡូនិងថ្មតេឡេម៉ាស៊ីនត្រជាក់ | 224,000 | 86,836,592 |
| 125 | 30/មករា/2012 | គូរ Logo ថ្មី | 400,000 | 86,436,592 |
| 126 | 8/កុម្ភៈ/2012 | ជួសជុលម៉ាស៊ីនព្រីនធ័រ | 80,000 | 86,356,592 |
| 127 | 17/កុម្ភៈ/2012 | កៅអីប្រជុំគជភខ | 21,280,000 | 65,076,592 |
| 128 | 18/កុម្ភៈ/2012 | សម្អាត-រៀបចំតុបន្ទប់ប្រជុំ | 120,000 | 64,956,592 |
| 129 | 22/កុម្ភៈ/2012 | កម្មករសែងកៅអី | 50,000 | 64,906,592 |
| 130 | 24/កុម្ភៈ/2012 | ថតចម្លងសម្រង់ពាក្យឡ,លនិងណ,ន | 700,000 | 64,206,592 |
| 131 | 17/កញ្ញា/2012 | ចូលបុណ្យសពលោក មៀច ប៉ុណ្ណ | 1,000,000 | 63,206,592 |
| 132 | 17/កញ្ញា/2012 | ធ្វើកូរ៉ោនចូលរួមរំលែកទុក្ខសពលោក មៀច ប៉ុណ្ណ | 200,000 | 63,006,592 |
| 133 | 3/តុលា/2012 | ចូលបុណ្យសពម្តាយឧត្តមសេនីយទោ ឡាយ ប៊ុនថន | 200,000 | 62,806,592 |
| 134 | 24/មករា/2013 | ចូលបុណ្យសពម្តាយឯកឧត្តមបណ្ឌិត ស៊ុន ហួរ | 200,000 | 62,606,592 |
| 135 | 25/កុម្ភៈ/2013 | ចូលបុណ្យសពឯកឧត្តម ខៀវ សុម៉េត | 200,000 | 62,406,592 |
| 136 | 25/កុម្ភៈ/2013 | ធ្វើកូរ៉ោនចូលរួមរំលែកទុក្ខសពឯកឧត្តម ខៀវ សុម៉េត | 180,000 | 62,226,592 |
| 137 | 1/មីនា/2013 | ចូលរួមក្នុងកម្មវិធីសិទ្ធិនារី | 800,000 | 61,426,592 |
| 138 | 14/កក្កដា/2013 | ផ្សាយលិខិតចូលរួមមរណៈទុក្ខមហាឧបាសក ហ៊ុន នាង ក្នុងកាសែតកោះសន្តិភាព | 800,000 | 61,426,592 |
| 139 | 2/សីហា/2013 | ចូលបុណ្យសពម្តាយឯកឧត្តម បួន លីមហេង | 200,000 | 62,026,592 |
| 139 | 5/សីហា/2013 | បោះពុម្ពសទ្ទានុក្រមឈ្មោះប្រទេស+ភាសាវិទ្យា/អ.សិ. | 12,956,000 | 48,470,592 |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ
អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
គេហទំព័រ : www.nckl.gov.kh, ទូរសព្ទ :០១២ ៤៧៣ ៧០១,០១២ ៩០៦ ៥៨៥,០៩២ ៨៩២ ៣៤៣

National Council of Khmer Language
Conseil National de la Langue Khmère
ទូរសារ : ០២៣ ៨៦៦ ២០៧. អ៊ីមែល : info@nckl.gov.kh

លេខ៥ បោះពុម្ពចំនួន ២ ០០០ ច្បាប់
បោះពុម្ពនៅរោងពុម្ព ជោគជ័យ
ផ្ទះលេខ៧៤៩  មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្រាបែក ខណ្ឌចំការមន រាជធានីភ្នំពេញ